ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០៩**

**សវនាការលើអង្គសេចក្តី (លើកទី៤)**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន
លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍
*(Judge Silvia Carwright)*
លោក យ៉ា សុខន
លោក ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc Lavegne)*
លោក ធូ មណី
លោក យូរ ឧត្តរា
លោកស្រី ក្លូឌា ហ្វេនស៍ *(Ms.Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក លឹម សួយហុង
លោក ម៉ាត្ទូ គ្រីស្ពារ
*(Mr. Matteo Crippa)*
លោកស្រី សែ កុលវុឌ្ឍី
កញ្ញា ណាថាក់ វិចស៊ែល
*(Ms. Natacha Wexels-Riser)*
លោក ឌុច ផារី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក រ៉ូប៊ឺត ពេទីត *(Mr. Robert Petit)*

លោក យ៉េត ចរិយា

លោក តាន់ សេណារ៉ុង

លោក អាឡិចសាន់ឌឺ បេ៊ត

*(Mr. Alexander Bates)*

លោក ជឺហ៊្គិន អាស្មាន*(M.r Jurgen Assmann)*

លោក ប៉ាក ចាន់លីណូ (ក្រឡាបញ្ជី)

**មេធាវីការពារជនជាប់ចោទ កាំង ហ្គេក អ៊ាវ ៖**

លោក ការ សាវុត្ថ

លោក ហ្វ្រង់ស្វ័រ រូ *(Mr. François ROUX)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms.Heleyn UNAC)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ហុង គីមសួន

លោក គង់ ពិសី

លោក យុង ផានិត

លោក គឹម ម៉េងឃី

កញ្ញា ទី ស្រ៊ីនណា

កញ្ញា ម៉ុច សុវណ្ណារី

លោកស្រី ស៊ីលឃើស្ទួត ហ្សីនស្គី

*(Ms. Silke Studzinsky)*

លោក អាឡាំង វ៉ែនណឺ

*(Mr. Alain Werner)*

លោក ហ្វីលីព កាណុន

*(Mr. Philippe Canonne)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក កូវ កែវរតនៈ

# ឧបសម្ព័ន្ធ

## សាក្សី

**សាក្សី** ៖ ជនជាប់ចោទ **កាំង ហ្គេកអ៊ាវ** ហៅ ឌុច
ត្រួតពិនិត្យដោយ ចៅក្រម **ហ្សង់ម៉ាក ឡាវែន៍** ផ្តើមពី................................................. ទំព័រ ២០

## បញ្ជីឈ្មោះ អ្នកនិយាយ៖

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| កញ្ញា ម៉ុច សុវណ្ណារី | ខ្មែរ |
| លោក រ៉ូបឺត ពេទីត | អង់គ្លេស |
| លោក ហ្វ្រង់ស្វ័រ រូ | បារាំង |
| ជនជាប់ចោទ | ខ្មែរ |
| ចៅក្រម និល ណុន (ប្រធាអង្គជំនុំជម្រះ) | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

*[ចៅក្រមចូលមកកាន់បន្ទប់សវនាការ]*

[0៩:0៨:00]

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញអង្គុយចុះ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសាលាដំបូងប្រកាសបន្តសវនាការ ។

ជាដំបូងនេះ អង្គជំនុំជម្រះសូមអញ្ជើញក្រឡាបញ្ជីឡើងរាយការណ៍ អំពីស្ថានភាពវត្តមាន និង អវត្តមានភាគី ដែលត្រូវចូលរួមនៅក្នុងនីតិវិធីសវនាការនៅព្រឹកនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធាន ខ្ញុំបានត្រួតពិនិត្យវត្តមាន អវត្តមាន និងអត្តសញ្ញាណរបស់ភាគី ដែល បានចូលរួមក្នុងដំណើរការនីតិវិធីរួចរាល់ហើយ ហើយដែលក្នុងថ្ងៃនេះ មានមេធាវីដើមបណ្តឹងរដ្ឋប្បវេ-ណី ទើបតែមានវត្តមាន គឺលោក *ហ្វីលីព កាណុន* សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ក្រឡាបញ្ជីបញ្ចូលនៅបញ្ជីវត្តមាន អវត្តមាននៃភាគីចូលរួមនៃនីតិវិធីសវនាការនៅព្រឹកនេះចូល ទៅក្នុងប្រតិចារឹក?

ជាកិច្ចបន្តអង្គជំនុំជម្រះសូមធ្វើការឆ្លើយតបចំពោះបញ្ហាមិនទាន់ដោះស្រាយ ដែលភាគីនានាបាន លើកឡើងនៅក្នុងអំឡុងពេលសវនការ នាថ្ងៃទី៣១ ខែមីនា និង ថ្ងៃទី១ ខែមេសា ឆ្នាំ២០០៩ កន្លងមក ។ អង្គជំនុំជម្រះសូមឆ្លើយដោយសង្ខេបចំពោះសំណើសុំបំភ្លឺផ្សេងៗ ដែលភាគីនានាបានលើកឡើងក្នុង អំឡុងពេលសវនាការកាលពីសប្តាហ៍មុន។ បន្ទាប់មកអង្គជំនុំជម្រះសាលាដំបូងនឹងចេញសេចក្តីសម្រេច ចំនួនពីរ ។

សេចក្តីបំភ្លឺទីមួយ អង្គជំនុំជម្រះសូមលើកឡើងថា ជាថ្មីចំពោះការយល់ឃើញរបស់ខ្លួនថា នៅ ក្នុងអំឡុងពេលឆ្លើយតបទៅនឹងការធ្វើសេចក្តីសន្និដ្ឋានសង្ខេបបើកការចោទប្រកាន់របស់សហព្រះរាជ អាជ្ញា មេធាវីការពារក្តីមិនបានស្នើសុំជាផ្លូវការណាមួយស្តីពីនីត្យានុកូលភាពនៃដំណើរការនីតិវិធី ឬមួយ

យុត្តាធិការរបស់តុលាការទេ ។

សេចក្តីបំភ្លឺទីពីរ អង្គជំនុំជម្រះសូមបញ្ជាក់ អំពីបញ្ហាកម្មវិធីជំនុំជម្រះ ការសួរចម្លើយជនជាប់ចោទ ការស្តាប់ចម្លើយសាក្សី អ្នកជំនាញ ព្រមទាំងការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ។

[០៩:១៣:០២]

អង្គជំនុំជម្រះសាលាដំបូងសូមលើកឡើងសាជាថ្មីនូវអ្វី ដែលបានចែងនៅក្នុងសេចក្តីណែនាំស្តីពីកម្មវិធីជំនុំជម្រះចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៩ ថា “អង្គជំនុំជម្រះនឹងសួរចម្លើយជនជាប់ចោទមុន និងបន្ទាប់មកអង្គជំនុំជម្រះនឹងស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញពាក់ព័ន្ធ” ជាបន្តបន្ទាប់ទៅតាមលំដាប់លំដោយ ដែលខ្លួនយល់ឃើញថាមានប្រយោជន៍ ។

អង្គជំនុំជម្រះសាលាដំបូងគ្រោងនឹងអនុវត្តតាមលំដាប់លំដោយនៃអង្គហេតុដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។ ភាគីនឹងត្រូវបានផ្តល់ជូនដំណឹងអំពីអង្គហេតុដែលកំណត់សម្រាប់ថ្ងៃសវនាការប្រហែលពីរសប្តាហ៍ជាមុន ។ ចំពោះអង្គហេតុនីមួយៗនោះ អង្គជំនុំជម្រះនឹងស្តាប់ការសួរចម្លើយជនជាប់ចោទជាមុន និងបន្ទាប់មកនឹងផ្តល់ឱកាសឲ្យភាគីនានាសួរសំណួរទីកាន់ជនជាប់ចោទ ។

បន្ទាប់មកទៀត អង្គជំនុំជម្រះនឹងហៅដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញដែលពាក់ព័ន្ធនឹងអង្គហេតុនោះ ។ ដើមបណ្តឹង សាក្សី និងអ្នកជំនាញនឹងត្រូវបានអង្គជំនុំជម្រះស្តាប់ចម្លើយជាមុន និងបន្ទាប់មកអង្គជំនុំជម្រះនឹងផ្តល់វេទិការជូនទៅភាគីនានា ។

អនុលោមតាមវិធានផ្ទៃក្នុង អ.វ.ត.ក ជនជាប់ចោទគួរតទល់ជាមួយចម្លើយជាលាយលក្ខណ៍អក្សររបស់សាក្សីបានតែនៅក្រោយពេលដែលសាក្សីនោះត្រូវបានគេស្តាប់ចម្លើយរួចប៉ុណ្ណោះ ។ ប្រសិនបើសាក្សីនោះ អាចត្រូវបានគេនាំមកកាន់តុលាការ ។

អនុលោមតាមវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក អង្គ ជំនុំជម្រះះសាលាដំបូងនឹងខិតខំប្រឹងប្រែកោះហៅសាក្សីនីមួយៗតែម្តងប៉ុណ្ណោះ ។ ប៉ុន្តែ ចំពោះសាក្សីដែលពាក់ព័ន្ធជាមួយនឹងអង្គហេតុលើសពីមួយ អង្គជំនុំជម្រះសាលាដំបូងនឹងសម្រេចតាមករណីជាក់ស្តែងថា តើសាក្សីទាំងនោះគួរកោះហៅមកស្តាប់ចម្លើយតែម្តង ចំពោះអង្គហេតុទាំងអស់ ឬថាតើសាក្សីទាំងនោះគួរកោះហៅមកសាជាថ្មី ?

បន្ទាប់មកភស្តុតាងបន្ថែមណាមួយពាក់ពន្ធ័នឹងអង្គហេតុនេះនឹងត្រូវយកមកអាន ឬសង្ខេបដោយអនុលោមតាមបទប្បញ្ញត្តិនៃវិធាន ៨៧.២ ។

អង្គជំនុំជម្រះសូម បញ្ជាក់ថា ការសួរតទល់គឺជារបៀបសួរសំណួរបែបប្រព័ន្ធច្បាប់ ខំមិនឡ

ដំណើរការនីតិវិធីចំពោះមុខ តុលាការនេះត្រូវបានគ្របដណ្តប់ដោយប្រព័ន្ធច្បាប់ ស៊ីវិលឡ។ ការសួរតទល់គ្នាដែលជារបៀបសួរសំណួរនេះមិនសមស្របទេសម្រាប់ប្រព័ន្ធច្បាប់ស៊ីវិលឡ។ ចំពោះការកំណត់កម្មវិធីសវនាការសម្រាប់ដំណើរការសវនាការ ដើមបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះសាលាដំបូងនឹងស្តាប់ចម្លើយរដ្ឋប្បវេណីទាំងឡាយណាដែលបានដឹងអំពីអង្គហេតុជាក់លាក់នៅពេលជំនុំជម្រះពិចារណាលើអង្គហេតុទាំងនោះ ។ ចំពោះដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀត នឹងត្រូវបានស្តាប់ចម្លើយ នៅពេលដូចគ្នានៅ ពេលជិតដល់ចុងបញ្ចប់នៃដំណើរការជំនុំជម្រះ ។

[០៩:១៦:១៨]

ឥឡូវនេះយើងមិនទាន់អាចកំណត់អំពីការកំណត់កម្មវិធីសវនាការសម្រាប់ដើមបណ្តឹងរដ្ឋប្បវេ-ណីទាំងនោះបាននៅឡើយទេ ។ អង្គជំនុំជម្រះនឹងជូនដំណឹងអំពីកម្មវិធីសវនាការនេះដល់ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី អ្នកជំនាញ ចំនួនពីសប្តាហ៍ជាមុន។ ប៉ុន្តែ ចំពោះដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលរស់នៅក្រៅប្រទេស អង្គជំនុំជម្រះនឹងខិតខំជូនដំណឹងអំពីកម្មវិធីសវនាការនេះយ៉ាងតិច៤សប្តាហ៍ជាមុន ។ វាជាការល្អសម្រាប់ការជូនដំណឹងអំពីកម្មវិធីសវនាការសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញដែលរស់នៅក្រៅប្រទេស ។ ប្រសិនបើ អ្នកទាំងនោះអាចជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងឲ្យបានឆាប់តាមដែលអាចធ្វើទៅបានអំពីកាលបរិច្ឆេទដែលខ្លួនអាចចូល ឬមិនអាចចូលបានតាមការកោះហៅរបស់អង្គជំនុំជម្រះ ។

សេចក្តីបំភ្លឺទីបី លោក ហុង គឹមសួន ជាមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ និងតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុម៤ បានលើកឡើងថា រហស្សនាមដែលប្រើនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនស៊ីគ្នានឹងរហស្សនាមដែលជនជាប់ចោទ-- (សុំទោស) ដែលអង្គជំនុំជម្រះសាលាដំបូងបានប្រើកន្លងមកនោះទេ ។ អង្គជំនុំជម្រះសូមបញ្ជាក់ថា ក្នុងអំឡុងពេលសវនាការ ភាគីត្រូវប្រើរហស្សនាមដែលអង្គជំនុំជម្រះសាលាដំបូងបានដាក់ឲ្យសម្រាប់ហៅសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវទទួលវិធានការការពារ ។

ភាពខុសគ្នាក្នុងការប្រើប្រាស់រហស្សនាម ដូចដែលបានលើកឡើងដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដោយហេតុថា តុលាការត្រូវអានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលជាឯកសារសាធារណៈ ដែលសហចៅក្រមស៊ើបអង្កេតជាអ្នកដាក់រហស្សនាមឲ្យសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីទាំងនោះ ។

ជាចុងបញ្ចប់អង្គជំនុំជម្រះចេញសេចក្តីសម្រេចចំនួនពីរ ដូចខាងក្រោម៖

សេចក្តីសម្រេចទីមួយ: អង្គជំនុំជម្រះសាលាដំបូងសម្រេចបដិសេធនូវសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ ដែលបានស្នើឲ្យផ្តល់ឱកាសលើកមតិយោបល់ចំពោះចម្លើយតបរបស់ជនជាប់ចោទដែលបានឆ្លើយតបនឹងសេចក្តីសន្និដ្ឋានចោទប្រកាន់របស់សហព្រះរាជអាជ្ញា ។ ដោយហេតុថាវិធាន៨៩ ស្ទួន២ ផ្តល់ឱកាសឲ្យជនជាប់ចោទឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានចោទប្រកាន់របស់សហព្រះរាជអាជ្ញា ប៉ុន្តែ មិនបានផ្តល់ឱកាសឲ្យខាងរដ្ឋប្បវេណីធ្វើការឆ្លើយតបណាមួយទេ។ ផ្ទុយពីការលើកឡើងរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីគឺថា ជនជាប់ចោទមានឱកាសឆ្លើយតបចំពោះសេចក្តីសន្និដ្ឋានចោទប្រកាន់មានចែងនៅក្នុងវិធានផ្ទៃក្នុងនេះ ។

សេចក្តីសម្រេចទីពីរ:

២(ក) អង្គជំនុំជម្រះសាលាដំបូងសម្រេចបដិសេធនូវសំណើរបស់ដើម បណ្តឹងរដ្ឋប្បវេណីដែលសុំធ្វើសេចក្តីសន្និដ្ឋាន ទាក់ទិងនឹងសំណើសុំរបស់មេធាវីការពារក្តីសុំឲ្យដោះលែងជនជាប់ចោទបាននៅក្រៅឃុំក្នុងអំឡុងពេលសវនាការ និងឯកសារដែលដាក់ដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី កាលពីថ្ងៃទី១ ខែមេសា ឆ្នាំ២០០៩ ឯកសារលេខ E៣៩ ដែលស្នើសុំ ឆ្លើយតបទៅនឹងមេធាវីការពារក្តី។ ដោយហេតុថា វិធានផ្ទៃក្នុង៨២ អនុវិធាន៣ មិនបានផ្តល់លទ្ធភាព ឲ្យមានអន្តរាគមន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីដូចលើកឡើងនោះទេ ។ វិធាននេះដែលខុសគ្នាពីច្បាប់នៃព្រះរាជាណាចក្រកម្ពុជា កើត ចេញមកពីការសម្រេចដោយប្រុងប្រយ័ត្នរបស់កិច្ចប្រជុំពេញអង្គ របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលបានសម្រេចនេះ រៀបចំឲ្យមានការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងដំណើរការនីតិវិធីចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលសាលាក្តីនេះ ត្រូវដោះស្រាយបទឧក្រិដ្ឋធំៗ ដែលថ្លឹងថ្លែងនូវសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាមួយនឹងតម្រូវការ ឲ្យមានការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងឆាប់រហ័ស ។

[០៩:២០:២៥]

អង្គជំនុំជម្រះសាលាដំបូង យកចិត្តទុកដាក់ជានិច្ចចំពោះសេចក្តីសម្រេចដែលចេញដោយអង្គបុរេជំនុំជម្រះថាមានសារសំខាន់ណាស់ ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងមិនជាប់កាតព្វកិច្ចនិងសេចក្តីសម្រេចទាំងនោះទេ ។

២(ខ) ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានអញ្ជើញឲ្យផ្តល់មតិយោបល់លើសំណើបន្ទាប់បន្សំរបស់

សហមេធាវីការពារក្តីដែលបានលើកឡើងថា រយៈពេលនៃការឃុំខ្លួនជនជាប់ចោទនៅតុលាការយោធាត្រូវបានលើកយកមកពិចារណាចំពោះគោលបំណងនៃការផ្តន្ទាទោស ។ ជនជាប់ចោទមានសិទ្ធិស្នើសុំកាត់បន្ថយការផ្តន្ទាទោសជាថ្នូរនឹងការរំលោភបំពានសិទ្ធិរបស់ជនជាប់ចោទ ។ មតិយោបល់របស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរនៅក្នុងរយៈពេល៥ថ្ងៃ គិតចាប់ពីថ្ងៃនេះតទៅ ដោយហេតុថា ជាធម្មតាដើមបណ្តឹងរដ្ឋប្បវេណីនឹងមិនអនុញ្ញាតឲ្យផ្តល់មតិយោបល់ចំពោះការផ្តន្ទាទោសដែលត្រូវដាក់លើជនជាប់ចោទនោះទេ។ អង្គជំនុំជម្រះអញ្ជើញឲ្យដើមបណ្តឹងរដ្ឋប្បវេណីផ្តល់មតិយោបល់លើសំណើ បន្ទាប់បន្សំទាក់ទងនឹងបញ្ហាច្បាប់តែប៉ុណ្ណោះ ។

ជាកិច្ចនីតិវិធីបន្ទាប់នេះ មុននឹងចាប់ផ្តើមដំណើរការនីតិវិធីពិភាក្សាលើអង្គហេតុម-១៣ ដោយអនុលោមតាមវិធាន២៣.៧(ង).១នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះដំបូង ។ សូមអញ្ជើញមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី ឡើងធ្វើការស្នើសុំទទួលស្គាល់មេធាវីបរទេសដែលជាដៃគូរបស់ខ្លួនដែលមិនទាន់បានធ្វើការស្នើសុំទទួលស្គាល់ពីអង្គជំនុំជម្រះសាលាដំបូង ក្នុងអំឡុងពេលប្រជុំរៀបចំសវនាការ និងសវនាការបឋមកន្លងមក។ សូមអញ្ជើញ មេធាវីតំណាង មេធាវីជាតិ តំណាងឲ្យដើមរដ្ឋប្បវេណីក្រុមបី ។

**កញ្ញា ម៉ុច សុវណ្ណារី៖**

នាងខ្ញុំមេធាវី ម៉ុច សុវណ្ណារី ជាដំបូងសូមគោរពដល់លោកប្រធានអង្គជំនុំជម្រះសាលាដំបូង ហើយនិងសូមគោរពដល់អង្គជំនុំជម្រះសាលាដំបូងទាំងមូល ។ នៅពេលនេះនាងខ្ញុំសូមបង្ហាញ និងសុំធ្វើការស្នើសុំឲ្យទទួលស្គាល់ដល់មេធាវីអន្តរជាតិដែលជាដៃគូរបស់នាងខ្ញុំ គឺលោកមេធាវី ហ្វីលីព កាណុន ដែលលោកជាប្រធាន គណៈមេធាវីមួយនៅប្រទេសបារាំង ហើយលោកបានទទួលការស្បថចូល ហើយបានទទួលបាននូវការអនុញ្ញាតឲ្យប្រកបវិជ្ជាជីវៈនៅក្នុងក្របខ័ណ្ឌនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហើយលោកបានគោរពតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជារួចហើយ ។ ហើយលោកត្រូវបានទទួលស្គាល់ដោយអង្គបុរេជំនុំជម្រះ ដើម្បីចូលរួមនៅក្នុងតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី នៅក្នុងដំណើរការនៃនីតិវិធីនេះដែរ ។

ដូច្នេះ នាងខ្ញុំសូមស្នើសុំដល់លោកប្រធាន និងអង្គជំនុំជម្រះសាលាដំបូងទាំងមូលទទួលស្គាល់គាត់ហើយអនុញ្ញាតឲ្យគាត់អាចនឹងចូលរួមនៅក្នុងដំណើរការនៃសវនាការលើអង្គសេចក្តីចាប់ពីពេលនេះតទៅ ។ នាងខ្ញុំសូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញក្រោកឈរលោកមេធាវី ហ្វីលីព កាណុន !

លោកមេធាវី ហ្វីលីព កាណុន អង្គជំនុំជម្រះទទួលស្គាល់លោកធ្វើមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមបីសម្រាប់គោលបំណងនៃកិច្ចដំណើរការនីតិវិធីចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនេះ ។ ដោយយោងទៅតាមការទទួលស្គាល់នេះ លោកមានសិទ្ធិ និងបុព្វសិទ្ធិដូចគ្នានិងមេធាវីជាតិដែរ ចាប់ពីពេលនេះតទៅ ។ សូមអង្គុយចុះ ។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទ កាំង ហ្គេកអ៊ាវ មកកាន់ឈើរាងវង់ក្រចកសេះដែលបានត្រៀមសម្រាប់ជនជាប់ចោទ ។

តទៅនេះ អង្គជំនុំជម្រះសូមជម្រាបថា ចាប់ពីពេលនេះទៅអង្គជំនុំជម្រះធ្វើសវនាការពិភាក្សាដេញដោលលើអង្គហេតុម-១៣ ។ មុននឹងចាប់ផ្តើមសួរសំណួរទៅដល់ជនជាប់ចោទអំពីអង្គហេតុពាក់ព័ន្ធនឹងមន្ទីរសន្តិសុខម-១៣ អង្គជំនុំជម្រះសាលាដំបូងសូមជម្រាបថា មុននឹងចាប់ផ្តើមសំណួរទៅជនជាប់ចោទអំពីអង្គហេតុពាក់ព័ន្ធម-១៣ អង្គជំនុំជម្រះសូមជម្រាបថា អង្គហេតុដែលប្រព្រឹត្តនៅមន្ទីរសន្តិសុខម-១៣ ដែលជនជាប់ចោទជាអ្នកទទួលខុសត្រូវមិនមែនជាផ្នែកនៃអង្គហេតុដែលមាននៅក្នុងដីកាបញ្ជូនរឿងមកជំនុំជម្រះនោះទេ ។ ពីព្រោះថា ទីមួយ យុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺកម្រិតត្រឹមថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។ ទីពីរដីកាដំណោះស្រាយបានយោងទៅលើតែលើអង្គហេតុពាក់ព័ន្ធទៅនឹង ឌុច ពាក់ព័ន្ធនឹងជនជាប់ចោទក្នុងឋានៈជាអនុលេខា និងក្រោយមកជាលេខានៃមន្ទីរស-២១ តែប៉ុណ្ណោះ ។ ប៉ុន្តែ ដើម្បីបានយល់ឲ្យកាន់តែច្បាស់នូវបរិបទរបស់ស-២១ រួមមានអង្គការចាត់តាំង រចនាសម្ព័ន្ធប្រតិបត្តិការរបស់មន្ទីរស-២១ និងហេតុផលនានា ព្រមទាំងបុគ្គលភាពរបស់ជនជាប់ចោទផងនោះ ដូច្នេះនៅពេលសវនាការនេះវាពិតជាមានការពាក់ព័ន្ធនឹងចាំបាច់ត្រូវត្រួតពិនិត្យលើបញ្ហានេះ ដែលជនជាប់ចោទខ្លួនឯងផ្ទាល់បានរៀបរាប់យ៉ាងនៅដំណាក់កាលស៊ើបសួរ និងការឆ្លើយតបជាលើកដំបូងទៅនឹងការចោទប្រកាន់សង្ខេបរបស់សហព្រះរាជអាជ្ញា ។

អង្គជំនុំជម្រះសូមជម្រាបជូនដល់ភាគីទាំងអស់ថា នៅពេលសួរសំណួរអំពីអង្គហេតុម-១៣ សំណួរទាំងឡាយនិងអាចសួរផងដែរ ពាក់ព័ន្ធនឹងបរិបទនយោបាយ និងប្រវត្តិសាស្ត្រនៅក្នុងអំឡុងពេលនោះ ។ ការឃុំខ្លួនជនជាប់ចោទនៅក្នុងអំឡុងឆ្នាំ១៩៦៨ ឆ្នាំ១៩៧០ និងបច្ច័យនានាអំពីការឃុំខ្លួន

គាត់នោះ ។ តួនាទីរបស់ជនជាប់ចោទនៅពេលបង្កើតមន្ទីរសន្តិសុខម-១៣ ជាការជាប់ពាក់ព័ន្ធរបស់ជនជាប់ចោទក្នុងបក្សកុម្មុយនីស្តកម្ពុជា ។ អង្គជំនុំជម្រះបានឃើញផងដែរនូវឯកសារនានាដែលមាននៅក្នុងសំណុំរឿងគឺ មួយចម្លើយរបស់ ហាម អ៊ីន ឯកសារ ស៊ីឌីខេម(ស៊ិក) ឧបសម្ព័ន្ធ៤ D៥៩ ចម្លើយរបស់ អ៊ិន វ៉ន ឯកសារ ស៊ីឌីខេម ឧបសម្ព័ន្ធ១២ D៥៩ ។ របាយការណ៍នៃការបញ្ជូនរឿងឲ្យ ស៊ើបសួររបស់សហព្រះរាជអាជ្ញាឯកសារលេខ ១៩២៥ ។ អត្ថបទដកស្រង់ចេញពី ស៊ីឌីខេម ទស្សនាវដ្តីស្វែងរកការពិតបោះពុម្ពពិសេសនៅខែកក្កដា ឆ្នាំ២០០៣ ប្រព័ន្ធសន្តិសុខរបស់តំបន់ពិសេសម-១៣ ដែលមានលេខ ERN ០០៨០៣៩៥ ដល់ ០០០៨០៤៥៧។ ចម្លើយរបស់ជនជាប់ចោទជាមួយតំណាង *យូ.អិន.អេច.ស៊ី.អរ* លោក *គ្រីស្តូហ្វើ ប៊ីស្ស៊ូ* ឯកសារ D៩ ។ ដោយហេតុនីតិវិធីនេះប្រព្រឹត្តទៅអស់រយៈពេលវែងគឺអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក កាំង ហ្កេកអ៊ាវ អាចអង្គុយ ដូច្នេះដើម្បីឆ្លើយតបទៅនឹងសំណួរផ្សេងៗ ។ ហើយមុននឹងមានសំណួរពាក់ព័ន្ធនឹងបញ្ហានេះ អង្គជំនុំជម្រះសូមជម្រាបសួរទៅលោក កាំង ហ្កេកអ៊ាវ ហៅ ឌុច ចូរលោកធ្វើការនិទានរៀបរាប់អំពីការបង្កើតនិងកិច្ចប្រតិបត្តិការនៃមន្ទីរសន្តិសុខម-១៣ ដែលមានទីតាំងស្ថិតនៅ អមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ និងម-១៣ ខ ផងដែរដែលលោកធ្លាប់ធ្វើការនៅទីនោះ ដែលលោកនៅចងចាំ ។ តើលោកអាចរៀបរាប់អំពីបញ្ហាដូចខាងលើនេះជូនដល់អង្គសវនាការបានជ្រាបអ្វីខ្លះទៅ ? សូមអញ្ជើញ ។

[០៩:២៩:៥៧]

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោប្រធានសូមអនុញ្ញាតពីលោកប្រធាន មុនឲ្យធ្វើជនជាប់ចោទនឹងឆ្លើយ មេធាវីសូមផ្តល់សេចក្តីសន្និដ្ឋានមួយចំនួនទាក់ទងនឹងឯកសារដែលលោកប្រធានបានយោងទៅលើ គឺជាសេចក្តីថ្លែងការណ៍របស់ ឌុច ដែលបានឆ្លើយទៅឲ្យអង្គការសហប្រជាជាតិដែលនិយាយសម្ភាសដោយលោក *គ្រីស្តូប៊ីស្ស៊ូ* ។ សេចក្តីថ្លៃការណ៍នេះ ត្រូវបានដាក់ចូលក្នុងសំណុំរឿង ដោយសហព្រះរាជអាជ្ញា នៅក្នុងសេចក្តីយោង៧១០ ។

នៅពេលដែលការិយាល័យសហចៅក្រមស៊ើបអង្កេត បានយោងទៅរកសេចក្តីថ្លែងការណ៍នេះគឺថាបានបញ្ជាក់យ៉ាងត្រឹមត្រូវ ទៅលើលេខយោងនោះ ។ សេចក្តីចម្លើយរបស់ កាំង ហ្កេក អ៊ាវ ហៅ ឌុច ដែលថាជា “ជនសង្ស័យ” ហៅថា *ដេចអ៊ីឌីអេច* ដែលគណៈកម្មាធិការឧត្តមស្នងការជនភៀសខ្លួនសហប្រជាជាតិនិយាយថា “ជាជនសង្ស័យ” ។ ហៅខាងសហព្រះរាជអាជ្ញា ហើយយើងបានយោងទៅ

រកលេខយោង៧១០ នៅក្នុងសេចក្តីរាយការណ៍នោះ ។

ទោះបីជានោះជាហេតុការណ៍ពិតដែលថា ឌុច នោះត្រូវបានសម្ភាសន៍ក្នុងខណៈជាជនសង្ស័យក៏ដោយ ។ កំណត់ហេតុនោះត្រូវតែមានព័ត៌មានមួយចំនួនដែលបញ្ជាក់ថា ឌុច ត្រូវបានប្រាប់ជាមុនថាគាត់មានសិទ្ធិនៅស្ងៀមមិនឆ្លើយតប ប៉ុន្តែព័ត៌មាននេះមិនមានបញ្ជាក់នៅក្នុងឯកសារនោះទេ ។ នេះមានន័យថា សេចក្តីថ្លែងការណ៍ដែលគាត់បានផ្តល់នោះ ត្រូវបានកត់ត្រាយកនៅពេលដែល ឌុច ស្ថិតនៅក្នុងករណីជាជនសង្ស័យ ដែលគាត់មិនមានការជូនដំណឹងថា គាត់មានសិទ្ធិនៅស្ងៀមមិនឆ្លើយតបនោះទេ ។ ដូច្នេះហើយៗគាត់មិនបានដឹងថាចម្លើយនោះ ថ្ងៃណាមួយនឹងដាក់ជូនសំណុំរឿងរបស់ព្រះរាជអាជ្ញាទេ។ អាស្រ័យហេតុនោះហើយ ដូចដែលមេធាវីតែងតែមេធាវីលើកជាញឹកញាប់នោះ បញ្ជាក់ជាថ្មីម្តងទៀត ឯកសារមួយនេះមិនគប្បីយកមកប្រើ ដើម្បីប្រឆាំងនឹងជនជាប់ចោទនោះទេ ។

ប្រសិនបើជនជាប់ចោទចង់យោងទៅរកឯកសារនោះ ជនជាប់ចោទអាចធ្វើដូច្នេះបាន ប៉ុន្តែ គ្មានករណីណាមួយដែលសហព្រះរាជអាជ្ញាអាចយោងទៅលើឯកសារនោះមកប្រើដើម្បីប្រឆាំងជនជាប់ចោទបានទេ ។ អរគុណ ។

[០៩:៣៣:០៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញា ។

**លោក រ៉ូបឺត ពេទីត៖**

អរគុណលោកប្រធាន ។ លោក លោកស្រីចៅក្រម អរុណសួស្តី! ខ្ញុំនឹងនិយាយដោយសង្ខេប ខ្ញុំសង្ឃឹមថាខ្ញុំនិយាយដោយសង្ខេប ។

តុលាការនេះដឹងហើយថា តុលាការនេះមានសេរីភាពក្នុងការពិចារណាភស្តុតាង ដែលពាក់ព័ន្ធដែលផ្តល់ក្នុងចំណោមភស្តុតាងផ្សេងៗ ។ ហើយភស្តុតាងទាំងអស់នោះ គឺក្នុងករណីដែលវាមិនផ្ទុយពីបញ្ញាយុត្តិធម៌ ។ ដូច្នេះ ខ្ញុំសូមសន្និដ្ឋានថា ការប្រកាស ឬចម្លើយរបស់ជនជាប់ចោទចំពោះអ្នកតំណាងពីររបស់ឧត្តមស្នងការសិទ្ធិមនុស្សនៅពេលនោះ គឺវាជាឯកសារពាក់ព័ន្ធ ។ នេះជាលក្ខណៈវិនិច្ឆ័យចំពោះករណីនេះ ។

ប្រសិនបើមានមូលដ្ឋានណាមួយ មេធាវីការពារក្តីគិតថា វាមានភាពចាំបាច់ក្នុងការដកចេញជាការពិតមេធាវីការពារក្តីបានគិតថា ក្នុងហេតុផលណាក៏ដោយចម្លើយមួយនេះ របស់ជនជាប់ចោទមិន

គួរជាផ្នែកមួយនៅក្នុងសំណុំរឿង ។ ដូច្នេះ មេធាវីការពារក្តី គឺគាត់មានកាតព្វកិច្ចច្បាស់លាស់ គឺកាតព្វកិច្ចច្បាស់លាស់មួយ ដើម្បីបង្ហាញនិងដាក់សំណើចំពោះមុខសហចៅក្រមស៊ើបអង្កេត ដើម្បីសុំដកចម្លើយនោះចេញពីសំណុំរឿង ។

នេះគឺជាវិធានជាក់លាក់ និងកាតព្វកិច្ចជាក់លាក់ ដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង ។ មេធាវីការពារក្តីមិនបានស្នើសុំដកចេញទេ ហើយដូចដែលបានលើកឡើងឯកសារនោះបានបញ្ចូលទៅក្នុងសំណុំរឿងតាំងពីការកកើតដំបូងរបស់តុលាការនេះ ។ ហើយបានយោងជាក់លាក់ក្នុងអំឡុងពេលស៊ើបអង្កេត មេធាវីការពារក្តីនៅពេលនោះបានលើកឡើងថា នៅពេលដែលមានការលើកឡើងដោយសហចៅក្រមស៊ើបអង្កេតបានលើកឡើថា មេធាវីបានលើកឡើងថា គាត់មានការព្រួយបារម្ភចំពោះចម្លើយមួយនោះ។ ប៉ុន្តែ មេធាវីការពារក្តី គឺគាត់មិនបានធ្វើការអនុវត្តឲ្យសមស្របចំពោះចម្លើយនោះ គឺការដាក់សំណើសុំឲ្យដកចម្លើយនោះចេញពីសំណុំរឿង ។ ឥឡូវនេះ ឯកសារនេះ នៅក្នុងសំណុំរឿង ហើយនៅចំពោះអង្គជំនុំជម្រះសាលាដំបូងដើម្បីពិចារណា ។

ជាថ្មីម្តងទៀត គឺខ្ញុំមានការភ្ញាក់ផ្អើលចំពោះការអះអាងរបស់មេធាវីការពារក្តី ចំពោះសិទ្ធិដែលកំណត់ចំពោះលោកហើយនិងភាគី ។ ជាពិសេសទាក់ព័ន្ធទៅនឹងឯកសារមួយនេះទាក់ទងនឹងសិទ្ធិរបស់ជនជាប់ចោទខ្លួនឯង ក្នុងការសម្រេចថា ឯកសារណាមួយដែលយើងអាច ឬក៏មិនអាចយកមកពិចារណា។ ប្រសិនបើឯកសារនោះនៅក្នុងសំណុំរឿង ហើយបើកឲ្យមានការពិចារណានិងការពិភាក្សាដេញដោល ដូច្នេះហើយ គឺវាមាននៅក្នុងវិធាន និងច្បាប់របស់យើងដែលមានចែងច្បាស់លាស់ ។ ខ្ញុំសូមលើកឡើងជាចំណុចចុងក្រោយ ប្រសិនបើឯកសារមួយនេះ គឺមានចែងនៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរថាជាចម្លើយរបស់ជនសង្ស័យដោយសារតែនៅពេលនោះ គឺយើងបានកំណត់អត្តសញ្ញាណចម្លើយផ្សេងៗដែលបានលើកឡើងដោយ កាំង ហ្គេកអ៊ាវ ហៅ ឌុច នៅពេលនោះ គាត់ជាជនសង្ស័យ ។ ដូច្នេះ យើងកំណត់ចម្លើយជនសង្ស័យដើម្បីធ្វើការបែងចែងពីចម្លើយសាក្សី ចម្លើយរបស់អ្នកជំនាញ ។ល។ និង ។ល។

ប្រសិនបើខ្ញុំយល់មិនខុសទេ លោក លោកស្រី នឹងមើលឃើញចម្លើយផ្សេងៗទៀត ដែលលើកឡើងដោយជនជាប់ចោទចំពោះអ្នកកាសែត ដែលយើងបានយោងនៅក្នុងដីកាបញ្ជូនរឿងស៊ើបសួរថា ជាចម្លើយរបស់ជនសង្ស័យ ។ ដូច្នេះ គឺកាលៈទេសៈនេះ គឺយើងមិនអាចថាវាមិនមែនជាចម្លើយដែលបានផ្តល់នៅពេលនោះទេ ដោយមន្ត្រីតុលាការ ។ ហើយមិនមែនថា វាធ្វើឡើងនៅក្នុងបរិបទនៃការចាប់ខ្លួន

ឬក៏ចម្លើយនោះមានការចោទប្រកាន់ណាមួយរបស់ភ្នាក់ងាររដ្ឋ ។ ប៉ុន្តែ ចម្លើយនោះ គឺជាចម្លើយដែលផ្ដល់ឡើងដោយសេរីភាពរបស់ជនជាប់ចោទផ្ដល់ជូនអ្នកតំណាងរបស់ឧត្ដមស្នងការសិទ្ធិមនុស្ស ឬក៏គេបានបំពេញក្នុងអាណត្តិរបស់គេ ដើម្បីប្រមូលឯកសារផ្សេងៗទាក់ទងទៅនឹងការរំលោភសិទ្ធិមនុស្ស ។

ជាការពិតណាស់មេធាវីការពារក្ដី គាត់អាចមើលឃើញហេតុផលច្បាប់ណាមួយដែលថា ឯក-សារនោះ ឬចម្លើយនោះ បន្ទាប់ពី២ឆ្នាំ គឺគាត់សុំឲ្យដកពីការពិចារណារបស់លោកចៅក្រម ។ ដូច្នេះខ្ញុំសូមអញ្ជើញថាឲ្យលោកចៅក្រម ខ្ញុំសូមបញ្ជាក់ជូនចៅក្រមថា ចម្លើយនេះគឺវាមានលក្ខណៈផ្លូវច្បាប់ ហើយសូមឲ្យធ្វើការពិចារណា ។

[០៩:៣៩:៣០]

**លោក ហ្រ្វង់ស្វ័រ រូៈ**

លោកប្រធាន សូមអភ័យទោស ហើយខ្ញុំនឹងឆ្លើយតបក្នុងពាក្យយ៉ាងខ្លី ហើយលោកព្រះរាជមិនបានយល់ពីអ្វី ដែលខ្ញុំបានលើកនោះទេ ។ ខ្ញុំមិនបាននិយាយថា ឯកសារនោះត្រូវតែដកចេញពីសំណុំរឿងទេ ។ ខ្ញុំគ្រាន់តែរំឭកឡើងវិញថា នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០០៨ យើងបានសម្ដែងនូវការរក្សាសិទ្ធិយ៉ាងច្បាស់លាស់ចំពោះសហចៅក្រមស៊ើបអង្កេត ។ លោកចៅក្រមនឹងបានឃើញហើយ នៅក្នុងទំព័រទី២ នូវការពិនិត្យរបស់សហចៅក្រមស៊ើបអង្កេត នៅក្នុងនៅខែមករា ឆ្នាំ២០០៨ នោះ ។

លោកសហព្រះរាជអាជ្ញាបានដឹងច្បាស់ថា ឯកសារនោះគឺដាក់ថា D៣៨ យើងបានសម្ដែងនូវការរក្សាសិទ្ធិ ។ យើងមិនបានបញ្ជាក់ថាគប្បីដកឯកសារនេះចេញនោះទេ ។ អ្វីដែលយើងខ្ញុំបញ្ជាក់ ខ្ញុំរក្សាជំហរហ្នឹង គឺថាឯកសារនេះគឺមិនអាចគាត់យកប្រើប្រឆាំងនឹងជនជាប់ចោទបានទេ ដោយផ្អែកទៅលើកាលៈទេសៈមួយចំនួនដែលកត់ត្រាយកឯកសារនោះហើយមានព័ត៌មាននោះ ។

ហើយខ្ញុំសូមបញ្ជាក់ថា វាមិនមែនជារឿងធម្មតាទេ ដែលថាតំណាងរបស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សទៅធ្វើសម្ភាសន៍ ហើយយកចម្លើយរបស់ជនណាម្នាក់ ហើយក្នុងចម្លើយនោះបានបញ្ជាក់ថា ជាជនសង្ស័យនោះ ។ វាខុសធម្មតា ។ ហើយគប្បីក្រោយមកក៏ត្រូវបានយកមកប្រើនៅក្នុងសំណុំរឿងរបស់សហព្រះរាជអាជ្ញា ។

ការិយាល័យរបស់អង្គការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ត្រូវតែគោរពសិទ្ធិមនុស្សជាលក្ខខណ្ឌអប្បបរមា ។ ហើយឯកសារនេះ ជាបញ្ហាមួយស្ថិតនៅក្នុងបរិបទនោះ ។ ជនជាប់ចោទអាចនឹងប្រើនៅផ្នែកមួយនៃឯកសារនេះ ដោយគាត់ចង់យកមកប្រើ ។ ដូច្នេះ ឯកសារនេះមិនអាចយកប្រើ

ដើម្បីប្រឆាំងជនជាប់ចោទបានទេ ពីព្រោះថាខ្លួនគាត់ពីខាងដើមនោះ គាត់មិនមានបានទទួលជម្រាបពីសិទ្ធិរបស់គាត់ ។ ដល់អ៊ីចឹងហើយ យើងបានលើកពីការរក្សាសិទ្ធិរបស់គាត់នៅពេលមុនហ្នឹង ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សំណួរមួយទៅមេធាវីការពារ ដើម្បីលើកឡើងបញ្ហាមួយទាក់ទងទៅនឹងឯកសារនេះ ។

តើមេធាវីចាត់ទុកថាអាចថាទៅរួចទេដែលអង្គជំនុំជម្រះសាលាដំបូងអាចយោងទៅរកឯកសារនោះ គឺជាមូលដ្ឋានមួយដើម្បីពិនិត្យមើលស្ថានភាពជនជាប់ចោទដែរឬក៏អត់ទេ? ថាតើមេធាវីយល់ថាថាតើឯកសារមួយនោះអាចនឹងមានលទ្ធភាពដែលខ្លួនមាន មានតែជនត្រូវចោទនោះទេ អាចលើកបានឬលើកមិនបាននោះ?

[០៩:៤២:៣៦]

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកចៅក្រម គឺជាចម្លើយដដែល ដែលយើងនឹងផ្តល់ជូនទៅសហចៅក្រមស៊ើបអង្កេត។ គឺជនជាប់ចោទបានសម្តែងការរក្សាសិទ្ធិដូចដែលខ្ញុំលើកឡើងដូច្នេះឯង ។ ហើយបានឯកភាព និង ឆ្លើយទៅនឹងសំណួរទៅចៅក្រមទាក់ទងទៅនឹងឯកសារនេះ ។ ដូច្នេះ ជនជាប់ចោទនឹងឯកភាពទៅនឹងអង្គជំនុំជម្រះ ដើម្បីនឹងសួរសំណួរទៅគាត់ ។ គាត់នឹងឆ្លើយ ។

ប៉ុន្តែ មេធាវីការពារមិនអាចឯកភាពថាព័ត៌មានទាំងអម្បាលមាណនៅក្នុងឯកសារនោះ នឹងអាចត្រូវយកមកប្រើប្រឆាំងនឹងជនជាប់ចោទបានទេ ពីព្រោះជនជាប់ចោទមិនត្រូវបានផ្តល់សិទ្ធិត្រឹមត្រូវទេ នៅក្នុងពេលគេសួរយកចម្លើយនោះ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកសហព្រះរាជអាជ្ញា ។

[០៩:៤៣:៣៣]

**លោក រ៉ូប៊ឺត ពើទីត៖**

លោកប្រធាន លោក លោកស្រីចៅក្រម ជាទីគោរព! ខ្ញុំសូមធ្វើការសន្និដ្ឋានថា លោក លោកស្រីចៅក្រមធ្វើការ ឯកសារ សិទ្ធិសម្រេចទៅលើឯកសារនេះ ចំពោះការដែលយើងលើកឡើងថាជាឯកសារដោះបន្ទុក ។ វាគួរតែមានការពិភាក្សាដេញដោល និងការចេញសេចក្តីសម្រេចដើម្បីធានាថាឯកសារនេះ ដែលយើងបានធ្វើការសន្និដ្ឋាន វាមានចម្លើយផ្សេងៗ ដែលវាមានប្រយោជន៍សម្រាប់លោក

លោកស្រីចៅក្រមក្នុងការចេញសេចក្តីសម្រេចចំពោះព័ត៌មានដាក់បន្ទុក និងដោះបន្ទុក ចំពោះឧក្រិដ្ឋកម្មដែលជនជាប់ចោទបានប្រព្រឹត្ត ។

ខ្ញុំខកខានមិនបានយល់ ថាតើចម្លើយជនជាប់ចោទនោះ គឺវាមានព័ត៌មានដែលវានាំទៅដល់ការស្វែងរកការពិតនិងលក្ខខណ្ឌផ្សេង ។ ហើយគឺខ្ញុំមិនបានយល់ថា ឯកសារនេះ គឺវាបំពេញលក្ខខណ្ឌនៃសេចក្តីសម្រេចរបស់ចៅក្រម ចំពោះចម្លើយដែលលើកឡើងរបស់ជនជាប់ចោទ ។ ប្រសិនបើយើងមិនពិចារណាទៅលើព័ត៌មានផ្សេងៗនេះ ព័ត៌មាននេះ គឺត្រូវយកមកធ្វើការដេញដោលនិងសម្រេច ។ ហើយចំពោះយើងខ្ញុំសូមលើកឡើងសាជាថ្មីថា ខ្លឹមសារនៃចម្លើយរបស់ជនជាប់ចោទនេះ រហូតមកដល់ពេលនេះទាល់តែវាដកចេញពីសំណុំទើបយើងអាចពិចារណាថា វាជាឯកសារសម្រាប់ដាក់បន្ទុក និងដោះបន្ទុក ។ ដូច្នេះ ខ្ញុំស្នើសុំអង្គជំនុំជម្រះសាលដំបូង សូមធ្វើការបំភ្លឺនៅពេលនេះ ឬក៏ពេលក្រោយទាក់ទងទៅនឹងចម្លើយមួយនេះ ។

ប្រសិនបើមានការពិភាក្សាដេញដោល ហើយយើងគួរតែរៀបចំ លោក លោកស្រីគួររៀបចំជាការដេញដោលជាលាយលក្ខណ៍អក្សរ និងផ្ទាល់មាត់ ។ សូមអរគុណ ។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៤៨:០៨]

**ប្រធានអង្គជំនុំ៖**

បន្ទាប់ពីបានស្តាប់នៅមតិយោបល់របស់មេធាវីការពារក្តី ហើយមានការឆ្លើយតបដោយសហព្រះរាជអាជ្ញាពាក់ព័ន្ធជាមួយនឹងឯកសារ ដែលបានសួរចម្លើយជនជាប់ចោទ ដោយតំណាងរបស់ *យូអ៊ិនអេចស៊ីអ* (UNHCR) កន្លងមក ។ បញ្ហានេះអង្គជំនុំជម្រះសូមជម្រាបជូនភាគីថា សូមឲ្យភាគីទាំងអស់អាចសរសេរជាលាយលក្ខណ៍អក្សរ ជាសេចក្តីសន្និដ្ឋាន នូវអ្វីដែលតាមការយល់ឃើញរៀងៗខ្លួនមកដើម្បីបញ្ជូនមកអង្គជំនុំជម្រះ ។ អង្គជំនុំជម្រះនឹងពិចារណាសម្រេចអំពីបញ្ហានេះ នៅពេលក្រោយ ។

ជាកិច្ចបន្ត ពាក់ជាមួយនឹងដំណើរការប្រព្រឹត្តនៃការសួរដេញដោលទៅលើអង្គហេតុម-១៣ ជាមួយនឹងជនជាប់ចោទ ។ ហើយជាថ្មីម្តងទៀត អង្គជំនុំជម្រះសូមជម្រាបសួរទៅលោក កាំង ហ្កេកអ៊ាវ ហៅ ឌុច ចូរលោកធ្វើការនិទានរៀបរាប់អំពីការបង្កើត និងប្រតិបត្តិការមន្ទីរសន្តិសុខម-១៣ ដែលមានទីតាំងស្ថិតនៅអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ រួមទាំងម-១៣(ខ) ផង ដែលលោកធ្លាប់ធ្វើការនៅទីនោះដែលនៅចាំ ។ តើលោកអាចនិទានរៀបរាប់ប្រាប់ដល់អង្គសវនាការនៅពេលនេះបានទេ? អំពីអ្វី

ដែលយើងបានលើកឡើងនេះ ។ សូមអញ្ជើញ ។

**ជនជាប់ចោទ៖**

សូមគោរពលោកប្រធាន ។ ខ្ញុំសូមថ្លែងអំណរគុណលោកប្រធាន ដែលអនុញ្ញាតឲ្យខ្ញុំនិយាយអំពីប្រវត្តិមន្ទីរ១៣ ក្នុងឋានៈដែលគេហៅថា *ហ្សីរីព្រីដង់* ។ ទន្ទឹមនឹងនេះ ខ្ញុំក៏សុំមានសូមណូមពរមួយមុននឹងចូលដល់ម-១៣ ខ្ញុំសូមអនុញ្ញាតលោកប្រធានជម្រាបអង្គជំនុំជម្រះនៅពេលនេះ អំពីប្រវត្តិខ្ញុំមុននោះតទៅទៀត ។ បើសិនជាលោកប្រធានអនុញ្ញាតខ្ញុំនឹងជម្រាបជូនយ៉ាងខ្លី ។

[០៩:៥០:២៧]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត, សូមអញ្ជើញ ។

**ជនជាប់ចោទ៖**

អង្គជំនុំជម្រះសាលាដំបូងជាទីគោរព! ខ្ញុំបាទចាប់អារម្មណ៍នឹងបញ្ហានយោបាយចាប់តាំងពីឆ្នាំ១៩៥៧ មកម្លេះ រហូតដល់ឆ្នាំ១៩៦៤ នៅក្នុងខែតុលា ទើបខ្ញុំបាទសម្រេចចិត្តធ្វើបដិវត្តន៍ ។ ខ្ញុំជឿថាសេចក្តីសម្រេចចិត្តនេះត្រឹមត្រូវហើយសម្រាប់ជីវិតរបស់ខ្ញុំ ។ ខ្ញុំបានលះបង់អ្វីៗទាំងអស់ដើម្បីបដិវត្តន៍យ៉ាងស្មោះស្ម័គ្រនិងយ៉ាងប្តូរផ្តាច់ ។ ក្នុងរបបនេះប្រាក់ខែដែលកាលនោះ ខ្ញុំបានទទួលប្រាំពាន់ពីររយប្អាយ ដែលខ្ញុំគម្រោងទុកពីលើកមុនៗនឹងខ្ញុំចេញធ្វើការ ។ ខ្ញុំថាដល់ពេលខ្ញុំចេញធ្វើខ្ញុំនឹងសន្សំទុកមួយខែពី៤០០០ទៅ៥០០០សម្រាប់អនាគតខ្ញុំ ។ ខ្ញុំប្រែប្រួល លះបង់ទាំងអស់ដើម្បីបដិវត្តន៍ ។ ទន្ទឹមនេះដែរមានហេតុភេទមួយចម្លែកដែលអ្នកស្រុកគេសង្កេតឃើញ ខ្ញុំដែលធ្លាប់តែចុះឡើងទៅជម្រាបសួរសុខទុក្ខម្តាយនៅឯស្មោង ខ្ញុំមិនដែលទៅទៀតទេ ។ ពីព្រោះអី? ពីព្រោះខ្ញុំដឹងថា ឪពុកម្តាយខ្ញុំក៏គាត់យល់ថាផ្លូវនេះជាផ្លូវល្អដែរ ក៏ប៉ុន្តែគាត់ក៏មិនចង់ឲ្យខ្ញុំធ្វើខ្លាចគុក ខ្លាចច្រវ៉ាក់ ខ្លាចស្លាប់ ។ ខ្ញុំលែងជាន់ផ្ទះនេះទី២ ដែលគេសង្កេតឃើញ ។

ទី៣) ដែលគេសង្កេតឃើញ កូនសិស្សជាពិសេសដែលខ្ញុំបង្រៀននៅស្គន់ ។ គេចាប់អារម្មណ៍នឹងសន្តានចិត្តខ្ញុំ ដែលខុសពីគេពីឯងនៅពេលនោះ ។ សូមជម្រាបលោកប្រធានដោយស្មោះថា ពេលនោះខ្ញុំសន្មតទុកសកម្មភាពរបស់ខ្ញុំថា ខ្ញុំរស់នៅក្នុងកូនសង្គមកុម្មុយនីស្ត នៅក្នុងកណ្តាលចំណោមសង្គមពាក់កណ្តាល អាណានិគមពាក់កណ្តាលសក្តិភូមិ ។ ខ្ញុំអត់ខ្លាចគ្រោះថ្នាក់ជីវិតស្លាប់បាត់បង់ គុកច្រវ៉ាក់ទៀតទេ ។ សូមបញ្ជាក់លោកប្រធានថា កិច្ចដំណើរការរបស់ខ្ញុំបណ្តើរៗដែលខំប្តូរផ្តាច់នឹងបដិវត្តន៍នេះ

ធ្វើឲ្យលោកគ្រូមេកុដិដែលខ្ញុំគោរព ហើយលោកដែលស្រឡាញ់ខ្ញុំណាស់ដែរនោះ លោកដឹង ។ លោករកវ៉ៃខ្ញុំ ខ្ញុំដឹងថា គ្រូខ្ញុំស្រឡាញ់ខ្ញុំ មិនសម្លាប់ខ្ញុំទេ ខ្ញុំសុខចិត្តជានិច្ច ។ ទូលពិតគ្រូខ្ញុំដោយត្រង់ លោកក៏អនុគ្រោះ ហើយទន្ទឹមនេះលោកក៏បានឲ្យពាក្យទូន្មានខ្លះ ដែលថា "អ៊ឺ! អ្អែងដើរនេះវាត្រូវហើយ អញស្មានថាអ្អែងចូលជើងចូលដៃជាមួយពួកអាចារ្យនាងខាងខ្មែរសេរីតើ? ខ្មែរសេរីមិនបានទេ គេយកសាច់អ្អែងទៅរងកាណុងជំនួសគេ" ។ ខ្ញុំក៏អរបានគ្រូលើកទឹកចិត្តអ៊ីចឹង ខ្ញុំធ្វើតទៅទៀត ។

[០៩:៥៣:៣៧]

នៅថ្ងៃ២៩ ខែតុលា ពេលដែលខ្ញុំ-- សុំទោស! ខ្ញុំសូមនិយាយតទៅទៀត អំពីជំហរលះបង់របស់ខ្ញុំ ។ ខ្ញុំលះបង់មួយខែ៥៥០០ ខ្ញុំទុកតែ១៥០០ ទេ សម្រាប់រស់នៅខ្លួនឯង ក្រៅពីនេះទុកបដិវត្តន៍ទាំងអស់ ។ ដល់វ៉ាកង ពេលវិស្សមកាលឆ្នាំ១៩៦៧ ខ្ញុំលមើលជីវិតកម្មករពិបាកយ៉ាងម៉េច? ខ្ញុំដោះខោអាវគ្រូបង្រៀនខោអាវត្រឹមត្រូវទៅស្លៀកពាក់ខោអាវកម្មករទៅធ្វើគូលីអាទិត្យ ។ ក្នុងមួយថ្ងៃ ខ្ញុំបាន២០រៀល ខ្ញុំធ្វើការមួយអាទិត្យម្ភៃថ្ងៃ(ស៊ុក) ។ នៅខែ៧, ខែ៦-៧ ១៩៦៧ ហ្នឹងឯង ខ្ញុំបានរៀនសូត្រវគ្គសម្ងាត់របស់បក្សកុម្មុយនីស្តកម្ពុជា អ្នកដឹកនាំរៀនហ្នឹង គឺ ឆាយ គឹមហ៊ុរ ។ ឯកសារដែលខ្ញុំមានកាលនោះមានច្រើន ។ ទី១ គឺឯកសារមាគ៌ាជាយុត្តិសាស្ត្រនៃការតស៊ូបដិវត្តន៍នៅកម្ពុជា ឯកសារនេះបាត់ទៅហើយ ។ ឯកសារទី២ គឺឯកសារគោលនយោបាយជាយុទ្ធវិធីនៃការប្រមូលកម្លាំងរណសិរ្សធំទូលាយសម្រាប់បដិវត្តន៍ប្រជាជនប្រជាធិបតេយ្យ ឯកសារនេះក៏មិនឃើញមានទៀតទេ ។ ឯកសារទី៣ គឺលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា លក្ខន្តិកៈឆ្នាំ១៩៦០ ។ ឯកសារទី៤ គឺមោទនភាពត្រូវនិងខុស ។ ឯកសារទី៥ គឺសតិអារម្មណ៍អង្គការវិន័យ ។

នៅខែតុលា ឆ្នាំ១៩៦៧ ដែរ វន វ៉េតគាត់ហៅខ្ញុំទៅជួបធ្វើការ ពេលហ្នឹងហើយ ជាពេលដំបូង

ដែលខ្ញុំជួប វន វ៉េត ខ្ញុំអរណាស់ ។ គេឲ្យខ្ញុំចូលបក្ស តែពិធីបញ្ចូលបក្សត្រូវតែធ្វើនៅចំការលើ ហើយគេឲ្យខ្ញុំទៅជនបទ ខ្ញុំទៅលាឪពុកម្តាយខ្ញុំ ។ ខ្ញុំសូមនិយាយឲ្យល្អិតបន្តិចចុះ ឪពុកខ្ញុំមានការតក់ស្លុតដែរ គាត់ឲ្យខ្សែកថាមកខ្ញុំ ខ្ញុំតាមពិតខ្ញុំមិនជឿប៉ុន្មានទេ ។ ប៉ុន្តែ ខ្ញុំត្រូវតែយក ផ្គាប់គុណឪពុក ។ ខ្ញុំលាពួកម៉ាកខ្ញុំៗដោះនាឡិកាដូរនឹងខ្ញុំ *ទីតានី* ដូចគ្នា ។ ប៉ុន្តែអានាឡិកាគេនោះ វាមានចារកថាពីក្រោម ។ ខ្ញុំសុខចិត្តដូរ ខ្ញុំមកលាមិត្តភក្តិខ្ញុំនៅកំពង់ធំ ។ ខ្ញុំមកថ្វាយបង្គំលាព្រះសង្ឃកុដិលេខ៣ គ្រូខ្ញុំ តែលោកទៅទេសន៍បាត់ ។ ខ្ញុំបានលាមិត្តភក្តិនៅនោះ ។ ខ្ញុំចេញដំណើរទៅៗពិធីបុណ្យបញ្ចូលបក្ស ខ្ញុំបក្ខជនត្រៀម

នៅថ្ងៃ២៥ ធ្នូ ១៩៦៧ ។ អ្នកទទួលស្គាល់ខ្ញុំ ជាតិប្រជាជនស្គាល់ហើយ សាកលលោកក៏ស្គាល់ដែរ គឺ កែ ពក ។ បងពក នេះជាអ្នកទទួលស្គាល់ខ្ញុំ ។

ពេលនោះខ្ញុំឈរនៅមុខទង់បក្ស លើកដៃដាក់គោរពអ៊ីចេះ ហើយសច្ចាថា នឹងស្មោះត្រង់នឹងបក្ស វណ្ណៈនិងប្រជាជនកម្ពុជាអស់មួយជីវិត និងបម្រើបក្ស វណ្ណៈប្រជាជនកម្ពុជាអស់មួយជីវិត ដោយមិនខ្លាចធ្វើពលីកម្មអ្វី ។ នេះជាគោលការណ៍នៃការចូលបក្សជំនាន់នុំង ។ ខ្ញុំចូលបក្សនៅថ្ងៃ២៥ ធ្នូ ខ្ញុំត្រូវគេចាប់នៅថ្ងៃ៥ មករា ឆ្នាំ១៩៦៨ ។ ពេលចាប់នោះទៀតខ្ញុំអត់តក់ស្លុតទេ ធ្វើម៉េចជីវិតយើងៗសម្រេចចិត្តអ៊ីចឹងហើយ យើងទទួល ។

[០៩:៥៧:០៥]

ថ្ងៃ០៣ ខែមេសា ១៩៧០ លន់ នល់ គាត់ដោះលែងខ្ញុំនៅមុខរដ្ឋសភា ។ ខ្ញុំទៅផ្ទះបានបីអាទិត្យខ្ញុំត្រឡប់មកវិញធ្វើសកម្មភាពប្រមូលកម្លាំងដែលចេញពីគុក ដើម្បីចាំទទួលភារកិច្ចបដិវត្តន៍ ។ នៅពេលហ្នឹងហើយ ដែលមានគេប្រាប់ថា ប្រយ័ត្នខ្លួនឲ្យមែនទែន ខាង តាណុន គឺ លន់ ណុន គេមានគិញ្ចសម្ងាត់របស់គេ អង្គរក្សសម្ងាត់របស់គេសម្រាប់លួចចាប់កម្មេចសម្ងាត់មនុស្ស ។ ខ្ញុំក៏ចេះតែប្រយ័ត្នដែរហើយទន្ទឹមនឹងនេះខ្ញុំវាយការណ៍ ការវិភាគយើងប្រយ័ត្ន ក៏ប៉ុន្តែច្បាស់លាស់ ប៉ុនគេមិនទាន់ឲ្យថាច្បាស់លាស់ទេ ។ មនុស្សដែលចេញពីគុកប៉ុន្មាន ឃើញបាត់តែម្នាក់ទេ រកមិនឃើញ មិនដឹងបាត់ដានទៅណាប៉ុន្តែ យើងខ្ញុំមិនចង់សន្និដ្ឋានថា មនុស្សនោះត្រង់ខាងកូនចៅតាណុន ចាប់ទេ អត់ទេ ពីព្រោះគ្នាជាស្រី ។ ដូច្នេះថ្ងៃ-- សូមទោស ខែសីហា ១៩៧០-- ១៩៦៨-- ១៩៧០ ខែសីហា ១៩៧០ ខ្ញុំទៅជនបទជាលើកទី២ ដើម្បីធ្វើសកម្មភាព នៅពេលនឹងហើយដែលយើងខ្ញុំឃើញទំនាស់ស្នូគស្មាញ ។

លើកមុនខ្ញុំឃើញទំនាស់រវាងបដិវត្តន៍នឹងចក្រពត្តិ គឺនឹង តានល់ តែម្តង ។ ឥឡូវនេះខ្ញុំឃើញទំនាស់ស្មុគស្មាញ បក្សពលករវៀតណាមខេត្តអាងយ៉ាង មកចាត់តាំងរដ្ឋអំណាចនៅកម្ពុជា ។ គេបាញ់សម្លាប់ខ្មែរអ្នកទារពន្ធម្នាក់ឈ្មោះ ពិន ឯម នៅលើទន្លេបាសាក់ ត្រង់ម្តុំឃុំព្រែកស្តី ។ គេបាញ់សម្លាប់បក្ខជនបក្សពលកររបស់គេទេ ប៉ុន្តែកំណើតជាខ្មែរក្រោម ឈ្មោះ ចៅកែម នៅវត្តពោធិបាន ។ ខ្ញុំគិតថាជារឿងទំនាស់ធម្មតា ។ ក៏ប៉ុន្តែឥឡូវនេះខ្ញុំគិតថា វាជាការអនុវត្តផែនការសហព័ន្ធឥណ្ឌូចិនរបស់លី យន់ហាក់ ។ ទន្ទឹមនេះ ក៏វាមានទំនាស់នៅក្នុងបក្សកុម្មុយនីស្តកម្ពុជាដែរ គឺកាប់គ្នាដើម្បីអំណាច សុខ ប៊ុតចំរើន ឈ្មោះដើម ស៊ីសុវត្ថិ ប៊ុតមុន្នី ជាអនុលេខាគណៈកម្មាធិកាតំបន់២៥ ។ បក្ខជនម្នាក់ឈ្មោះដើម

ហ៊្វូន គៀត ហើយនឹងចាប់បក្សជនបីនាក់ដាក់គុក ។ លេខា សុខបុតចំរើន ដាក់ឃុំក្នុងផ្ទះនៅសីលា ។ ខ្ញុំហើយនឹងមិត្ត ប៉ុន គេទុកនៅក្នុងអង្គភាពយោធាសម្រាប់បម្រើបង្រៀនសីលធម៌តទៅទៀត ។

ទម្រាំដល់ខែប្រាំ ដែលខ្ញុំធ្វើការទាក់ទងបានល្អ ជាមួយនឹងប្រធានសេនាធិការតំបន់២៥ ទើបខ្ញុំរត់មកនៅនិរតី ។ ដល់មកនៅនិរតីនេះហើយ ដែលគេឲ្យខ្ញុំទៅរៀន ហើយដល់ថ្ងៃ២០ កក្កដា នេះហើយ ដែលគេឲ្យខ្ញុំធ្វើប្រធានមន្ទីរ១៣ នេះប្រវត្តិដើម ដែលខ្ញុំយល់ដឹងអំពីបដិវត្តន៍ ហើយនិងបានឧទ្ទិសខ្លួនខ្ញុំចំពោះបដិវត្តន៍ ។

នៅពេលដែលគេប្រគល់ភារកិច្ចឲ្យខ្ញុំធ្វើប្រធានមន្ទីរ១៣ ខ្ញុំអង្វរកថា អូយ! ខ្ញុំខ្លាចណាស់ អាប្រធានមន្ទីរនគរបាលនេះ វាត្រូវតែគោរពមេ ។ បើមេធំបងចំរើន ឈ្មោះដើម ស៊ីសុវត្ថិ ប៊ុតមុន្នីអនុលេខាតំបន់២៥ ធ្វើបែបនេះថ្ងៃណាមួយគង់គ្រោះថ្នាក់ទេ តែគេចាប់មេហើយ អានគរបាលទៅណាគ្នា ត្រូវតែគេចាប់ដែរ ។ ឮខ្ញុំនិយាយអញ្ចឹង ឆាយ គឹមហ៊ា គាត់ថា មិត្តមានមតិហ្នឹងត្រូវហើយ អ្នកដែលគេចាប់ជាអ្នកទទួលខុសត្រូវចំពោះមុខប្រវត្តិសាស្ត្រ មិត្តកុំទាមទារចាប់អ្នកណាឲ្យសោះ សូម្បីសេចក្តីរាយការណ៍របស់មិត្ត ក៏ត្រូវតែត្រង់កុំឲ្យគេថាយើងលម្អៀង កុំឲ្យគេថាយើងមានបំណងចាប់អ្នកនេះ ចាប់អ្នកនោះ ។

ដូច្នេះ អ្នកដែលគេសម្រេចចាប់មនុស្សប្រគល់មកឲ្យមិត្ត គឺជាសមាជិកមជ្ឈិមបក្ស ដូចយ៉ាងតាម៉ុក ឈ្មោះដើម អ៊ុង ជឿន ដូចយ៉ាង បង ស៊ី ឈ្មោះដើម ជូ ជេត ដូចយ៉ាង បង ប៉ាល់ ឈ្មោះដើម លោកតា ហ្លួត ហេង ដូចយ៉ាង បង វន តុលាការលោកស្គាល់ហើយ វន វ៉េតសុទ្ធតែជាសមាជិកមជ្ឈិម ដូច្នេះ គេមិនធ្វើផ្តេសផ្តាសទេ គេទទួលខុសត្រូវចំពោះមុខប្រវត្តិសាស្ត្រ មិត្តកុំភ័យ ខំតែធ្វើការងារទៅ ។ គាត់និយាយមួយម៉ាត់ទៀតគាត់ថា ជាតិប្រជាជនត្រូវការកុលបុត្ររបស់ខ្លួនឲ្យបំពេញការងារនេះ ដើម្បីការពារតំបន់រំដោះ ដើម្បីការពារអាយុជីវិតជាតិប្រជាជន ។ ខ្ញុំថា ខ្ញុំអត់ដែលចេះសួរទេ អង្វរ ប្រកែកគេអ៊ីចឹង អង្វរកគេហើយ ថាមិនដែលចេះសួរទេ ខ្ញុំមិនដែលធ្វើនគរបាលពីមុនមកទេ ខ្ញុំចង់តែបង្រៀនទេ ។ ដោយថាឥឡូវយើងត្រូវពឹងអ្នកណា ការបង្រៀនខាងនគរបាល គ្មានអ្នកណាគេបង្រៀនយើងទេ វាប៉ះពាល់ដល់ការសម្ងាត់ប្រទេសជាតិគេ មិត្តធ្វើទៅដើម្បីមានពិសោធន៍ ។ ជាតិប្រជាជនត្រូវការមិត្តហើយ មិត្តធ្វើទៅ ។ មិត្ត គាត់ៗនិយាយមួយម៉ាតទៀតថា ខ្ញុំសោកស្តាយណាស់ បង ហុក, ឆាយ គឹមហ៊ា នេះ គាត់ថា ខ្ញុំសោកស្តាយណាស់ដោយមិត្តឯង និយាយមកចំពោះខ្ញុំ មិនបានអានសៀវភៅមួយគេថា *អ៊ិចស្តៀរិយ៉ង់ ហ៊ិសស្ទូរិក ដឺឡាឌុចតាទ័រ ដឺប្រូលិតារិយ៉ា* ។ ខ្ញុំថា ហ៊ឺ បងឆ្លើយ ប្រហែលជា

យើងមិនអាចធ្វើបានតាមខ្សែភាពយន្ត ដែលយើងមើលជាមួយគ្នានៅកុនភ្នំពេញទេ ពីរឿនតាមដានហ្នឹង ។ គាត់ថា ឥឡូវខំទៅយើងធ្វើពីអត់ទៅមាន មិត្តកុំភ្លេចថា យើងរំដោះជាតិ មិនមែនរំដោះយកអត់មនុស្សទេ គឺយើងរំដោះយកមនុស្ស យើងរំដោះយកមនុស្សជាសំខាន់ មានមនុស្ស គឺមានអ្វីៗទាំងអស់ ។ ខ្ញុំប្រកែកនឹងគេមិនឈ្នះគេ លើកមួយម៉ាត់ទៀតថា ខ្ញុំអត់ប៉ានសម្លាប់មនុស្សទេ ខ្ញុំអត់ប៉ានសម្លាប់មនុស្សទេ ។ គាត់ថារឿងនេះ យើងជាបញ្ញាជន យើងតឹងតែបន្តិចមែន ក៏ប៉ុន្តែយើងរៀនសូត្រពីកសិករ ទុកឲ្យកសិករគេធ្វើទៅ ។ យើងរៀនសូត្រពីគេ យើងមានតែប្រាប់គេតែប៉ុណ្ណឹងទៅបានហើយ ។

[១០:០៣:៣៤]

ខ្ញុំក៏សុខចិត្តទទួលៗ សរុបមករឿងមន្ទីរ១៣នេះ វាវិវត្តន៍ទៅអ៊ីចឹង ។ នៅពេលដែលទទួលបានមុនដំបូងមនុស្សម្នាក់ដែលគេចាប់យកមកនោះ ឈ្មោះ ប៉ាង ដូចជា កៅ ប៉ាង ឬក៏ កៅ ប៊ុនប៉ាង ខ្ញុំភ្លេចហើយ ខ្ញុំសួរអង្វរក សួរមិនចេញ កំពុងតែសួរៗ អង្កាល់ហ្នឹង ខ្ញុំសួរនៅឃុំថ្នកុប នៅផ្ទះអមផ្លូវហ្នឹង ស្រាប់តែកម្មាភិបាលហាណូយពីណា ពីរនាក់ គេមកដោះស្រាយអ្នេ អត់មាននរណាចាត់តាំងទេ គេមានកាំភ្លើងខ្លីផង គេចូលទៅវ៉ៃភួសផស កៅ ប៉ាង នោះឆ្លើយថា ខ្ញុំគិញមែន គេចាត់តាំងឲ្យមក ។ ខ្ញុំនៅតែនឹកឃើញការពិតនៅឯណា ? ដល់ពេលហ្នឹងហើយ ដែលខ្ញុំចាប់ផ្តើមពិចារណាពីរឿង ពិតមិនពិតពីពេលហ្នឹងហើយដែលខ្ញុំឃើញថា អ្នឹ មនុស្សណាដែលដោះស្រាយមិនរួច ឲ្យលែងមិនរួចទេ ខ្ញុំឲ្យមិត្តប៉ុន គេទៅសួរហើយឲ្យគេវាយអីខ្លះទៅ ខ្ញុំណែនាំ ខ្ញុំអនុញ្ញាតមែនឲ្យវ៉ៃឲ្យអីមែនពិត ។

ឯចំណែកមនុស្សណាដែលខ្ញុំចង់ដោះលែង មើលទៅឃើញឲ្យដោះលែងកើត ខ្ញុំសួរផ្ទាល់ខ្លួនឯងហើយ ។ ខ្ញុំដោះលែងបានបណ្តើរៗខ្លះមក ប៉ុន្តែនៅទីនោះ ដូចក្នុងសៀវភៅ *"ឡឺ ព័រតែល"* របស់*ប៊ីហ្សូ* គាត់សរសេរអ៊ីចឹង ងងឹត, សើម មនុស្សស្លាប់ ដោយសារខ្វះពន្លឺ ដោយសារខ្វះបាយ ខ្វះអនាម័យ ខ្វះថ្នាំសង្កូវច្រើន ។ ខ្ញុំក៏ផ្លាស់កន្លែងទៅពីឃុំថ្នកុប ពីអន្លង់វែងនេះ ទៅភូមិមួយក្បែរជើងភ្នំពីស ឈ្មោះទួលស្វាយមាស ឬក៏គេហៅថា អាតាលារ ទៅធ្វើស្រែ ។ នៅពេលដែលធ្វើស្រែហ្នឹងហើយ ដែលមានគេវ៉ៃដណ្តើមកាំភ្លើងរត់រួចអស់ទៅ ។ ដល់ចិត្តខ្ញុំមិនចង់ធ្វើនគរបាលស្រាប់ ខ្ញុំអង្វរកបង វន, វន វេតថាឲ្យគាត់ដាក់ទោសឲ្យខ្ញុំមក ។ ខ្ញុំទទួលបង ។ សុំបងមេត្តាអនុវត្តវិន័យមកលើខ្ញុំចុះ វន វេតគាត់មើលមុខខ្ញុំគាត់មើល ហើយគាត់ងាកមុខចេញធ្វើភ្នែកព្រិចៗ ឆ្លើយម៉េចមិនឆ្លើយរហូតអត់ឆ្លើយ យូរៗគាត់បញ្ជូនមនុស្សទៅឲ្យសួរទៀតហើយ ។ ខ្ញុំថា អូ! ជាតិនេះខ្ញុំគេចមិនរួច អំពីអាការងារដែលខ្ញុំមិនចង់ធ្វើនោះទេម្ល៉េះហើយដើម្បីលួងចិត្ត ខ្ញុំសូត្រកំណាព្យ *"ឡាម៉ែរ ឌុយ លូ"* សូត្រទាំងខុសសូត្រទាំងត្រូវ ចេះតែទៅ

ហើយ ។ ប៉ុនអាត្រូវមែនទែន គេនិយាយអ៊ីចេះ គេថា *"ព័្ពវ៉ េ ហ្សេមៀរ ព្រីយ៉េ អាហ្គីឡាម៉ុងឡាស ហ្វេអេមីអេឡូតាស អេដង់ឡាវ័រ អឺ អូឡឺស័រ តាវូលុយតាពើលេ ស៊ូហៀរ អេម័រ សាំងតាកូលេ កំម័រ"* ។ ខ្ញុំទន្ទេញអង្គាល់នោះមិនបានអ៊ីចឹងទេ ឥឡូវខ្ញុំមើលឃើញឡើងវិញ ។ ដូច្នេះ ដើម្បីដោះស្រាយបញ្ហាខ្លួនឯងគឺអ៊ីចឹង ។ ទន្ទឹមពេលនេះហើយ វាមានរឿងមួយទៀតធ្វើឲ្យខ្ញុំនិង តាម៉ុក ទាស់គ្នារហូត ។ រឿងនោះខ្ញុំខំយកចិត្តគាត់ណាស់ គាត់បញ្ជូន សង្ហា ហឿន ដែលជាមហាជនម្នាក់របស់គាត់ យកមកឲ្យខ្ញុំសួរ សង្ហា ហឿន ហ្នឹងជាអ្នកអាយ៉ៃ ជាមហាជនដែលគាត់ស្រលាញ់ គាត់ស្រលាញ់ សង្ហា ហឿន ស្មើគ្នានឹងស្រលាញ់ សំបិត ដែរ ។ សំបិត តួឯកល្ខោន, សង្ហា ហឿន មេអាយ៉ៃ គាត់ស្រលាញ់ពីរនាក់ហ្នឹងខ្លាំងណាស់ ។

[១០:០៧:២៣]

ខ្ញុំដឹងថាគាត់នៅចម្ការក្រូច ស្ទុះទៅសុំយោបល់គាត់ គាត់ថា កុំវ៉ៃ ខ្ញុំថា បាទខ្ញុំអត់វ៉ៃទេ ។ គាត់សរសេរសំបុត្រមួយមក សង្ហា ហឿន ខ្ញុំរត់យកសំបុត្រនោះមកឲ្យ បងហឿន វិញ ។ ខ្ញុំអត់ប៉ាន់វ៉ៃ អ្ហឺ ខ្ញុំបាន តាម៉ុក ពេញចិត្តម្តង ។ រួចពេលហ្នឹងគាត់បានណែនាំទៀតថា មិត្តឌុច ណ៎ា ប្រយ័ត្នឲ្យមែនទែនសម័យតស៊ូអារុធពីលើកមុន យូរៗយើងមិនដាច់ខាតជាមួយនឹងគិញយើងបាត់ដីម្តុំ យូរៗយើងបាត់ដីម្តុំគាត់ឆ្លៀតណែនាំខ្ញុំអ៊ីចឹងទៅទៀត ។ ក៏ប៉ុន្តែ សង្ហា ហឿន គាត់មិនឲ្យវ៉ៃ ។ ខ្ញុំក៏ទុក បងហឿន ហ្នឹងចេញទៅ ។ ធម្មតាទេ តែខាងលើសម្រេចចាប់ហើយ គ្មាននរណាប៉ានដោះលែងទេ បងហឿន ខ្ញុំទុកហ្នឹងរហូតទាល់តែលក្ខខណ្ឌជីវភាពសម្ភារៈវាធ្វើឲ្យគាត់ស្លាប់ទៅ ។

ទន្ទឹមនេះ មានរឿងទំនាស់ ។ ទន្ទឹមនឹងការត្រូវគ្នានឹងគាត់ វាមានរឿងទំនាស់នឹងគាត់ ។ ថ្ងៃមួយគាត់ឲ្យគេចាប់កម្មាភិបាលហាណូយម្នាក់ ឋានៈអនុលេខាវរសេនាតូច មកឲ្យខ្ញុំ ខ្ញុំស្ទុះទៅរកគាត់នៅមន្ទីរយោធា ។ គាត់ឮថាខ្ញុំទៅ គាត់ស្ទុះមកដែរ គាត់ថាមក ឌុចៗ សួរវាឲ្យឆាប់ មិត្តសំពងបំបែកក្បាលទៅបើវាមិនឆ្លើយ អាណាៗប្រើឲ្យវាធ្វើ ។ មិត្តកុំភ្លេចណាក្រដាសដែលគេផ្ញើមកនោះក្រដាសរើកៗៗៗជាក្រដាសហែកពីសៀវភៅតែមួយជាមួយ ចុង ជាមួយ មិត្តចុង ។ ខ្ញុំថា អ៊ូ! អន្តរធានហើយ ឥឡូវមិត្តតោះៗទៅជួបមិត្ត យ៉ាន មិត្តយានហ្នឹងលេខាកងវរសេនាតូចហ្នឹង ។ ឲ្យ មិត្តយ៉ាន បង្ហាញអង្រឹងបង្ហាញអី ខ្ញុំយកអង្រឹង យកមុង របស់ មិត្តយ៉ាន យកមកមើល*ត្រាហ្វេ* គ្រាប់ ។ ខ្ញុំវិភាគតាម*ត្រាហ្វេ*គ្រាប់ខ្ញុំថា អ៊ូ! មែន មែនរឿងនែ៎ ពត និងមិត្តយ៉ាន ទេ កម្មាភិបាលហាណូយនោះ ឈ្មោះ ប្រាជ្ញ សុនហៅ ពត មិនមែនៗ ពត បាញ់មិត្តយ៉ាន ទេ គឺមិត្តយ៉ាន បាញ់ខ្លួនឯង ។ ខ្ញុំអត់ប៉ានតវ៉ាជាមួយតាម៉ុកទេ

គេចប្រូចមកផ្ទះ វត់មករាយការណ៍ជូន បងវន ។ បងវន មិនសុខមិនសាប់ទៅរាយការណ៍ជូនមជ្ឈិម ។ ពេលហ្នឹងហើយ តាម៉ុក គាត់ថាអញលែងប្រើ អាឌុច មួយជាតិអញ អញអត់ចេះប្រើទេ អាឌុច ។ ហ្នឹងបានជាចេញពាក្យមួយពីខាងមជ្ឈិមមកគេថា កុំបច្ចេកទេស ត្រូវនយោបាយ ។ មិត្តកុំឈរលើបច្ចេទេសដើម្បីវិភាគខ្មាំង ត្រូវឈរលើនយោបាយ ។ ទន្ទឹមគ្នា ពេលនុ៎ង វាមានរឿងនៅអមលាំង មានមនុស្សម្នាក់ឈ្មោះ ប៉ិត គាត់រត់ពង្រត់ប្រពន្ធគេទៅ គាត់ហ្នឹងមានប្រពន្ធមានកូន កូនក្រមុំទៅហើយ ទៅពង្រត់ប្រពន្ធគេយកទៅអ៊ីឧដុង្គ ទៅជួបសារី សយ ទៅជួប ហង់ យីវ ។ ទាហានស័ក្តិប្រាំ ហើយនិងស័ក្តិបួនកន្លះរបស់ លន់ នល់ ។ មិនបានប៉ុន្មានថ្ងៃគាត់ត្រឡប់មកវិញ ដល់គាត់ត្រឡប់មកវិញ បងស៊ីគាត់ចាប់ ប៉ិត ហ្នឹងយកទៅឲ្យខ្ញុំ ។ ខ្ញុំសួរចម្លើយ ។ ដល់សួរចម្លើយចុះឡើងៗ វ៉ៃពេលហ្នឹង ឲ្យមិត្តប៉ុនវាយ ស្រាប់តែផ្កាយអារឿង កាំភ្លើង ទៅនេះទៅយកកាំភ្លើងយកមកលាក់នៅក្នុងដីរំដោះ ដើម្បីបះបោរពីក្នុងដីរំដោះទៅវិញ ។ តាម៉ុក គាត់ថារកឲ្យឆាប់ ឃើញអញបំពាក់មួយវរសេនាតូច កាំភ្លើងហ្នឹងបានវរសេនាតូច ។ ខ្ញុំក៏ខំរកតាមបញ្ហាហើយ ជូ ជេត ហៅ ស៊ី នោះគាត់ខំជួយណែនាំខ្ញុំបណ្តើរៗ គិតទៅពេលហ្នឹង ខ្ញុំចាប់អ្នកអមលាំង ដែលជាមូលដ្ឋានបង្អែកបដិវត្តន៍ប្រហែលជាជិតហាសិបនាក់ ។ ឈ្មោះខ្ញុំដែលខ្ញុំរំឭកឃើញបណ្តើរៗប្រហែលជាម្ភៃប្លាយនាក់ ។ ខ្ញុំតក់ស្លុតនឹងការចាប់អាយុជីវិតមនុស្សដែលឃើញមុខគ្នារាល់ថ្ងៃច្រើនដែរ ។

ដល់ចុងបញ្ចប់ ដើម្បីមានពិសោធន៍ខ្លួនឯងផ្ទាល់ ខ្ញុំសួរចម្លើយមនុស្សម្នាក់ឈ្មោះ ង៉ែត សំប៊ុន ហៅ រំពេ ផ្ទាល់ខ្លួនប្រហែលជាមួយខែ បានខ្ញុំសួរចប់ ដើម្បីមានពិសោធន៍គិតតាមទ្រឹស្តីសព្វគ្រប់ ។ ដូច្នេះ រឿងវ៉ៃ រឿងអី រឿងសួរចម្លើយអី គឺពិតជាខ្ញុំខំពុះពារពិតប្រាកដមែន ។

[១០:១១:២៨]

សរុបមក រឿងដែលខ្ញុំបានធ្វើនៅម-១៣ ខ្ញុំចាំមិនភ្លេចទេ ។ ខ្ញុំបានតាំងចិត្តថា នឹងសរសេរជាអត្ថបទមួយឲ្យអស់អំពីឧក្រិដ្ឋកម្មរបស់ខ្ញុំទៅលើជាតិប្រជាជនខ្ញុំនៅពេលនោះ ឲ្យច្បាស់ ហើយនិងរំឭកឈ្មោះអ្នកប៉ុន្មានដែលនៅអមលាំងនោះឡើងឲ្យអស់ ។ រូបភាពត្រង់ណាដែលខ្ញុំឃោរឃៅយ៉ាងម៉េច ខ្ញុំក៏នឹងសរសេរឲ្យអស់ ខ្ញុំត្រៀមរួចអស់ហើយ ប្រហែលជាសរសេរ ប្រហែលជាពីដប់ប្រាំទៅម្ភៃ *ប៉ាវ៉ាក្រាស* ឬក៏ហៅថា *ផាវ៉ាក្រាស* ខ្ញុំហៅ*សាប់ចេច* មិនត្រូវទេ ដូចតូចពេក ត្រៀមសរសេរដើម្បីឲ្យស្គាល់ឧក្រិដ្ឋកម្មរបស់ខ្លួន ដែលខ្លួនបានបានធ្វើទៅលើជាតិប្រជាជនរបស់ខ្លួន ក្នុងឯង ។

សូមបញ្ជាក់ថា តាំងពីពេលនោះមក ឆាយ គឹមហ៊ី របស់ខ្ញុំនេះមិនដែលប៉ាននិយាយថា យើងធ្វើ

បដិវត្តន៍ យើងនឹងរំដោះយកមនុស្ស មិនរំដោះយកដីទៀតទេ ខ្ញុំអត់ដែលឮបង គឹមហ៊ៃ និយាយអ៊ីចឹងទៀតទេ លែងមាត់លែងក ។ ឯចំណោក ជូ ជេត វិញ ថា អូ៎! មិត្តយើងធ្វើនេះត្រូវហើយ គឺយើងកម្ទេចតែវណ្ណៈសក្តិភូមិ ហើយនិងនាយទុនទេ ។ សក្តិភូមិ សំដៅអី សំដៅពួកអាវ៉ាសែបន្តិចបន្តួច ហើយនិងមេឃុំចាស់ ។ ចុះនាយទុនសំដៅអី សំដៅគ្នាអ្នកលក់ដូរបន្តិចបន្តួចកាលពីជំនាន់នុ៎ង ខ្ញុំថា ឱ! អន្តរធានហើយ ។ រឿងនេះហើយ ដែលខ្ញុំចង់គេចពីមន្ទីរនគរបាល ហើយសុំបង ចេង អន ទៅនៅខាងឧស្សាហកម្មជាមួយនឹងគេ តែមិនបានទៅ ។

ដូច្នេះ សរុបមកខាងនៅមន្ទីរ-១៣នេះ ខ្ញុំសូមសរុបសង្ខេបប៉ុណ្ណេះ ហើយសូមលោកចៅក្រមលោកមេត្តា សួរខ្ញុំតាមជាក់ស្តែងតទៅទៀត ។ សូមអរគុណ ។

[១០:១៣:១៨]

**ប្រធានអង្គជំនុំ៖**

ជនជាប់ចោទអង្គុយចុះ ដើម្បីអាចឆ្លើយនឹងសំណួរ ។

តទៅនេះ តើលោក លោកស្រីចៅក្រម មានសំណួរអ្វីត្រូវសួរដល់ជនជាប់ចោទរូបនេះទេ អំពីអង្គហេតុ ដែលពាក់ព័ន្ធនឹងម-១៣នេះ ។ សូមអញ្ជើញលោក ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** នៅពេលដែលលោកនិយាយជាលើកដំបូង ចំពោះមុខតុលាការនេះ លោកបានឆ្លើយទៅនឹងការចោទប្រកាន់ដែលបានចោទប្រឆាំងនឹងលោក ។ លោកបាននិយាយថា ខ្ញុំសង្ឃឹមថា ខ្ញុំថា ខ្ញុំមិនបញ្ជាក់អ្វីឲ្យខុសទេ លោកថា ពលរដ្ឋកម្ពុជា បានទទួលរងបន្ទាប់ពីមានការកាប់សម្លាប់ ដែលបានចាប់ផ្តើមឡើង នៅក្នុងឆ្នាំ១៩៦៦ ដែលជាពិសេស ដោយសារតែមានគោលនយោបាយ ដែលអនុវត្តដោយលន់នល់ ។ ហើយពេលនោះ ដោយមានរដ្ឋប្រហារក្នុងឆ្នាំ១៩៧០ បើសិនខ្ញុំចាំច្បាស់នោះ គឺថាវាមានការប្រកួតប្រជែងរវាងកម្មាភិបាល ដើម្បីសម្លាប់ប្រជាពលរដ្ឋខ្មែរ អ្វីដែលខ្ញុំចង់ដឹងគឺថា តើលោកអាចបញ្ជាក់ថា សេចក្តីថ្លែងការណ៍នោះ គឺជាប្រយោគដំបូងដែលលោកបានបញ្ជាក់នោះ តើលោកអាចបន្ថែមអ្វីក្នុងចំណុចនេះ?

[១០:១៥:០០]

**ឆ៖** សូមគោរពលោកចៅក្រម ឡាវែន៍ ជាទីគោរព! ទស្សនៈវិភាគរបស់ខ្ញុំចំពោះការកាប់សម្លាប់

ទៅលើប្រជាជនកម្ពុជា ខ្ញុំនៅរក្សាដដែល ។ ក្នុងនោះឧក្រិដ្ឋកម្មរបស់ខ្ញុំដែលចូលរួមនៅខាងម-១៣ ខ្ញុំនឹងបញ្ជាក់ដូចតទៅ៖

វិញ្ញាណក្ខន្ធអ្នកដែលស្លាប់ទៅនៅម-១៣ ទាំងប៉ុន្មាន ខ្ញុំសុំខមាទោស ដូចវិញ្ញាណក្ខន្ធអ្នកដែលស្លាប់ទៅនៅស-២១ ដែរ ។ បងប្អូនអ្នកដែលស្លាប់ទៅទាំងប៉ុន្មាន ខ្ញុំនឹងសុំទោសនៅពេលសុំទោសជារួម នៅពេលតុលាការលោកអនុញ្ញាតឲ្យខ្ញុំសុំទោសជារួមដូចគ្នាដែរ ។

ត្រឡប់មកវិញឧក្រិដ្ឋកម្មទៅជាតិប្រជាជនខ្ញុំ មានប៉ុន្មានភាគី ខ្ញុំគិតថានេះវាជារឿងនយោបាយ ។ ខ្ញុំនឹងបញ្ជាក់បើសិនជាលោកចៅក្រមត្រូវការ តែបញ្ជាក់នេះ គឺសូមបញ្ជាក់ថា តាមទស្សនៈខ្ញុំ តាមទស្សនៈវិភាគរបស់ខ្ញុំ ។

**ស៖** ប្រហែលជាយើងនឹងមានឱកាស ដើម្បីត្រឡប់ទៅចំណុចនេះនៅពេលក្រោយ ។ ឥឡូវនេះខ្ញុំនិយាយអំពីចំណុចមួយ គឺថាមុន ម-១៣ ។ ខ្ញុំគិតថា វាចំណុចសំខាន់មួយដើម្បីនឹងដកស្រង់ពីបរិបទប្រវត្តិសាស្ត្រឡើងវិញ នៅក្នុងមន្ទីរម-១៣ ដែលថាវាកើតឡើងម៉េច? អនុវត្តដូចម្តេច? លោកបាននិយាយអំពីការកាប់សម្លាប់នៅក្នុងឆ្នាំ១៩៦៦ ។ សូមឲ្យលោកបញ្ជាក់ថា លោកផ្ទាល់ លោកបានឃើញធ្វើជាសាក្សីនៅក្នុងករណីនោះ ជាអំពើហិង្សានយោបាយ តើលោកអាចបញ្ជាក់ប្រាប់យើង ដូចម្តេចខ្លះអំពីហេតុការណ៍នោះ?

**ឆ៖** សូមគោរពលោកចៅក្រម! ខ្ញុំតាមដានព្រឹត្តិការណ៍នយោបាយ បោះឆ្នោតឆ្នាំ១៩៦៦ នេះច្បាស់លាស់ ។ ក៏ប៉ុន្តែដែលថា ឲ្យឃើញនឹងភ្នែកព្រឹត្តិការណ៍សំឡូត គឺអត់ឃើញទេ ។ សូម្បីតែរូបក្បាលខ្មោច ដែល ខៀវ សំផន គាត់ដាក់នៅក្នុងសៀវភៅប្រវត្តិសាស្ត្ររបស់គាត់នោះ ក៏ខ្ញុំមិនដែលឃើញទេពីមុនមក ។ ក៏ប៉ុន្តែព្រឹត្តិការណ៍ដែលវាទៅដល់ត្រចៀកខ្ញុំ អំពីការកាប់សម្លាប់នៅសំឡូត ពេលនោះតិចណាស់ៗ ក៏ប៉ុន្តែខ្ញុំដឹងថា ព្រឹត្តិការណ៍នេះវាកើតឡើងដោយសារឧត្តមសេនីយ៍ លន់ នល់ ។

[១០:១៨:៣១]

**ស៖** អ៊ីចឹងហើយនៅក្នុងបរិបទនយោបាយដែលយើងត្រឡប់ទៅរកការឃុំខ្លួននៅពេលក្រោយបន្តិចទៀត ។ ប៉ុន្តែ លោកនិយាយអំពីរដ្ឋប្រហារឆ្នាំ១៩៧០ ។ រដ្ឋប្រហារនោះដែលថាគេធ្វើរដ្ឋប្រហារបណ្តេញសម្តេច សីហនុ ហើយអ៊ីចឹងហើយសាធារណរដ្ឋជារបបមួយដែលបានបង្កើតឡើងដោយ លន់ នល់ តើលោកអាចប្រាប់យើងទេ? បានថាតើរដ្ឋាភិបាលនោះ គេអនុវត្តដូចម្តេច? ថាដោយមានការប្រកាសនៅខែមីនា ឆ្នាំ១៩៧០ ដែលលោកយល់ឃើញថាដូចម្តេច ដែលថាសម្តេច សីហនុបានប្រកាស

ឲ្យប្រជាពលរដ្ឋខ្មែរងើបឡើង ។ តើបក្សកុម្មុយនីស្តកម្ពុជាបានទទួលបទពិសោធន៍ក្នុងសម័យកាលនោះដូចម្តេច? ថាតើការរួមគ្នាគេធ្វើដូចម្តេច? ចង់ក្រងយ៉ាងដូចម្តេច?

**ឆ៖** សូមលោកគោរពលោកចៅក្រមជាទីគោរព ! ខ្ញុំសូមឆ្លើយនឹងសំណួររបស់លោកទៅតាមទស្សនៈនយោបាយរបស់ខ្ញុំ ដែលខ្ញុំឃើញ ។ សម្តេចនរោត្តម សីហនុ ពេលនោះលោកនៅជាប្រមុខរដ្ឋនៃប្រទេសកម្ពុជា លោកមានគោលជំហរមួយ គឺរាជានិយម ការពាររាជបល្ល័ង្ករបស់លោក ។ ដោយឡែកឧត្តមសេនីយ៍ លន់ នល់ មិនមែន នរោត្តមសីហនុ ទេ គាត់ងាកទៅខាងសហរដ្ឋអាមេរិក ។ មានការគាំទ្រពីសហរដ្ឋអាមេរិក ។ នៅពេលដែលគាត់ក្តាប់បានសភាឆ្នាំ១៩៦៦ គាត់ចាត់ចែងកិច្ចការឲ្យកើតផ្ទុះរឿងសំឡូតនេះ ។

ដូច្នេះ សភាពការណ៍កាន់តែច្របូកច្របល់តាំងពីពេលនោះមក ។ ម្ខាងសម្តេចព្រះនរោត្តម សីហនុ រាជានិយម ម្ខាងបក្សកុម្មុយនីស្តកម្ពុជា វណ្ណៈអធន ជាបក្ស *ណាហ្ស៊ីយ៉ូណាលីស្ត* នៅលើសាកលលោក តែម្ខាងទៀតឧត្តមសេនីយ៍ លន់ នល់ ។ នេះវាប្រចាក់-- វា១ច្របូកច្របូលគ្នាអ៊ីចឹង ។ បើសិនបើតាមខ្ញុំយល់ដែរ ប្រសិនបើ *រីឆាត និចស៊ុន (Richard Nixon)* គាត់កុំប្រញាប់ឲ្យ លន់ នល់ គាត់ធ្វើរដ្ឋប្រហារពេក ទុកឲ្យសម្តេចព្រះ នរោត្តម សីហនុ លោកកម្ចាត់ខ្មែរក្រហម ឲ្យ លន់ នល់ សហការជាមួយនឹងសម្តេច សីហនុ ប្រហែលជាខ្ទេច ខ្មែរក្រហមមើលទៅ ងើបមិនងាយរួចទេ ។ បើមិនខ្ទេចក៏ងើបមិនងាយរួចដែរ ។ ប៉ុន្តែ ដល់ *រីឆាត និចស៊ុន* ហើយ និង លោក *ហង់រី ឃីស៊ីងជឺ* គាត់ប្រញាប់ពេក វាទៅជា ប៉ុល ពត គេហៅថា ឱកាសមាស *ឱកាស សុងដ័រ* សម្រាប់បដិវត្តន៍របស់គាត់ ។ គាត់ស្រែកអំពាវនាវពីប៉េកាំងមកកូនចៅចូលព្រៃម៉ាគី ។ កូនចៅចូលព្រៃម៉ាគី ប្រជាជនកម្ពុជាដែលស្រលាញ់នរោត្តម សីហនុ មិនមែនស្រលាញ់ខ្មែរក្រហមទេ ចូលទៅ ។ ចូលទៅខ្មែរក្រហមក្តាប់អប់រំបណ្តោះបណ្តាលបណ្តើរ១ពី៧០ រហូតដល់ ៧៥ សុទ្ធតែ ប៉ុល ពត ។

[១០:២២:១៧]

សរុបមកលក្ខណៈនយោបាយវាបែបនេះ ។ ម្នាក់១ស្វែងរកចំណេញខាងនយោបាយទាំងអស់គ្នា លន់ នល់ ទៅដោយ លន់ នល់ ទៅ ។ សម្តេចព្រះនរោត្តម សីហនុ ទៅដោយព្រះនរោត្តមសីហនុទៅ ។ នៅពេលនុ៎ង ដែលសម្តេចព្រះនរោត្តមសីហនុ ហើយនិង ប៉ុល ពត រួបរួមគ្នាទៅជារណសិរ្សរួបរួមជាតិកម្ពុជាឡើង ។ ឯចំណែករដ្ឋាភិបាលរួបរួមជាតិកម្ពុជាធ្វើការនៅតែខាងក្រៅនុ៎ង ទីស្នាក់ការរបស់រាជរដ្ឋាភិបាលកម្ពុជានៅសណ្ឋាគារមួយនៅក្រុងប៉េកាំង គេហៅថា “សណ្ឋាគារមិត្តភាព” នៅទិសពាយ័ព្យ

ក្រុងប៉េកាំង ។ ឯចំណែក ប៉ុល ពត នៅក្នុងព្រៃធ្វើសកម្មភាពក្តាប់ប្រជាជន ក្តាប់កងទ័ព រើ លន់ នល់ វាយឯណេះ ។ នេះខ្ញុំសូមនិយាយអំពីភាគីនយោបាយ តាមទស្សនៈដែលខ្ញុំយល់ឃើញ ត្រូវឬខុសយ៉ាងម៉េច? អានេះវាជាទស្សនៈរបស់ខ្ញុំ ។

**ស៖** លោកប្រហែលជាបានដឹងអំពីរណសិរ្សរួបរួមជាតិកម្ពុជា ហើយនិងអំពីកងទ័ពជាតិរំដោះប្រជាជនកម្ពុជា ។ តើកងទ័ពនោះ មានខ្មែរក្រហមជាយុទ្ធជាខ្មែរក្រហម តើជាកងវរសេនារបស់សម្តេចសីហនុ ដែរ ថាតើជាកងទ័ពដែលគ្រប់គ្រងដោយខ្មែរក្រហមតែម្នាក់ឯង ឬយ៉ាងម៉េច ?

**ឆ៖** លោកចៅក្រមជាទីគោរព! ការយល់ដឹងរបស់ខ្ញុំអំពីកងទ័ព មានលក្ខណៈតូចចង្អៀត ។ សូមពន្យល់តាមលទ្ធភាព សូមអធិប្បាយតាមលទ្ធភាព ដែលខ្ញុំធ្វើទៅបាន ។

ឆ្នាំ១៩៦៨ ជាឆ្នាំដែលខ្មែរក្រហមចាប់ផ្តើមធ្វើសង្គ្រាមប្រដាប់អាវុធ ។ ថ្ងៃ១៨ មករា ១៩៦៨ បក្សកុម្មុយនីស្តកម្ពុជា ឲ្យ រស់ ញឹម ធ្វើកុបកម្មដណ្តើមអាវុធនៅបាយតម្រាំ ១៨ មករា មិនមែន ១៧ ទេ។ ក្រោយមកកែមក ១៧ វិញ ដោយ ប៉ុល ពត ឃើញវាជាន់គ្នាជាមួយនឹង ១៨មីនា របស់ លន់ នល់ ។ ១៨ មករា នេះចាប់ផ្តើមផ្ទុះអាវុធ ។ នៅខាងពាយព្យគេយកភ្នំវាយចាបធ្វើជាបង្អែក ។ នៅខាងនិរតី មានលេខាភូមិភាគនិរតីឈ្មោះ ម៉ា ម៉ង់ យកភ្នំឱរ៉ាល់ ធ្វើជាមូលដ្ឋានបង្អែក ។ នៅខាងភ្នំវល្លិ៍ តាម៉ុក យកភ្នំវល្លិធ្វើជាមូលដ្ឋានបង្អែកនៃការតស៊ូ ។ ឯចំណែកនៅខាង កែ ពក, កុយ ធួន នោះយកព្រៃឡង់ ព្រៃសិននេះ ធ្វើជាមូលដ្ឋានបង្អែក ។

ដោយឡែក ប៉ុល ពត នៅក្នុងឆ្នាំ១៩៦៨ ខ្លួនឯងរំដោះដីនៅខាងភូមិភាគឦសានរតនគីរី ។ បើតាម លន់ នល់ និយាយនៅក្នុងសម្ភាសន៍សន្និសីទការងារមួយ មានទំហំដីប៉ិនខេត្តកំពង់ឆ្នាំង ។ ដូច្នេះកងទ័ពនេះ វាកកើតឡើងមុនដំបូងជាសង្គ្រាមឈ្លប ជាកងឈ្លប ។ ហើយសូមបញ្ជាក់ជូនលោកចៅក្រមថា សង្គ្រាមឈ្លប កងឈ្លបនេះ វាជាដំណាក់ទី២ ហើយទេ ។ ដំណាក់ទី១ គេហៅថា កងការពារសម្ងាត់ វាមានតាំងពី ១៩៦៦ ម្ល៉េះ ។ ខ្ញុំឃើញនៅក្នុងឯកសារចម្លើយសារភាព ។

[១០:២៦:៣៣]

គេហាត់ពត់លត់ដំមនុស្ស ដោយគេមានកងឈ្លបរបស់គេស្រាប់អ៊ីចឹង ពេលដែលប្រជាជនខឹងជាមួយនឹង លន់ នល់ ការពារសម្តេច សីហនុ, ប៉ុល ពត ត្រងយកកម្លាំងនេះទៅរៀបចំកងទ័ពបណ្តើរៗមក ។ ដំបូងឡើយ បើតាមខ្ញុំចាំមានត្រឹមតែអនុសេនាធំទេ មិនមានដល់វរសេនាតូចទេ ហើយចេះតែកកើតមក ។

ដោយឡែក កាលដែលវាឈ្នះទាហានខេមរភូមិន្ទ មិនខេមរភូមិន្ទទេ ទាហានរបស់ លន់ នល់ ដោយសារពួកវៀតណាម ដែលគេមកបោះទីតាំងស៊ុត្រីទន្លេសាប រត់នឹងគ្រប់បែក *បេ*៥២ របស់អាមេរិកមកជ្រកនៅស្រុកខ្មែរ ។ ឆ្លៀតឱកាសនឹងភ្លាម គេប៉ះបោរឈ្មុលឡើងដណ្ដើមរដ្ឋអំណាច កាន់កាប់រដ្ឋអំណាចនៅកម្ពុជា ។ ជាពិសេសខ្ញុំបានលើកជូនឧទាហរណ៍អម្បាញ់មិញហើយ នៅខាងស្ពានកោះធំ លើកដែក កៀនស្វាយនេះ ។ បក្សកុម្មុយនីស្តកម្ពុជាគេ-- សុំទោស! បក្សពលករវៀតណាម គេរៀបចំរដ្ឋអំណាចទៅតាមគោលការណ៍សហពន្ធន៍ឥណ្ឌូចិន ព្រោះ ឡេ យន់ ខ្លួនគេនេះ គេនៅតែតាំងខ្លួនគេជាបិតាឥណ្ឌូចិន ទោះបីជាមាន ៥៤ ក៏ដោយ ។

ដូច្នេះគណៈកម្មាធិការកងទ័ពដែលគេចាត់តាំង ដែល ខៀវ សំផន ជាប្រធាន អីៗនុំង ជារូបភាពបង្ហាញសាកលលោកទេ ។ ឯចំណែក ប៉ុល ពត នៅតែក្ដាប់ទ័ពតាំងពីជាតិណា ជាតិណីមក នៅតែ ប៉ុល ពត ក្ដាប់ទ័ពដដែលទេ ។ ដូច្នេះការកសាងកងទ័ពវាទៅបណ្ដើរៗអ៊ីចឹង សូមបញ្ចោក់ជូនលោកចៅក្រមប៉ុណ្ណេះ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមប្រកាសសម្រាក ២០នាទី រហូតដល់ម៉ោង១១ ខ្ទះ១៥នាទីអញ្ជើញចូលវិញ ។

*[សវនាការសម្រាកនៅម៉ោង ១០:៣០ រហូតដល់ម៉ោង ១១:០៥នាទី]*

[១០:៥៤:០៥] [១១:០៥:00]

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញអង្គុយចុះ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

មានបញ្ហាមួយ ដែលខ្ញុំចង់ឲ្យលោក លោកស្រី ធ្វើការដោះស្រាយ គឺការបកប្រែមានបញ្ហា គឺអ្នកស្ដាប់ភាសាអង់គ្លេស គឺពិបាកយល់នូវអ្វីដែលបានលើកឡើង ។ ដូច្នេះ ខ្ញុំសូមស្នើឲ្យជនជាប់ចោទនិយាយឲ្យបានយឺតៗបំផុត ហើយធ្វើការឈប់ឲ្យបានច្រើនកន្លែង ។ យើងត្រូវដឹងថា ភាសាបកប្រែ

ពីខ្មែរទៅអង់គ្លេសគឺគាត់គួរតែជម្រាបយើងឲ្យបានដឹងនៅពេលដែលមានបញ្ហា ប្រសិនមិនដូច្នោះទេ គឺថាបកប្រែនឹងមិនត្រឹមត្រូវ ។

ដូច្នេះ នៅក្នុងសវនាការផ្លូវច្បាប់ បើសិនជាអ្នកបកប្រែអត់យល់ គឺយើង--លោកអ្នកបកប្រែត្រូវជម្រាបប្រាប់ឲ្យយើងដឹង ហើយបញ្ហាទីពីរ ប្រសិនបើមានបញ្ហាបច្ចេកទេស នៅពេលដែលជនចោទនិយាយឈ្មោះមនុស្ស ឬក៏ទីកន្លែងផ្សេងៗនោះ គឺក្រឡាបញ្ជី ឬក្រឡាបញ្ជីខ្មែរ គឺគួរតែសរសេរភ្លាមៗនូវឈ្មោះទាំងអស់នោះ ដើម្បីឲ្យយើងអាចមើលឃើញក្នុងអេក្រង់របស់យើង យើងអាចមើលឃើញជាភាសាឡាតាំង ហើយខ្មែរយើងសរសេរជាភាសាឡាតាំង ហើយយើងគួរ យើងធ្វើដូច្នេះដើម្បីយើងយល់ថាមានការលើកឡើងឈ្មោះណាខ្លះ នេះជាសំណើររបស់ខ្ញុំ ហើយមិនមានអ្វីពិបាកទេ ។

ដូច្នោះ ក្រឡាបញ្ជីជាតិគួរតែសរសេរឈ្មោះផ្សេងៗជាភាសាឡាតាំង នៅពេលដែលមានការលើកឡើងហើយ ខ្ញុំស្នើឲ្យជនជាប់ចោទនិយាយឲ្យបានយឺតៗ ដើម្បីឲ្យយើងអានឈ្មោះ ឬបញ្ជាក់ឈ្មោះនោះឲ្យបានត្រឹមត្រូវ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះ កត់សម្គាល់នូវសំណូមពររបស់មេធាវីការពារក្តីដែលបានលើកឡើងនូវបញ្ហានេះ។ ហើយក៏ស្របដែរ ទៅនឹងហេតុផលទាំងឡាយ ដែលក្រឡាបញ្ជីនៃអង្គសាលាដំបូងបានធ្វើការកត់សម្គាល់អ៊ីចឹងទីមួយ គឺសុំបញ្ជាក់ម្តងទៀត ជនជាប់ចោទនៅពេលដែលឆ្លើយនឹងសំណួរដែលភាគីផ្សេងៗនឹងសួរព្រមទាំងអង្គជំនុំផងនោះ សូមនិយាយឲ្យបានយឺត យឺតបន្តិច ។ ហើយទីពីរ គឺបានសូមនិយាយហ្នឹងដោយមានការខ្លីៗ ដើម្បីជាការសម្រួលដល់ការបកប្រែផង ហើយចំពោះបច្ចេកទេសផ្សេងទៀតនោះ គឺអង្គជំនុំជម្រះនឹងព្យាយាមដើម្បីធ្វើការសម្រួលជាមួយនឹងខាងបច្ចេកទេសនៃខាងរូបភាពនេះ ជាមួយនឹងខាងក្រឡាបញ្ជីនៃអង្គជំនុំជម្រះ ដើម្បីឲ្យដំណើរការទៅបានល្អ ។

ហើយមុននឹងចាប់ផ្តើមដំណើរការនៃការសួរពាក់ព័ន្ធជាមួយនឹងមន្ទីសន្តិសុខ“ម-១៣” អង្គជំនុំជម្រះសូមឆ្លៀតឱកាសជម្រាបជូនដំណឹងដល់ភាគីទាំងអស់បានជ្រាបថា កិច្ចដែលភាគីត្រូវធ្វើសេចក្តីសន្និដ្ឋាន ឬយោបល់កត់សម្គាល់សង្ខេបទៅនឹងបញ្ហាពាក់ព័ន្ធនឹងចម្លើយរបស់ជនជាប់ចោទជាមួយនឹងតំណាងរបស់យូ.អ៊ិន.អេក.ស៊ី.អរ លោក គ្រីស្ទហ្វឺ-- គ្រីស្តុប ប៉េស៊្វ ឯកសារលេខ ឌី០៩(D09) ERNចាប់ពី០០១៤៧៨៤១ រហូតដល់០០១៤៤៨៧៨-៨៨ ដោយសង្ខេបនោះ សូមឲ្យភាគីសរសេរនៅក្នុងកម្រិតមិនឲ្យលើសពីបួនទំព័រ ជាភាសាខ្មែរ និងពីរទំព័រ ជាភាសអង់គ្លេស ឬក៏ជាភាសាបារាំង

ហើយកំណត់ត្រឹមម៉ោងបួនរសៀលថ្ងៃពុធ ទី៨ ខែមេសា ឆ្នាំ២០០៩ ជាកំហិតក្នុងការដាក់ជូននូវឯកសារនេះមកអង្គជំនុំជម្រះ ។

ជាកិច្ចបន្តនេះ សូមអញ្ជើញលោក ហ្សង់ម៉ាក អញ្ជើញបន្តទៀត ។

អញ្ជើញសហព្រះរាជអាជ្ញា ។

**លោក រ៉ូប៊ឺត ពេទីត៖**

សូមអភ័យទោស និយាយអំពីបកប្រែ ថាខ្ញុំសូមឲ្យលោក លោកស្រីចៅក្រម និយាយបញ្ជាក់អំពីភាសា និងចំនួនទំព័រទៅលើបញ្ហា ដែលលោក លោកស្រីបានលើកឡើងអម្បាញ់មិញទាក់ទងនឹងសន្និដ្ឋាននេះ ដោយសារតែបកប្រែមិនសូវច្បាស់ ។

**ប្រធានអង្គជំនុំ៖**

ខ្ញុំសូមជម្រាបថា សេចក្តីសន្និដ្ឋាន ឬក៏យោបល់កត់សម្គាល់ដោយសង្ខេប គឺអង្គជំនុំជម្រះតម្រូវឲ្យភាគីធ្វើក្នុងកម្រិតមិនឲ្យលើសពីពីរទំព័រ ចំពោះភាសាបារាំង ឬក៏ភាសាអង់គ្លេស ចំណែកឯភាសាខ្មែរកម្រិតត្រឹមមិនឲ្យលើសបួនទំព័រ ។

បន្តកិច្ចនីតិវិធីដេញដោលតទៀត សូមលោកហ្សង់ម៉ាក បើសិនជាលោកមានសំណួរអ្វីចង់សួរជនជាប់ចោទបន្ត, សូមអញ្ជើញ ។

[១១:០០:៥១]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** ដូច្នេះ យើងបន្តចំពោះបរិបទប្រវត្តិសាស្ត្របន្តទៀត ការបង្កើតមន្ទីរម-១៣ លោកបានរៀបរាប់ ជូនយើងអំពីការធ្វើផ្តួលរលំ ហើយលោកនិយាយអំពីការអំពាវនាវរបស់សម្តេច ព្រះសីហនុលើប្រជាជន ហើយលោក លោកស្រីនិយាយអំពី--លោកនិយាយអំពីកងកម្លាំងរបស់ខ្មែរក្រហម ហើយលោកបានរៀបរាបអង្គហេតុមួយចំនួន ដែលលោកមិននៅក្នុងជួរយោធា។ តើលោកជាផ្នែកមួយនៃកងកម្លាំងយោធា ឬយ៉ាងម្តេច ?

**ឆ៖** នៅខែធ្នូ ឆ្នាំ១៩៧០ មានបង្កើតគណៈកម្មាធិការតំបន់២៥ គេឲ្យខ្ញុំជាបង្រៀននយោបាយនៅក្នុងអង្គភាពកងទ័ព ។ ខ្ញុំមិនមែនជាកម្មាភិបាលដឹកនាំកងទ័ពប្រយុទ្ធទេ ។ ដល់ខែឧសភា ឆ្នាំ១៩៧១ ខ្ញុំឃើញ បរិយាកាសនៅទីនោះ វាមិនមែនជាបរិយាកាសបដិវត្តន៍ ជាបរិយាកាសកាប់គ្នាដណ្តើមបុណ្យស័ក្តិ ខ្ញុំក៏ឆ្លៀតឱកាសមកភូមិភាគនិរតី ។ សរុបមក និយាយមួយមាត់ ខ្ញុំនៅក្នុងកងទ័ព ក៏ប៉ុន្តែ

ជាកម្មាភិបាលបង្រៀននយោបាយ ។

**សៈ** អភ័យទោស ថាតើលោមានឃើញមានការទម្លាក់គ្រាប់បែកដែរឬទេ ? តើការទម្លាក់គ្រាប់បែក បែបណាដែលលោកបានជួបប្រទះឃើញ ?

**ឆៈ** នៅតំបន់២៥ គឺផ្នែកខាងស្រុកស្អាង និងកោះធំ ដែលខ្ញុំឃើញមានការទម្លាក់ពីគ្រាប់បែកពីកប៉ាល់ហោះ ដែលខ្មែរហៅថា អាស្លាបកាត់ ក៏ប៉ុន្តែប្រហែលជាភាសាអង់គ្លេស គេហៅថា *ស្កាយរ៉េឌ័រ* គ្រាប់បែកធម្មតា ហើយគ្រាប់បែកណាប៉ាល់ អាឆេះ ខ្លោចមនុស្សនោះ ។ ទន្ទឹមនេះ ក៏មានកាំភ្លើងធំ ១០៥ផ្តោងពីតាខ្មៅ ហើយនឹងពីស្អាងទៅចូលក្នុងដីរំដោះពីព្រែកតូច ទីផ្សាររបស់ស្រុកស្អាង ព្រែកតូចទីផ្សាររបស់ស្រុកស្អាងចូលទៅក្នុងដីរំដោះ ។ ដល់ខ្ញុំទៅនៅឯ អមលាំង គ្មានឃើញណាប៉ាល់ទេ ឃើញតែអាគ្រាប់ បែកធម្មតាដែលយន្តហោះ ខ្មែរគេហៅថាអាស្លាបកាត់នោះ ទម្លាក់លើភូមិ ឃុំ ហើយនិងការបាញ់ពីលើកប៉ាល់ហោះមកដី បាញ់នៅជិតមន្ទីរខ្ញុំពីរ-បីម្តងដែរ ហើយឯចំណែកកប៉ាល់ហោះបេ៥២ ខ្ញុំឃើញវាហោះពីមេឃ ខ្ញុំដេកផ្ងារពោះមើល ឲ្យតែវាធំ អាងនឹងគេចទៅចំហៀងវា តែវាមិនដែលឃើញចំ ។ ប៉ុន្តែ កប៉ាល់ហោះអាប៉េ៥២ វាទម្លាក់នៅជិតមន្ទីភាគនិរតីម្តង ទម្លាក់នៅជិតនៅមន្ទីរភូមិភាគពិសេសម្តង នេះប៉េ៥២ ។

**សៈ** ខ្ញុំសូមចូលទៅដល់ពេលវេលាដែលលោកបានចូលរួមបក្សកុម្មុយនីស្ត ថាតើលោកចូលជាសមាជិកពេញសិទ្ធិនៃបក្សកុម្មុយនីស្តនៅពេលណា? តើលោកជាសមាជិកនៅពេលណា? ថាតើនរណាជាអ្នកណែនាំលោកឲ្យចូល? ថាតើលោកចូលយ៉ាងម៉េច?

**ឆៈ** សូមជម្រាបបញ្ជាក់ថា នៅឆ្នាំ១៩៦៥-៦៦ ខ្ញុំបានចូលនៅអង្គការមួយ គេហៅថាអង្គការមហាជនរបស់បក្ស ជាភាសារបស់បក្សកុម្មុយនីស្តកម្ពុជា អាហ្នឹងគេហៅថា "ចុងបង្គោល" ខ្ញុំមិនដឹងភាសាបរទេសប្រែថាម៉េចទេ "បង្គោល" បើបារាំងយើងហៅថា *"ភ្នឺ"* ។ ខ្ញុំគ្រាន់តែបញ្ជាក់ជូនលោកចៅក្រមថា "អង្គការបង្គោល" ដែលខ្ញុំចូលនេះ មានតម្លៃស្មើរតែស្មើនឹងអង្គការសម្ព័ន្ធយុវជនកុម្មុយនីស្តកម្ពុជា ក៏ប៉ុន្តែដោយខ្ញុំមានប្រាក់ខែហើយ គេឲ្យខ្ញុំចូលក្នុងអង្គការនេះ ។

បន្ទាប់មក ដូចខ្ញុំបានជម្រាបលោកចៅក្រមហើយ ដើមខែតុលា ១៩៦៧ វន វ៉េតគាត់ប្រាប់ថាបក្សសម្រេចឲ្យមិត្តចូលបក្សហើយ តែធ្វើពិធីនៅទីនេះមិនបានទេ មិត្តទៅឲ្យគេខាងជនបទធ្វើឲ្យចុះ ។ ដល់ទៅជនបទ ខ្ញុំជួប កែ ពក អនុលេខាភូមិភាគឧត្តរចាស់ ។ បង ពក ក៏ធ្វើពិធីបញ្ចូលខ្ញុំជាសមាជិកបក្ស ក្នុងឋានៈជាបក្សជនត្រៀម ដែលបារាំងយើងហៅថា *"ម៉េមប៊ែរ ស្តាហ្សែរ"* ។

ខ្ញុំចូលនៅថ្ងៃ២៥ ធ្នូ ១៩៧០ ។ ថ្ងៃ០៥ មករា ១៩៧០ អ៊ូ, សូមទោស! ២៥ ធ្នូ ១៩៦៩ ទេៗៗ! សូមទោស! ច្របូលច្របល់ថ្ងៃខែអស់ហើយ សូមទោស! ខ្ញុំសូមនិយាយម្តងទៀត ។

ខ្ញុំចូលជាសមាជិកបក្សក្នុងឋានៈជាបក្សជនត្រៀម នៅថ្ងៃ២៥ ធ្នូ ១៩៦៧ សូមបញ្ជាក់ ២៥ ធ្នូ ១៩៦៧ អ្នកទទួលស្គាល់ខ្ញុំជាបក្សជនត្រៀមគឺ កែ ពក អនុលេខាភូមិភាគឧត្តរ ។ ថ្ងៃ០៥ ខែមករា ១៩៦៨ គេចាប់ខ្ញុំយកមកដាក់គុក ។ ខ្ញុំទៅដល់គុកធំ សាខានៅគុកធំនោះដឹកនាំដោយបង ទេព សឿន អនុញ្ញាតឲ្យខ្ញុំចូលជាសមាជិកបក្សពេញសិទ្ធិ ។

នៅថ្ងៃ២០ កក្កដា ១៩៦៩ អ្នកទទួលស្គាល់ខ្ញុំជាបក្សជនពេញសិទ្ធិ គឺបង ទេព សឿន ។ សូមបញ្ជាក់ជូនជាតិ ប្រជាជនតាមរយៈអង្គជំនុំជម្រះថា បង ទេព សឿន នេះ ដល់ក្រោយមកគាត់យកឈ្មោះជា ស សឿន ។ បង ស សឿន នេះជាសមាជិកអចិន្ត្រៃយ៍សភាប្រជាជនកម្ពុជារបស់ ប៉ុល ពត នេះ គាត់ទទួលស្គាល់ខ្ញុំជាបក្សជនពេញសិទ្ធិនៅថ្ងៃ២០ កក្កដា ១៩៧០ ។

[១១:០៩:១០]

**ស៖** លោកបានជម្រាបអម្បាញ់មិញអំពីគ្រូរបស់លោក លោកថា គាត់មានតួនាទីសំខាន់នៅក្នុងជីវិតរបស់លោក ។ ថាតើលោកស្គាល់បក្សកុម្មុយនីស្តកម្ពុជាតាមរយៈគ្រូឬក៏យ៉ាងម៉េច? តើលោកស្គាល់តាមរយៈណា?

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា ទីមួយគ្រូបង្រៀនខ្ញុំតាមផ្លូវការរាជការ ។ គ្រូបង្រៀនខ្ញុំតាមផ្លូវការរាជការមានម្នាក់ពីរដែរ ដែលធ្វើឲ្យខ្ញុំចាប់អារម្មណ៍ចំពោះចលនានយោបាយ គឺ កែ គឹមហួត ។ ហើយនិងមេខ្ញុំទៅអនាគតហ្នឹង លោកគ្រូ សុន សេន ។ ក៏ប៉ុន្តែ ខ្ញុំចូលធ្វើនយោបាយស៊ប់ ដោយសារខាងរដ្ឋាភិបាលគេចាប់ជនចម្រើនជាង១០នាក់ ក្នុងនោះរួមមាន ឆាយ គឹមហ៊ា ផង ។ ពេលហ្នឹងខ្ញុំចូលធ្វើសកម្មភាពនយោបាយស៊ប់ជាមួយនឹងគេ ជាមួយនឹងមិត្តភក្តិនៅ *"អាំងស្ទីស្ទុយណាស្យូណាល់ ឌឺប៉េរ៉ាគូហ្ស៊ី គ្រូបស៊ូប"* ។ *"អាំងស្ទីស្ទុយណាស្យូណាល់ ឌឺប៉េរ៉ាគូហ្ស៊ីគ្រូបស៊ូប"* ហ្នឹងវាជាកន្លែងបណ្តុះបណ្តាលជនចម្រើននៅទីនោះហើយ ។ ពេលនោះខ្ញុំជាមួយនិងមិត្តភក្តិទេ ធ្វើសកម្មភាពរួមជាមួយគ្នា មាន កង សារ៉ន ។ កង សារ៉ន នេះគាត់ជាសិស្សជំនាន់ទី១ នៃអនុវិទ្យាល័យកំពង់ធំ គាត់ជានិស្សិតសាស្ត្រាចារ្យភាសាខ្មែរ ។ ហើយជាមួយនិងមិត្តភក្តិចាស់របស់ខ្ញុំតាំងពីក្មេងមក ឈ្មោះ ហូ ងារ នៅជាមួយនឹងគ្នានេះ ។

ដូច្នេះ គ្រូបង្រៀនវាម្យ៉ាង តែការសម្រេចចូលធ្វើសកម្មភាពបដិវត្តិន៍ រួមសកម្មភាពពិតប្រាកដ

ជាមួយនឹងគេវាម្យ៉ាងទៀត ។ គ្រូបង្រៀនដែលមានឥទ្ធិពលលើខ្ញុំ គឺមានពីរនាក់ហ្នឹងឯង ធំជាងគេ គឺលោកគ្រូ សុន សេន ដែលអនាគតក្រោយមកនោះគឺមេខ្ញុំហ្នឹង ។ ហើយអ្នកដែលរួមសកម្មភាពដំបូង គឺមាន កង សារ៉ន, មាន ហូ ងារ, មាន អ៊ឹម លន ហៅ “ណាត” ប្រធានស-២១ ដំបូងហ្នឹង ហើយធ្វើសកម្មភាពទាំងអស់គ្នាអ៊ីចឹងតរហូតមក ។

**ស៖** វាជាព្រឹត្តិការណ៍សំខាន់ចំពោះការចាប់ខ្លួន និងការឃុំខ្លួនលោក ប្រសិនបើខ្ញុំយល់ត្រឹមត្រូវ នោះ គឺលោកត្រូវបានចាប់ខ្លួននៅថ្ងៃទី០៥ ឆ្នាំ១៩៦៨ ហើយលោកបានដោះលែងនៅថ្ងៃទី០៣ ខែមេសា ឆ្នាំ១៩៧០ ។

**ឆ៖** អម្បាញ់មិញនេះ គឺពិតជាត្រឹមត្រូវហើយ វាចេញពីសម្តីខ្ញុំដែលរាយការណ៍ជូនលោកពិត ។ អ្នកដែលចាប់ខ្ញុំនៅចម្ការលើ សូមបញ្ជាក់ចំកន្លែងហ្នឹង នៅស្រុកចម្ការលើ ខេត្តកំពង់ចាម ។ អ្នកដែលទៅចាប់ខ្ញុំគឺប៉ូលិសរបស់ នរោត្តម សីហនុ អ្នកដែលចាប់ខ្ញុំហ្នឹង អ្នកស្រុកស្មោងជាមួយនឹងខ្ញុំទៀត ឈ្មោះ ស្រី គឹមសឿន រៀនមុនខ្ញុំ *ម៉ាប្រម៉ូស្យុង* នៅ *ក្រឡេស* នេះ ក៏ប៉ុន្តែគាត់ទៅចាប់ភារកិច្ចរបស់គាត់ ខ្ញុំរត់គេចមិនរួចអាហ្នឹងវាជាភារកិច្ចរបស់ខ្ញុំ ជារឿងខ្ញុំ ។ គេចាប់ខ្ញុំ បូលិស សីហនុ ។ ខ្ញុំមកជាប់គុកនៅ *អេតាម៉ាហ្ស៊័រ ឌឺឡាប៉ូលិស* នៅទួលគោក មិនមែននៅ *ឌឺរិចស្យុងស្ស៊េណារ៉ាល់ ឌឺឡាប៉ូលិសឌឺណាសេណាល់* នៅផ្លូវ*ប៉ាស្ទ័រ* ទេ ។

សូមបញ្ជាក់ថា ខ្ញុំមកជាប់គុក នៅ *“អេតាម៉ាហ្ស៊័រ ស្ស៊េណេរ៉ាល់ ឌឺឡាហ្គាកប្រូវាំងស្យាល់”* មិនមែននៅ *“ឌឺឡាប៉ូលិស” នុំង “ដឺឡាហ្គាសរ៉ូយ៉ាល់”, “អេតាម៉ាហ្ស៊័រ”* នេះនៅទួលគោក ។ ឯចំណែកខ្មែរក្រហមទូទៅគេជាប់គុក គេជាប់គុកនៅ *“ឌឺរិចស្យុងស្ស៊េណេរ៉ាល់ ឌឺឡាប៉ូលិស”* ដែលភាសាខ្លះហៅថា *ប៉េហ្ស៊ី* ប៉ូលិស *ហ្សួរឌីកប៉ែហ្ស* នោះ នេះសូមបញ្ជាក់ឡើងវិញ ខ្ញុំមកជាប់គុក ជាប់គុករបស់ នរោត្តម សីហនុ នៅទួលគោក ។ ហើយដល់ក្រោយមកអ្នកដែលដោះលែងខ្ញុំ ស្គាល់លោកជ្រាបហើយ លោកចៅក្រមក៏ជ្រាបដែរ ថ្ងៃ១៨ មីនា ១៩៧០ *សេនេរ៉ាល់* លន់ នល់ គាត់ធ្វើរដ្ឋប្រហារទម្លាក់នរោត្តម សីហនុ ដើម្បីអួតប្រាប់សាកលលោកថា គាត់មិនឃោរឃៅដូច នរោត្តម សីហនុទេ មកដល់ចោទគេខៀវ, មកដល់ចោទគេក្រហមចាប់ដាក់គុក ។

ឧត្តមសេនីយ៍ លន់ នល់ គាត់ធ្វើឫកជាដោះលែងមនុស្សទាំងអស់ ដែលនៅជាប់គុកនយោបាយ រួមទាំងខ្មែរក្រហម រួមទាំងខ្មែរសេរី រួមទាំង យួន យៀកកុង រួមទាំងយួនធីវគី ។ សូមបញ្ជាក់ជូនលោកចៅក្រមថា ពាក្យដែលខ្ញុំប្រើ *យួនធីវគី* នេះ ប្រើតាមភាសាអ្នកស្រុកខ្មែរ ភាសារផ្លូវការគេគឺ

រដ្ឋាភិបាលសាធារណរដ្ឋវៀតណាមដែលដឹកនាំដោយប្រធានាធិបតី *ង្វៀង យ៉ាំងធីវ* និងអនុប្រធានាធិបតី *ង្វៀង កៅគី* ។ ដូច្នេះពេលហ្នឹង គាត់ដោះលែងទាំងអស់ ទាំងខ្ញុំទាំងគេក៏បានរួច ។ ឆ្លៀតឱកាសនេះខ្ញុំសូមបន្ថែមពាក្យដែលខ្ញុំបានជម្រាបលោកចៅក្រមពីព្រឹកមិញថា មានគេឡើបប្រាប់ខ្ញុំថា ឲ្យប្រយ័ត្នខ្លួន តាណុន ប្អូនពៅ តានល់ មានកងសម្ងាត់របស់គេមួយ សម្រាប់លួចចាប់មនុស្សយកទៅធ្វើឃាតជាសម្ងាត់ ឲ្យខ្ញុំប្រយ័ត្នខ្លួននេះខ្ញុំត្រឡប់ទៅដល់នុ៎ងវិញ ។ ឥឡូវខ្ញុំបន្តទៅទៀត សរុបឡើងវិញ អ្នកដែលចាប់ខ្ញុំគឺប៉ូលិស នរោត្តម សីហនុ អ្នកដែលដោះលែងខ្ញុំគឺ លន់ នល់ ។

**ស៖** នៅក្នុងដីកាដំណោះស្រាយ លោកបានត្រូវបានចាប់ខ្លួន ដោយសារការរំលោភសន្តិសុខជាតិដោយចូលរួមសហការជាមួយនឹងបរទេស ថាតើលោកបានត្រូវបានគេនាំទៅមុខតុលាការ ត្រូវបានគេកាត់ទោស ហើយលោកមានមេធាវីការពារដែរឬទេ? ហើយលោកមានការដាក់ទោសដែរឬទេយ៉ាងម៉េចឬក៏យ៉ាងម៉េចចំពោះបញ្ហាទាំងអស់នេះ?

**ឆ៖** សូមបញ្ជាក់ថា ពាក្យដែលថាគេចោទប្រកាន់នេះ វា*ក្លាស៊ិក* ហើយជំនាន់នុ៎ង ។ ប្រឆាំងនឹងសេចក្តីសុខសាន្តក្នុងព្រះនគរចូលដៃចូលជើងជាមួយនឹងបរទេស ។ អាហ្នឹងជាពាក្យដែលគេចោទប្រកាន់ទៅលើខ្មែរក្រហម ហើយនិងខ្មែរសេរី ។ ខ្ញុំជាប់គុកតាំងពីថ្ងៃ០៥ មករា ១៩៦៨ រហូតដល់ខែមិថុនា ១៩៦៩ ទើបបានគេហៅខ្ញុំយកទៅកាត់ទោស ។ ខ្ញុំអត់ដែលឃើញមេធាវីទេ ទើបមកដល់ថ្ងៃឡើងសវនាការកាត់ទោស ស្រាប់តែឃើញលោកតា មួង ឡៅខាំ ទៅជាមេធាវីខ្ញុំ ។ គេកាត់ខ្ញុំមួយព្រឹកចប់ ។ គេកាត់ទោសម្ភៃឆ្នាំ បង្ខំឲ្យធ្វើការជាទម្ងន់ ។ ខ្ញុំអត់ឧទ្ធរណ៍ទេ ។ គេក៏បញ្ជូនខ្ញុំបន្ទាប់ពីនោះកន្លះខែមកគុកធំភ្នំពេញ ដែលបារាំងហៅថា *ប្រីស្សុងសង់ត្រាល់* គឺមកដល់ទីនេះហើយដែលខ្ញុំជួបសាខាបក្សកុម្មុយនីស្តកម្ពុជា ដែលធ្វើការសម្ងាត់នៅនឹងគុកធំនោះ ហើយដែលបញ្ចូលខ្ញុំជាសមាជិកពេញសិទ្ធិ ។

**ស៖** មុនពេលលោកបញ្ជូនមកគុកធំ ថាតើលោកត្រូវបានគេឃុំនៅព្រៃស ឬក៏ជិតព្រៃស ឬក៏យ៉ាងម៉េច?

**ឆ៖** ដំបូង គេដាក់ខ្ញុំនៅគុកប៉ូលីសនៅទួលគោក ដូចខ្ញុំជម្រាបលោកចៅក្រមអម្បាញ់មិញហ្នឹងដល់ក្រោយមកគេបញ្ជូនខ្ញុំមកគុក *ប៉េអ៊ឹម* នៅភ្នំពេញ ។ គុកប៉េអ៊ឹម ជំនាន់នោះមានពីរ ប៉េ.អ៊ឹម *សិចស្យុង* ភ្នំពេញ ហើយនិង *ប៉េអ៊ឹម* ទូទាំងប្រទេស ។ ខ្ញុំជាប់គុកប៉េអឹមទាំងពីរកន្លែង ។ ហើយដល់ថ្ងៃ-- ដូចជាខែ៥ ១៩៦៨ គេបញ្ជូនខ្ញុំពីប៉េអឹមទៅព្រៃស ។ ព្រៃសនេះជាគុកទាហាន គុករបស់ លន់ នល់ ។ និយាយ

ឲ្យត្រង់គឺនៅពេលហ្នឹងហើយ ដែលជីវិតអ្នកជាប់គុក តក់ស្លុតរន្ធត់បំផុតគ្រប់ដង្ហើម ពេលហ្នឹងហើយ ដែលគេលួចយកមនុស្សពីរនាក់យកទៅសម្លាប់ ។

ក្រៅប្រព័ន្ធច្បាប់ ទៅដល់គុកហើយនៅលួចយកទៅសម្លាប់ទៀត ។ មនុស្សម្នាក់ជា *អាំងស្ទុយ ទុយទ័រ ឌុយប្រេ្គ កុំប្លេម៉ង់ទែរ* ឈ្មោះ ឡោ សាន ។ គេលួចយកទៅសម្លាប់ មនុស្សម្នាក់ទៀតជា កសិករទេឈ្មោះ ឈាង ហុក ក៏លួចទៅសម្លាប់ដែរ ។ គេហៅយកពួកនេះចេញទៅ ខ្ញុំឃើញនឹងភ្នែក ។

ដូច្នេះ សរុបមកខ្ញុំនៅគុកព្រៃស ប្រហែលពីខែ៥ រហូតមកដល់ខែ៦, សូមទោស ខែ៥ ១៩៦៨ រហូតមកដល់ខែ៦ ចុងខែ៦ ឬដើមខែ៧ ១៩៦៨ ទើបបានខ្ញុំមកដល់គុកធំ ។

**ស៖** លោកទើបតែជម្រាបយើងខ្ញុំ លោកគឺជាអ្នកឃើញផ្ទាល់ភ្នែកចំពោះការសម្លាប់ក្រៅប្រព័ន្ធ តុលាការ ឬក៏ការសម្លាប់អ្នកជាប់ឃុំជាមួយនឹងលោក ។ ថាតើលោកអាចពន្យល់ឲ្យច្បាស់ជាងហ្នឹងដែរ ឬទេ ? លោកនិយាយអំពីការភ័យខ្លាចទាំងអស់នោះ ។ តើលោកអាចជម្រាបយើងខ្ញុំអំពីអារម្មណ៍របស់ លោក ហើយបទពិសោធន៍របស់លោកយ៉ាងម៉េចទាក់ទងទៅនឹងកំឡុងពេលលោកត្រូវបានឃុំខ្លួន ?

**ឆ៖** ពេលដែលខ្ញុំជាប់គុកប៉ូលិស ជាប់គុករាជតម្រួតនេះនៅៗទួលគោក ។ ខ្ញុំហើយនិងប៉ូលិស និយាយរាក់ទាក់គ្នា របៀបជាមនុស្សធម្មតារាល់ថ្ងៃ ។ មកនៅគុកប៉េអ៊ឺមភ្នំពេញ និងប៉េអ៊ឺមស្រះចក សភាពការណ៍គំរាមកំហែងមិនឲ្យខ្ញុំនិយាយជាមួយនឹងអ្នកទោសគ្នាឯងមាន ។ ជាពិសេស ពីសំណាក់ ប្រធានបន្ទប់ដែលជាអ្នកទោសដូចគ្នា ។

មកដល់ព្រៃស អ្នកកាច គឺអាប្រធានបន្ទប់នេះឯងដែលជាអ្នកទោសដូចគ្នា ។ វាវាយការណ៍ វា ទាត់ វាធាក់ បើសិនជាយើងខុស ។ ឯចំណែកមិត្តពីរនាក់របស់ខ្ញុំដែលគេយកទៅ គេយកទៅ បញ្ចេញពី គុកទៅ យើងខ្ញុំឃើញបញ្ចេញពីគុកទៅ ក៏ប៉ុន្តែថាឲ្យគេវ៉ៃ គេសម្លាប់នៅនឹងមុខគឺអត់ទេ ។ យកទៅបាត់ ដានរហូត ។ នៅពេលដែលគេយកទៅកណ្ដាលថ្ងៃត្រង់គេបិទទ្វារបន្ទប់យើងខ្ញុំទាំងអស់ គ្រប់គ្នាអស់ រលីង ហើយគេយកទៅ ។

អ្នកណាក៏ដឹង អ្នកណាក៏យល់ អ្នកណាក៏សន្និដ្ឋានអ៊ីចឹង ។ ហើយគេយកទៅ ហើយដល់ក្រោយ មកយើងខ្ញុំតាមរកឈ្មោះពីរនាក់មិនឃើញទេ មិនឃើញទៀតសោះ ។ នេះនិយាយអំពីការសម្លាប់នៅ គុកព្រៃស ។ នេះខ្ញុំវាមិននិយាយអំពីការកាប់សម្លាប់នៅ *ឌីវិចស្យុង ឌីវិចស្យុង ហ្សេនណេរ៉ាល់ ឌឺឡា ប៉ូលិស* ទេ ។ ដោយឮតែល្បីដល់ខ្ញុំ ហើយល្បីហ្នឹងពិត នេះខ្ញុំសុំមិននិយាយទេ ។

[១១:២៥:០៩]

**សៈ** ថាតើលោកខ្លួនឯងត្រូវបានៗធ្វើទារុណកម្ម ឬក៏លោកទទួលរងអំពើហឹង្សាណាមួយដែរ ឬទេ ? ថាតើជនអ្នកជាប់ទោសដែរហ្នឹង គឺគាត់ត្រូវបានទទួលបានការរងទារុណកម្មដូចគ្នាដែរឬទេ ?

**ឆៈ** នៅទូលគោកអ្នកសួរចម្លើយខ្ញុំជាស័ក្ដិពីរ ។ ស័ក្ដិពីរកងរាជតម្រួតគាត់ឈ្មោះ ជា លាងហ៊ិន គាត់ប៉ាានត្រឹមកំហកកំហែងខ្ញុំទេ ។

ឯចំណែក ពេលដែលខ្ញុំជាប់ហ្នឹងមានកសិករបីនាក់ទៀត មកជាមួយនឹងខ្ញុំ ។ កសិករបីនាក់ទៀតនេះ បើតាមខ្ញុំដឹងគាត់មានលួចវ៉ៃខ្លះ ។ ចំណែកនៅខាង *ឌីរិចស្យុង ហ្សែនេណេរ៉ាល់ ឌឹឡាប៉ូលិស* ដែលគេហៅថា *ប៉េអេស* (PS) នេះ អ្នកចេញវ៉ៃធ្វើទារុណកម្មទៅលើខ្មែរក្រហមជំនាន់នោះមាន ឈិត អ៊ីរ ។ ហើយនិង ដល់ក្រោយមកមានអធិការម្នាក់ទៀត *អាំងស្ពិចទ័រ ឌឹឡាប៉ូលិស* ម្នាក់ទៀតឈ្មោះ ហ៊ុំ , ហំ, ហ៊ុំ ខ្ញុំមិនដឹង ល្បីខាងវ៉ៃ ។ ខាងធ្វើទារុណកម្ម ប៉ុន្តែរឿងគេ ប៉ុន្តែខ្ញុំដឹងមក ច្បាស់លាស់ តែវាអត់ឃើញនឹងភ្នែក ។

មានម្នាក់នោះឈ្មោះ ងួន ឃាង គាត់ជា *កុងតែលល័រ កសិកម្ម* ងួន ឃាង ហ្នឹងជា *កុងតែលល័រ* កសិកម្មទៅជាប់នៅនុំង ។ ប៉ូលិសវាវ៉ៃ កំភ្លើងចូលដល់ព្រៃសហើយភ្លើងឲ្យឡើងចុងក្រាល គាត់បង្ហាញខ្ញុំ ។ អាហ្នឹងខ្ញុំឃើញតែស្នាមទេទៅដល់នុំង ។

ដូច្នេះសរុបមកផ្ទាល់ខ្លួនខ្ញុំ រាជតម្រួតគេអត់វ៉ៃទេ ។ គេមានលួចវ៉ៃខ្លះលើកសិករបីនាក់ដែលជាប់មកជាមួយនឹងខ្ញុំ សំណុំរឿងជាមួយនឹងគ្នា ។ ឯចំណែកនៅ *ប៉េអេស* (PS) វិញ ខ្ញុំឃើញភស្ដុតាង ថាគេមានវ៉ៃធ្ងន់ធ្ងរ ។

[១១:២៧:៤២]

សៈ ថាតើលោកមានអារម្មណ៍យ៉ាងម៉េចចំពោះការអនុវត្តទាំងអស់នោះ? ទោះបីជាលោកមិនមែនជាសាក្សីផ្ទាល់ភ្នែក ។ ថាតើលោកគិតអំពីការអនុវត្តបែបនោះយ៉ាងម៉េច គឺការសម្លាប់ដែលលោកនិយាយថា ក្រៅច្បាប់នោះ ។ គឺទីមួយគឺទាក់ទងទៅនឹងអំពើទារុណកម្ម ថាតើលោកយល់យ៉ាងម៉េច?

**ឆៈ** មុននឹងខ្ញុំចូលធ្វើបដិវត្តន៍ ខ្ញុំបានអានសៀវភៅអំពីអ្នកតស៊ូបដិវត្តន៍ច្រើនដែរ ។ សៀវភៅមកពីស្រុកចិនក៏មាន សៀវភៅមកពីយួនក៏មាន ។ សៀវភៅមកពីយួនមានសៀវភៅមួយដែលចាប់អារម្មណ៍អំពីរឿងធ្វើទារុណកម្មខ្លាំងដែរ ។ ចំណងជើងគេដាក់ថា នេះសៀវភៅមកពីយួន ចំណងជើងគេដាក់ថា "*ឌឹឡា ព្រីហ្សុង អូបាញ*" ហ្នឹងជារបៀបធ្វើទារុណកម្ម ។

ដូច្នេះ យើងខ្ញុំជាអ្នកធ្វើបដិវត្តន៍ យើងខ្ញុំបានតាំងចិត្តហើយថា បើកាលណាយើងខ្ញុំជាប់គុកទៅ

ច្បាស់ជាគេវ៉ៃយើងខ្ញុំហើយ ។ គេលួចយកទៅសម្លាប់ហើយ នេះបានគិតតែប៉ុនន៉ុងងអែង រឿងយុត្តិធម៌ ឬមិនយុត្តិធម៌ អាហ្នឹងមិនដឹងជាទៅស្រែកដល់ណាទេ ។ វាដឹងដែរថាវាមិនយុត្តិធម៌ គ្រាន់តែដឹង យើងខ្ញុំបានត្រៀមជីវិត ត្រៀមខ្លួន ត្រៀមអីទាំងអស់ទទួល ។ នេះជារឿងពិតនៃជីវិតបដិវត្តន៍របស់ខ្ញុំ ដែលខ្ញុំរៀន ។

**ស៖** ខ្ញុំសូមផ្តល់ព័ត៌មានពិស្តារ ។ ការធ្វើទារុណកម្មបានអនុវត្តដែលលោកបានដឹងមុនពេលដែលលោក ត្រូវបានគេឃុំខ្លួន ។ ថាតើលោកគិតថា ការទារុណកម្មនេះទទួលយកបានដែរ ឬទេ? ឬវាជាអំពើហួសហេតុ ឬក៏កាចសាហាវនៅក្នុងការយល់ឃើញរបស់លោក ?

**ឆ៖** ខ្ញុំបានជម្រាបថា ខ្ញុំបានត្រៀមទទួលទារុណកម្មអស់នេះ ។ ក្នុងឋានៈជាអ្នកតស៊ូអត់ខ្លាចស្លាប់ទេ។ ដឹងថាវាមានទារុណកម្មអស់នេះ ក៏ប៉ុន្តែឲ្យ *កុងដោនេ* អាហ្នឹង ថាជា *ត្រឹម* ហ៊ានដែរ ។ និយាយគិត ក៏ប៉ុន្តែមិនមានមធ្យោបាយអីប្រឆាំងក្រៅពីខំធ្វើបដិវត្តន៍ ដើម្បីរំលំអារបបហ្នឹង ហើយប្រឆាំងអារបបហ្នឹងទេ ។

ចង់ប្រឆាំងអារបបហ្នឹង របបទារុណកម្ម របបអីហ្នឹង គិតថាធ្វើបដិវត្តន៍គាស់រំលើងអស់ទៅក៏វានឹងចប់ ។ ហើយខ្ញុំគិតទៅដល់ខ្សែកុនមួយដែលខ្ញុំបានមើល ខ្សែកុនហ្នឹងមកពីចិន។ ខ្ញុំមើលគ្នាបួននាក់ ។ ខ្សែកុនហ្នឹងគេ និយាយភាសាចិនទេ ។ ប៉ុន្តែមានមិត្តៗម្នាក់ មិត្តស្រីម្នាក់ ស្រីម្នាក់គាត់ឈ្មោះ ឡៅ គាវ គាត់អ្នកបកប្រែ ។ មិត្ត ឡៅ គាវ ហ្នឹងអាយុប្រហាក់ប្រហែលខ្ញុំដែរ គាត់អ្នកបកប្រែឲ្យស្តាប់ ។ ខ្ញុំគិតថា ដល់បដិវត្តន៍ឈ្នះទៅ ការតាមដានចារកម្មប្រហែលតែទៅតាមហ្នឹង ។

ដូច្នេះ ត្រឡប់មកវិញឲ្យយើងខ្ញុំវិនិច្ឆ័យថា អាហ្នឹងទទួលបាន ឬទទួលមិនបាន? យើងខ្ញុំដឹងថាអាហ្នឹងវាជាបទឧក្រិដ្ឋមួយ ។ តើប្រឆាំងវាយ៉ាងម៉េច? វិធានការដោះស្រាយគឺធ្វើបដិវត្តន៍ ។ នៅពេលដែលចាប់ផ្តើមធ្វើបដិវត្តន៍ហ្នឹងយើងខ្ញុំជឿថា បក្សកុម្មុយនីស្តគេនឹងខំ តាមដានជនឧក្រិដ្ឋរបៀបដូចខ្សែកុន ដែលយើងខ្ញុំបានឃើញហ្នឹង ។ នេះសូមបញ្ជាក់ជូនប៉ុណ្ណោះ ។

[១១:៣២:២២]

**ស៖** ក្នុងការយល់ឃើញរបស់លោក ថាតើឧក្រិដ្ឋកម្ម ទារុណកម្មហ្នឹង តើឧក្រិដ្ឋកម្មអស់ហ្នឹងជាឧក្រិដ្ឋកម្មទារុណកម្ម ឬយ៉ាងម៉េច ?

**ជនជាប់ចោទ៖**

**ឆ៖** ឥឡូវនេះ វាខុសពីមុនបន្តិច ពីលើកមុនយល់ថា អាហ្នឹងវាឧក្រិដ្ឋ ។ ក៏ប៉ុន្តែ មុនឆ្នាំ១៩៧០ គេ

ជាអ្នកទទួលខុសត្រូវចំពោះមុខប្រវត្តិសាស្ត្រ ។ មិត្តជាកុលបុត្ររបស់ខ្មែរត្រូវការពារប្រជាជន ការពារដីរំដោះ ដោយអនុវត្តអាហ្នឹង ។ មិត្តត្រូវមើល “*អិចស្តេរវីយ៉ង់ អ៊ីស្ត្រីក ឌឺឡា ទីតាទារ ប្រូលុយតារីយ៉ា*” ។

ដូច្នេះ ដល់ក្រោយមកទៀតគេថា នែ៎! រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យជារដ្ឋាភិបាលពេញលក្ខណៈស្របច្បាប់របស់សហប្រជាជាតិដែលសហប្រជាជាតិទទួលស្គាល់ ។ ដូច្នេះ មិត្តឯងជាប៉ូលិស មិត្តឯងអត់មានទោសអីទេ ។ គេនិយាយអ៊ីចឹង ។ ក៏ប៉ុន្តែ ឥឡូវខ្ញុំអត់យករឿងអស់ហ្នឹងមកដោះស្រាយការពារខ្លួនទេ ។ ឱនកាយចំពោះមុខតុលាការកាត់ទោសខ្ញុំចុះ ។ ខ្ញុំខុសលើជាតិប្រជាជនខ្ញុំ វិនិច្ឆ័យខ្ញុំចុះ ។ កាលហ្នឹងយកពាក្យអស់ហ្នឹងមកគ្រាន់ជាល្បួងលោម បោកប្រាស់អារម្មណ៍ខ្លួនឯងប៉ុណ្ណោះ ។ នេះសូមបញ្ជាក់ ។

**ស៖** ខ្ញុំមិននិយាយអំពី អំពើរបស់លោកទេ ។ ខ្ញុំនិយាយអំពីអំពើទារុណកម្ម ដែលលោកឡើងថាមាននៅព្រៃស ហើយនិងពីការសម្លាប់មនុស្សនៅទីនោះ ។ ថាតើមែន ឬមិនមែន ? តើលោកមានអារម្មណ៍ថា អំពើទាំងនោះលោកគិតថាជាអំពើឧក្រិដ្ឋដែរឬទេ ?

**ឆ៖** ប្រហែលជាខ្ញុំយល់សំណួរលោកចៅក្រមមិនបានច្បាស់ទេ ។ ប៉ុន្តែ ឥឡូវខ្ញុំសូមសាកល្បងឆ្លើយ ។ ខ្ញុំយល់ថាសកម្មភាពដែលពួកប៉ូលិស គេធ្វើមកលើខ្មែរក្រហមជំនាន់នោះជាសកម្មភាពឧក្រិដ្ឋជាសកម្មភាពឧក្រិដ្ឋ ។ ដើម្បីលប់បំបាត់អាសកម្មភាពឧក្រិដ្ឋនេះទាល់តែខំធ្វើបដិវត្តន៍ ។ អានេះខ្ញុំគិតជំនាន់ហ្នឹង ។ ដូច្នេះ ទីមួយខ្ញុំសូមបញ្ជាក់ឡើងវិញ សកម្មភាពដែលប៉ូលិសរដ្ឋាភិបាលគេធ្វើមកលើខ្មែរក្រហម វាពិតជាសកម្មភាពឧក្រិដ្ឋ ។

[១១:៣៥:០០]

**ស៖** ទាក់ទងទៅនឹងលក្ខខណ្ឌនៃការឃុំខ្លួនរបស់លោកនោះ តើលោកអាចប្រាប់លោកបានទេថាតើលោកមានអ្វីបរិភោគគ្រប់គ្រាន់ទេ ប្រសិនជាលោក សមាជិកក្រុមគ្រួសារអាចមកលេងបានទេ? តើលោកមានលទ្ធភាពសរសេរអ្វីទេ? តើគេចាត់លោកថាជាមនុស្សធម្មតា ឬអមនុស្សធម៌? តើលោកអាចប្រាប់យើងបានទេអំពីលក្ខខណ្ឌឃុំខ្លួនរបស់លោក នៅពេលដែលលោកជាប់ឃុំខ្លួននៅសម័យនោះ?

**ឆ៖** ខ្ញុំបានជម្រាបលោកចៅក្រមហើយលក្ខខណ្ឌនៃការឃុំឃាំងខ្ញុំមានប្លែកគ្នា ។ នៅប៉ូលិសរបបហូបចុក គឺយករបបអ្នកទោសសាមញ្ញពីគុកធំយកទៅឲ្យខ្ញុំ ។ អន់ណាស់ ពិបាកហូប ។ ក៏ប៉ុន្តែប៉ូលិសអ្នកយាមខ្ញុំហ្នឹង គេឲ្យលុយមួយរៀល ហើយកាលនុំងយើងនៅប្រាំរៀលអីកើត ។ មួយរៀលៗម្នាក់អីទៅ ខ្ញុំទិញស្ករស ហើយនិងអំបិលយកទៅប៉ះប៉ូវសម្រាប់ហូប ។ គេឲ្យយើងខ្ញុំដេកពូកមែន

ក៏ប៉ុន្តែពួកនោះប្រឡាក់ ។ នឹកឃើញពេលណា វាដូចជាស្អុត ។

មកដល់ស្រះចក របបអាហាររបស់គេគួរសម ។ មកដល់ព្រៃសរបបអាហារក៏គួរសមដែរ ក៏ប៉ុន្តែនិយាយអំពីការលួចរបបហ្នឹងក៏ខ្លាំងណាស់ដែរ ។ ហ៊ឺ! ម្នាក់ៗបានធ្វើចាងហ្វាងគុក គេលួចរបបច្រើនណាស់ ។ នេះនិយាយពីរបបហូបចុក ។

ពេលមកដល់គុកធំ បានៗសាមគ្គីភាពរបស់អ្នកនយោបាយនៅគុកធំបង្ខំឲ្យរាជការគុកនៅជំនាន់នោះអនុវត្តក្រម១៣ ។ អ្នកចូលគុកមានរបបគេច្បាស់លាស់ អ្នកជាប់គុកនយោបាយមានរបបគេច្បាស់លាស់ ។ អត់មានអ្នកណាប៉ានរំលោភទេ ។ ដូច្នេះ ដែលគេអនុវត្តច្បាប់ឃុំឃាំងបានត្រឹមត្រូវតាមក្រម ១៣ ដែលសល់តាំងពីសម័យអាណានិគមនិយមបារាំងមកគឺនៅគុកធំ ក្រៅពីនោះសុទ្ធតែមានការរំលោភ ។

ឯចំណែកការចូលសួរសុខទុក្ខអំពីគ្រួសារ យើងខ្ញុំរស់នៅជាប់គុកប៉ូលិស ម្តាយខ្ញុំចូលមិនបាន ។ មកដល់ប៉េអ៊ឹមចូលមិនបានទៀត ។ មកដល់ព្រៃសចូលបាន ។ ម្តាយខ្ញុំគាត់អញ្ជើញចូលមក ។ បងប្អូនមិត្តភក្តិ ក្រុមគ្រួសារអ្នកផ្សេងទៀតចូលមក គេឲ្យមករាល់អាទិត្យ ។ ក្នុងមួយអាទិត្យគេឲ្យមកថ្ងៃព្រហស្បតិ៍ ។ មកដល់យើងខ្ញុំផ្ទេរមកដល់គុកធំ របបហូបចុកក៏ធូរធារ ពេទ្យក៏មានប្រចាំមានថ្នាំមានអីក៏សមរម្យ ហើយគ្រួសារចង់មកថ្ងៃណាក៏បានដែរ មកសុំច្បាប់គេ បង់មួយពេលហ្នឹង ម្តង៣០រៀល ។

នេះអំពីលក្ខខណ្ឌនៃការឃុំខ្លួនដែលប្តែកគ្នាពីកន្លែងមួយទៅកន្លែងមួយ ។ ខ្ញុំសូមរាយការណ៍ជូនប៉ុណ្ណេះ ។

**ស៖** លោកនៅថ្ងៃទី៣ មករា ឆ្នាំ១៩៧០ គេបានដោះលែងលោក ថាតើមានសមាជិកក្រុមគ្រួសារលោកបានធ្វើអន្តរាគមន៍ដើម្បីឲ្យគេដោះលែង ឬក៏បានជួយអ្វីក្នុងការដោះលែងនោះទេ?

**ឆ៖** ខ្ញុំសូមនិយាយតែអំពីរឿងនយោបាយរបស់ឧត្តមសេនីយ៍ លន់ នល់ ។ ក្រោយធ្វើរដ្ឋប្រហារគាត់ធ្វើនយោបាយ ដូចខ្ញុំបានរាយការណ៍ជម្រាបលោកចៅក្រមរួចហើយ ។ គាត់ដោះលែងអ្នកទោសនយោបាយទាំងអស់ ទាំងខ្មែរក្រហម ទាំងខ្មែរសេរី ទាំងយួន យៀកកុង យៀកមិញ ទាំងយួនយៀកកុងហើយនិងទាំងយួនរដ្ឋការព្រៃនគរ ដើម្បីអួតប្រាប់សាកលលោកថា នរោត្តម សីហនុ ឃោរឃៅ គាត់ត្រឹមត្រូវ គាត់មិនចេះតែដើរចោទគេ ហើយចាប់ដាក់គុក ដោយចោទថា ខៀវ-ក្រហម ទេ ។ ដូច្នេះ នេះគឺជាបរិបទនយោបាយ ដែលខ្ញុំសូមរាយការណ៍ជូនលោកចៅក្រម ។

**ស៖** ខ្ញុំគិតថា លោកមិនបានឆ្លើយសំណួរខ្ញុំត្រឹមត្រូវទេ ។ ខ្ញុំសួរម្តងទៀត ។

តើសមាជិកក្រុមគ្រួសាររបស់លោកបានធ្វើអន្តរាគមន៍អ្វី ដើម្បីឲ្យគេដោះខ្លួនលោកមុនគេ ឬធ្វើអ្វីខ្លះដើម្បីឲ្យគេដោះខ្លួនលោកនោះ?

**ឆ៖** ខ្ញុំសូមនិយាយជូនលោកចៅក្រម ខ្ញុំសូមនិយាយជូនលោកចៅក្រមទៅចុះ ។ ខ្ញុំកាត់ទោសរួចហើយ គេកាត់ទោសខ្ញុំរួចហើយ ។ គេកាត់ទោសរូបខ្ញុំរួចហើយ ម្តាយខ្ញុំគាត់រត់ទៅប្អូនជីទួតមួយគាត់ ។ ប្អូនជីទួតមួយគាត់នេះជាក្មួយប្រសាររបស់ លន់ នល់ ។ ជាក្មួយប្រសាររបស់ លន់ នល់ មិនមែនជាម្តាយមីងខ្ញុំ គាត់កូនអ្នកណាទេ ។ វរ១កូន តាណុន ហ្នឹងហើយផងមិនក៏មិនដឹង ។

នៅពេលដែលម្តាយមីងខ្ញុំគាត់ទៅជួប ។ ខ្ញុំអាណិតម្តាយមីងដែរ ដែលខ្ញុំមិនបានទៅជម្រាបសួរសុខទុក្ខគាត់សោះ ហើយគាត់រត់ទៅជួបឪពុកធំគាត់ដើម្បីឲ្យខ្ញុំបានរួច ។ ហើយតាមពិត លន់ នល់ គេសុខចិត្តដោះលែងខ្ញុំ ឲ្យតែខ្ញុំស៊ីញ៉េញត្តិមួយទៅសុំទោស តែខ្ញុំមិនព្រមស៊ីញ៉េ ព្រោះខ្ញុំដឹង ។ ខ្ញុំជឿជាក់ថា លន់ នល់ ចាញ់ ។ តែគុណឪពុកខ្ញុំ ម្តាយមីងខ្ញុំ ខ្ញុំមិនភ្លេចទេ ។ ខ្ញុំជឿជាក់ថា លន់ នល់ មិនអោតរហូតដល់ឲ្យខ្មែរក្រហមនៅចាប់បានទេ ។ គេខ្មាំងសត្រូវនឹងខ្ញុំនិងជាតិក៏ដោយ ក៏គុណគេចំពោះខ្ញុំ គេសុខចិត្តដោះលែងខ្ញុំ វាជាគុណគេម៉្យាងហើយ ។ ឪពុកមាខ្ញុំ ម្តាយមីងខ្ញុំ ខ្ញុំមិនភ្លេចទេ ខ្ញុំគិតថា កាលណាបដិវត្តន៍បានរំដោះខ្ញុំក្នុងឋានៈជាបក្សជនកុម្មុយនីស្តកម្ពុជា ក៏អាចជួយគាត់ឲ្យរួចផុតពីគ្រោះថ្នាក់សងគាត់វិញដែរ ។ ដូច្នេះ យើងចែកផ្លូវគ្នាដើរ ។ មួយឈ្នះ យើងអ្នកចាញ់ ។ ខ្ញុំគិតអ៊ិចឹង ។ ក៏ប៉ុន្តែ១៧ មេសា ខ្មេចៗ គ្រួសារខ្ញុំនៅសៀមរាបនៅសល់តែម្នាក់គត់ ។ ឥឡូវនេះ នៅសល់តែម្នាក់ទេ គ្រួសារខ្ញុំនៅកំពង់ឃ្លាំងអស់ជាងពាក់កណ្តាល ។ នេះដែលខ្ញុំមានការចុកចាប់ជាមួយនឹងបក្សកុម្មុយនីស្តកម្ពុជាដែលខ្ញុំស្រឡាញ់ហើយវាធ្លាក់មកដល់បែបនេះ ។ សូមសរុបមកវិញប៉ុណ្ណេះ ។

**ស៖** អន្តរាគមន៍នេះ តើគេបានជូនដំណឹងស្របទៅតាមប្រវត្តិផ្ទាល់ខ្លួនរបស់លោក? តើគាត់បានដឹងពីប្រវត្តិរបស់លោកថា ជាសមាជិកបក្សកុម្មុនីស្តកម្ពុជាទេ ?

**ឆ៖** ប្រវត្តិរូបនេះ ខ្ញុំមិនដែលនិយាយប្រាប់បក្សកុម្មុយនីស្តកម្ពុជាទេ ។ ពេលនោះ ខ្ញុំបានដោះស្រាយជាមួយនឹងម្តាយខ្ញុំយ៉ាងនេះ ។ ខ្ញុំថា ម៉ែ ខ្ញុំកំពុងតែតោងមែកឈើខ្មែរក្រហម ខ្ញុំបោះមែកឈើខ្មែរក្រហមចោល ខ្ញុំទៅតោងមែកឈើ តានល់ ។ សួរថាតើតានល់ គាត់ទុកចិត្តឬទេ? ហើយខ្ញុំបោះមែកឈើខ្មែរក្រហមទៅ តើខ្មែរក្រហមគេទុកចិត្តឬទេ?

ខ្ញុំថាអ៊ូ! ខ្មែរក្រហមក៏មិនទុកចិត្ត តានល់ ក៏គាត់មិនទុកចិត្តងាប់ទទេ អត់អំបិលប្រឡាក់ ។ ម៉្លោះហើយម៉ែអើយ! កូនសុំនៅនេះចុះ ។ ម្តាយខ្ញុំគាត់សួរខ្ញុំ ។ គាត់ថា កូនឯងសុខចិត្តនៅម្តេឆ្នាំហ្នឹងអី ?

ខ្ញុំថាអត់ទេម៉ែ ។ កងទ័ពខ្ញុំនៅពេញព្រៃប្រាំឆ្នាំទៀតគេមករំដោះខ្ញុំហើយ ។ នេះឆ្នាំ១៩៦៩ ខ្ញុំនិយាយអ៊ីចឹង ជម្រាបម្តាយខ្ញុំ ។

ដូច្នេះ សរុបមកសូមជម្រាបជាតិប្រជាជនកម្ពុជា តាមសំណួររបស់លោកចៅក្រម គឺថាខ្ញុំអត់មានឲ្យរឿងហ្នឹងដឹងដល់បក្សកុម្មុយនីស្តកម្ពុជាទេ ប្រវត្តិខ្ញុំដែលមានអន្តរាគមន៍ពីម្តាយខ្ញុំ ។ អត់ទេ អត់ដឹងសោះ ។ ប៉ុន្តែសាក្សីម្តាយខ្ញុំគាត់នៅរស់នៅ នៅឡើយទេ ។

**ស៖** ចំពោះលោកផ្ទាល់ ដែលលោកនិយាយដោយផ្ទាល់ខ្លួននោះថា តើអាចទៅរួចទេដែលថាក្នុងការលាក់នូវផ្នែកខ្លះនូវសមាជិកក្រុមគ្រួសារដើម្បីលាក់លៀមពីបក្សកុម្មុនីស្តកម្ពុជា? ថាតើអាចលាក់បានទេ? តើលោកបានស្បថទេ ដើម្បីឲ្យស្មោះត្រង់ចំពោះបក្សកុម្មុយនីស្តកម្ពុជាកាលនោះ?

**ឆ៖** កាលដែលខ្ញុំលើកដៃសច្ចាប្រណិធានជាមួយនឹងមុខបក្ស គឺពិត ។ ខ្ញុំអត់ក្បត់គេទេ ។ ក៏ប៉ុន្តែរឿងនេះវាជារឿងផ្ទាល់ខ្លួនដែលខ្ញុំសម្រេចរួចទៅហើយ មិនក្បត់គេទៅចូលខ្មាំង ។ ដល់ថ្ងៃក្រោមមកបែកការណ៍ទៅដល់គេក៏មិនអី ព្រោះខ្ញុំអត់បានក្បត់គេ ទៅចូលជាមួយនឹង តានល់ ។ទោះបីជាប់ជាបងប្អូនជាអីក៏ដោយ ខ្ញុំអត់ក្បត់គេទៅចូល លន់ នល់ ទេ ។ ខ្ញុំអត់បោះបង់ជួរទេ ។ ដូច្នេះខ្ញុំទោះបីជាបែកការណ៍គេ ថ្ងៃក្រោយក៏ខ្ញុំអត់មានបញ្ហា ខ្ញុំច្បាស់អ៊ីចឹង ។ ពិត ។ ខ្ញុំបានជជែកអង្វរកម្តាយខ្ញុំ ខ្ញុំអត់ប៉ានតមាត់ជាមួយម្តាយខ្ញុំទេ អ្នកមានគុណ ។ តែងអង្វរកគាត់អ៊ិចឹង ។

សរុបមក សកម្មភាពនេះមិនមែនជាសកម្មភាពក្បត់បក្សទេ ។ ខ្ញុំពិតជាបានសច្ចាប្រណិធានចំពោះទង់បក្សថា ស្មោះត្រង់នឹងបក្ស ក៏ប៉ុន្តែខ្ញុំអត់បានក្បត់បក្សខ្ញុំទេ ។

**ស៖** តើនៅក្នុងខណៈពេលនោះ នៅពេលដែលលោកស្បថនោះ តើលោកបានប្តូរឈ្មោះនៅពេលហ្នឹងទេ ?

**ឆ៖** ឈ្មោះបដិវត្តន៍ជាឈ្មោះដែលគេឲ្យខ្ញុំរើសតាំងពីនៅរៀនវគ្គសម្ងាត់នៅឆ្នាំ១៩៦៧ ។ នៅផ្ទះមួយដែលខ្ញុំជួលនៅផ្លូវលេខ១៦៣ ខាងលិចហើយនិងខាងត្បូងផ្សារទួលទំពូង ។ ឲ្យតែចូលធ្វើបដិវត្តន៍គេឲ្យរើសឈ្មោះមួយទៀត ឈ្មោះបដិវត្តន៍ គេហៅថាឈ្មោះបដិវត្តន៍ ។

**ស៖** តើឈ្មោះនេះត្រូវមានន័យអ្វីជាក់លាក់ដែរឬទេ?

[០៩:៤៨:៣១]

**ឆ៖** ឈ្មោះនេះ បើនិយាយពីន័យ ជាឈ្មោះដែលប្រជាជនខ្មែរធ្លាប់ប្រើ មិនមានន័យអីទេ ។ ក៏ប៉ុន្តែសម្រាប់ខ្ញុំ ដែលខ្ញុំជ្រើសរើសឈ្មោះនេះ ព្រោះខ្ញុំស្រឡាញ់ឈ្មោះនេះ ។ នៅពេលដែលខ្ញុំនៅ

ពីតូចខ្មោចជីតាខ្ញុំខាងម្តាយ គាត់លើកសរសើរជាងចម្លាក់ម្នាក់ឈ្មោះ ឌុច ដែលទៅកសាងព្រះបដិមាករ អង្គធំនៅវត្តពៅវើយ វត្តកំណើតខ្ញុំ ។ គាត់ថា អ៊ូ! ជាងឌុច ពូកែណាស់ ឆ្លាក់ល្អណាស់ ។ ខ្ញុំឮខ្មោច ជីតាខ្ញុំគាត់សរសើរពីរ-បីដងដែរ ពីរឿងខ្មោចលោកតាជាង ឌុច ។ ខ្ញុំក៏ចាំឈ្មោះនេះទុក ។

ដល់មកខ្ញុំរៀនដល់ថ្នាក់កុមារដ្ឋាន បារាំងគេហៅថា *កួរអង់ហ្វង់តាំង* ។ មានសៀវភៅមួយគេ សរសេរថា គ្រូឲ្យ ឌុច អានសៀវភៅ គេគូសរូប ។ ឌុច ងើបឡើងឈរត្រង់ខ្លួនក្បាលមិនងឹកងោក ។ អានមួយៗថាច្បាស់ៗ ។ សៀវភៅអត្ថបទហ្នឹងនៅមុនគេបំផុត ។ ដូច្នេះ ខ្ញុំចាប់អារម្មណ៍ហ៎ ឈ្មោះ ឌុច ហ្នឹង ដូចល្អហើយខ្មែរប្រើឈ្មោះហ្នឹង ។ ដល់បង ឆាយ គឹមហ៊ នេះហៅ ហុក នេះថាមិត្តជ្រើស រើសឈ្មោះបដិវត្តន៍មួយទៅ ។ ខ្ញុំថាអ៊ីចឹងយកឈ្មោះ ឌុច ព្រោះខ្ញុំដឹងខ្លួនថា ឈ្មោះ កាំង ហ្កេកអ៊ាវ នេះជាឈ្មោះចិន ដូច្នេះខ្ញុំធ្វើបដិវត្តន៍ខ្មែរ វាត្រូវតែប្រើឈ្មោះខ្មែរ ។ អ៊ីចឹងចំពោះឈ្មោះ ឌុច នេះមានគឺ ន័យត្រឹមប៉ុណ្ណឹងឯង គឺជាឈ្មោះដែលខ្ញុំស្រលាញ់។ ខ្ញុំគោរពដល់លោកតាជាង ឌុច ហើយក៏ខ្ញុំជឿជាក់ថា កុមារ ឌុច ដែលមាននៅក្នុងសៀវភៅកុមារដ្ឋានល្អ ។

**ស៖** អ៊ីចឹង យោងទៅរកអ្វីដែលលោកលើកឡើងនោះ គឺថាឈ្មោះកូនសិស្សមួយដែលជាពិសេស ដែល ជាអ្នកគោរពតាមគ្រូ ដែលជាអ្នកឆ្លើយសំណួរអ្វីដែលនឹងសួរ ហើយត្រៀមខ្លួនដើម្បីរៀនសូត្រ ឧស្សាហ៍ អ៊ីចឹងតាមន័យហ្នឹង ឬដូចម្តេច? ហ្នឹងជាការយោងទៅរកឈ្មោះដែលលោកប្រើបែបហ្នឹងឬ?

**ឆ៖** លោកចៅក្រមមានប្រសាសន៍ហ្នឹងត្រូវហើយ ។ ខ្ញុំស្រលាញ់ឈ្មោះ ឌុច នេះព្រោះខ្ញុំក៏ចង់ ធ្វើខ្លួនឲ្យទៅជាក្មេងមានសណ្តាប់ធ្នាប់ម្នាក់ ក្មេងចេះកោតខ្លាចគ្រូម្នាក់ ក្មេងដែលរង់ចាំបំពេញការងារអី ដែលល្អ ។

**ស៖** ប្រសិនបើយើងត្រឡប់ទៅក្រោយបន្តិចទៅរកមូលហេតុ ដែលលោកបានលើកឡើងអំពី ដែលលោកធ្វើការប្តេជ្ញាចិត្តចូលទៅក្នុងបដិវត្តន៍នោះ ដែលថាលោកបានប្រាប់យើងនៅក្នុងការស៊ើប អង្កេត ។ ហើយលោកបានស្វែងរកនូវយុត្តិធម៌ ហើយលោកចង់ការពារប្រជាជន ហើយចង់រំដោះប្រជា ជនដែល លោកចាត់ទុកថាទទួលរងការកៀបសង្កត់ពីរបបមុននោះ ។ ឥឡូវនេះ ពេលនោះលោកក៏ បាននិយាយ ដែរថា លោកបានចូលទៅក្នុងរបបខ្មែរក្រហម លោកចង់រំដោះប្រជាជនហើយមិនមែន ដើម្បីប្រព្រឹត្តបទឧក្រិដ្ឋនោះទេ ។ តើលោកអាចបញ្ជាក់ពីគំនិតនេះបានដែរឬទេ?

[០៩:៥២:៤៨]

**ឆ៖** ខ្ញុំទទួលស្គាល់ថា ខ្ញុំបានធ្វើការប្តេជ្ញាចិត្ត រំដោះជាតិ រំដោះប្រជាជនខ្ញុំ ឲ្យរួចផុតពីការជិះ

ជាន់នានា ។ ខ្ញុំគ្មានបំណងនឹងធ្វើបទឧក្រិដ្ឋទៅលើជាតិប្រជាជនខ្ញុំទេ ។ នេះជាការប្តេជ្ញាចិត្ត ជាសេចក្តីប្តេជ្ញាចិត្ត ឬក៏និយាយថា ជាសម្បថក៏បានដែរ ចំពោះជាតិប្រជាជន ។

**ស៖** លោកក៏បាននិយាយថា ពីការលះបង់ខ្លួន ហើយលោកមានចេតនាដើម្បីលះបង់ដើម្បីបដិវត្តន៍ ។ ពេលនោះហើយតើលោកមានគំនិតអ្វីទេ ថាអំពីការធ្វើពលិកម្មដែលលោកនឹងត្រូវធ្វើសម្រាប់បដិវត្តន៍នោះ ?

**ឆ៖** ខ្ញុំនិយាយពីពលិកម្ម ខ្ញុំធ្វើពលិកម្មលុយកាក់ជូនចំពោះបដិវត្តន៍ ធ្វើសកម្មភាពបដិវត្តន៍ ហើយខំៗ ជ្រមុជក្បាលធ្វើបដិវត្តន៍ ។ មិនខ្លាចគុក មិនខ្លាចទៅឆ្ងាយឪពុកម្តាយ ហើយក៏មិនខ្លាចសេចក្តីស្លាប់ ។ សូមជម្រាបលោកចៅក្រមថា ការកាត់ទោសរបស់ខ្ញុំៗ គឺនៅក្នុងខែមិថុនាៗ ១៩៦៩ ។ នៅក្នុងខែមីនា ឆ្នាំ១៩៦៩ ខ្ញុំគិត “ហ៊ឺ! បើតុលាការគេកាត់ទោសខ្ញុំប្រហារជីវិតបង់ដូច ព្រាប អិន” ។ ខ្ញុំគិតក្នុងចិត្តថា បើតុលាការគេកាត់ទោសអញ ប្រហារជីវិតបង់ដូច ព្រាប អិន ។ ឈ្មោះ ព្រាប អិន ហ្នឹង ជាខ្មែរសេរីម្នាក់ដែល នរោត្តម សីហនុ គាត់យកទៅបាញ់ចោល ។ សូមបញ្ជាក់ថា ព្រាប អិន ជាកម្មាភិបាលរបស់ខ្មែរសេរីម្នាក់ ដែលនរោត្តម សីហនុ យកទៅបាញ់ចោល ។

ខ្ញុំគិតថា បើសិនជាគេកាត់ទោសខ្ញុំយកទៅបាញ់ចោលដូច ព្រាប អិន ។ តើខ្ញុំត្រូវធ្វើម៉េច? ខ្ញុំគិតថា ខ្ញុំលើកដៃស្រែក ។ ជយោ! បក្សកុម្មុយនីស្តកម្ពុជា ។ ខ្ញុំគិតហើយ ខ្ញុំគិតតទៅទៀតថា តិចចុះបើគេកាត់ទោសប្រហារជីវិត ហើយគេមិនយកទៅប្រហារជីវិតភ្លាមៗ ។ តើខ្ញុំត្រូវធ្វើម៉េច? អើសទ្រាំជាប់គុកមួយជីវិតហ្នឹងទៅ ។ ដូច្នេះ ស្មារតីត្រៀមធ្វើពលិកម្មមានរហូត មានជាប់ជាប្រចាំក្នុងខ្លួន ទោះបីពលិកម្មបែបណាក៏ដោយក៏មិនរាថយដែរ ។

**ស៖** អ៊ីចឹង លោកបានត្រៀមខ្លួនជាស្រេចដើម្បីធ្វើពលិកម្មជីវិតរបស់លោកក្នុងមូលហេតុដើម្បីចលនាបដិវត្តន៍ ។ ខ្ញុំមិនដឹងថា តើពលិកម្មនេះវាមានន័យដូចម្តេច? ថាតើលោកបានគិតទេថាការពលិកម្មរបស់ លោកអាចនឹងពាក់ព័ន្ធទៅនឹងការកាប់សម្លាប់ដើម្បីបដិវត្តន៍នោះ ?

[១១:៥៨:៤៤]

**ឆ៖** ខ្ញុំគិតថា ការធ្វើបដិវត្តន៍នេះ របស់ដែលខ្ញុំស្រលាញ់បំផុត គឺធ្វើគ្រូបង្រៀន ។ ខ្ញុំសង្ឃឹមថាដល់បដិវត្តន៍ឈ្នះគេមិនចោលខ្ញុំទេ ។ គេឲ្យខ្ញុំធ្វើគ្រូ ព្រោះខ្ញុំក៏វាមាន-- នេះជាគំនិតរបស់ខ្ញុំ ។ ខ្ញុំគ្មានដឹងថា គេរុញខ្ញុំឲ្យចូលអាចង្គតល្បួងអ៊ីចឹងទេ ។

**ស៖** នៅក្នុងការយល់ឃើញរបស់លោក ថាតើបក្សកុម្មុយនីស្តកម្ពុជា ថាតើគាត់រកឃើញ

ពិសេសអ្វី អំពីលោកក្នុងការជ្រើសរើសលោកជាប្រធានមន្ទីរសន្តិសុខ ? ថាតើគុណសម្បត្តិ និងលក្ខណៈយ៉ាងម៉េច ដែលបក្សកុម្មុយនីស្តកម្ពុជាបានកំណត់រើសលើរូបលោក ?

**ជនជាប់ចោទ៖**

**ឆ៖** គុណធម៌ដែលគេត្រូវការ សំខាន់មែនទែនគឺការស្មោះត្រង់ចំពោះបក្ស ។ ក្នុងមួយជីវិតខ្ញុំមេខ្ញុំ ស្គាល់ខ្ញុំច្បាស់ណាស់ លោកគ្រូ សុន សេន បង ឆាយ គឹមហ៊ា ហើយក្រោយមក បងវន (វន វ៉េត) ។ សុទ្ធ តែស្គាល់ខ្ញុំថា ត្រង់នឹងគេអត់ប៉ិានលាក់។ នេះជាគុណធម៌ដែលបក្សកុម្មុយនីស្តកម្ពុជាត្រូវការពីបក្ខជនរបស់ខ្លួនគ្រប់រូបគឺហ្នឹង ។

ហើយគុណធម៌មួយទៀតដែលសំខាន់ដែរ គឺធ្វើការងារអីក៏ដោយត្រូវតែយកចិត្តទុកដាក់ទទួលខុសត្រូវចំពោះការងារនោះដោយហ្មត់ចត់ ។ ខ្ញុំមួយជីវិតខ្ញុំបើថាមិនធ្វើគឺមិនធ្វើ បើថាធ្វើ គឺធ្វើយកហ្មត់ចត់ យកល្អ ។

[១២:០១:៤២]

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដល់ម៉ោងដប់ពីរហើយ គឺត្រូវសម្រាកពិសារអាហារថ្ងៃត្រង់។ អង្គជំនុំជម្រះសូមប្រកាសផ្អាកសវនាការដើម្បីពិសារអាហារថ្ងៃត្រង់ ហើយរហូតដល់ម៉ោងមួយនិងសាមសិបនាទីរសៀល ។

អង្គជំនុំជម្រះ បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទត្រឡប់ទៅកាន់បន្ទប់រង់ចាំ និងបង្គាប់ឲ្យនាំគាត់ត្រឡប់មកវិញនៅវេលាមុនម៉ោងមួយនិងសាមសិបនាទីរសៀលនេះ ។ ហើយសូមជម្រាបដល់អ្នកចូលរួម និងសាធារណជនសូមអញ្ជើញចូលមកវិញនៅថ្ងៃនេះឲ្យបានមុនម៉ោងមួយនិងសាមសិបនាទី ។

*[សវនាការសម្រាកពីម៉ោង ១២:០៣នាទី ដល់ម៉ោង ១៣:៣៦នាទី]*

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការតទៅទៀត ។

នៅព្រឹកមិញ ដំណើរការនីតិវិធីពាក់ព័ន្ធជាមួយនឹងអង្គហេតុម-១៣ ហើយបានដំណើរការដល់

ទៅនៅក្នុងកិច្ចដំណើរការនៃការសួរជនជាប់ចោទ ។ ឥឡូវនេះ គឺដោយអង្គជំនុំជម្រះ ឥឡូវនេះយើងមុននឹងបន្តទៀត ដោយដំបូងនេះបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទមកកាន់ឈើរាងក្រចកសេះដែលបម្រុងទុកសម្រាប់ជនជាប់ចោទ ។

បាទ, អនុញ្ញាតឲ្យជនជាប់ចោទអង្គុយចុះ ។

លោកចៅក្រម ហ្សង់ម៉ាក ពីព្រឹកមិញ គឺដំណើរការប្រព្រឹត្តទៅលោកបានតាំងសំណួរដល់ជនជាប់ចោទ ហើយជាកិច្ចបន្តនេះ តើលោកនៅមានសំណួរអ្វីត្រូវសួរដោយជនជាប់ចោទទៀតទេ? បើមានសូមអញ្ជើញ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំសូមធ្វើការបន្តការសួរសំណួរជនជាប់ចោទបន្តទៀត ។ ប៉ុន្តែ ជាបឋមខ្ញុំគិតថា ដើម្បីរដ្ឋបាលនៃយុត្តិធម៌ ភាគីគួរតែត្រូវបានទទួលបញ្ជីសាក្សី ដែលកោះហៅចូលខ្លួនមកតុលាការ ដោយយើងរំពឹកថា សាក្សីទាំងអស់នេះ មិនទាន់ចូលមកទេ ចូលមកបង្ហាញខ្លួនទេ ។ ដូច្នេះឈ្មោះទាំងអស់ត្រូវតែលាក់ការសម្ងាត់ ។ ដូច្នេះ ដើម្បីជៀសវាងភាពលំបាកផ្សេងៗ យើងនឹងប្រើប្រាស់រហស្សនាម ហើយយើងនឹងមាន បញ្ជីដែលមានកូឡោនមួយ មានឈ្មោះ កូឡោនទីមួយ គឺមានឈ្មោះសាក្សី និងកូឡោនទីពីរ គឺរហស្សនាម ហើយខ្ញុំសូមរំឭកឡើងវិញថា នេះជាព័ត៌មានសម្ងាត់ យើងផ្តល់ជូនឲ្យជនជាប់ចោទ និងមេធាវី ការពារក្តីសហព្រះរាជអាជ្ញា និងភាគីផ្សេងៗ ។

លោកប្រធាន ខ្ញុំចង់សួរថាតើសមរម្យដែលឬទេ ចំពោះការដែលខ្ញុំលើកឡើងទាំងអស់នេះ?

**ប្រធានអង្គជំនុំ៖**

ជាការត្រឹមត្រូវហើយ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំសូមបន្ថែមថា យើងមានតែបញ្ជីហ្នឹងជាភាសាអង់គ្លេសតែប៉ុណ្ណោះក្នុងលក្ខណៈជាក់ស្តែង យើងនឹងមានបញ្ជីភាសាខ្មែរនឹងចែកជូនទៅតាមហ្នឹង ។

**ស៖** ដូច្នេះ យើងអាចបន្តទៀតចំពោះនីតិវិធីរបស់យើងព្រឹកនេះ ព្រឹកមិញនេះជនជាប់ចោទត្រូវបានចែករំលែក គឺឲ្យគាត់ធ្វើការដឹកនាំមន្ទីរម-១៣ ហើយគាត់បានលើកឡើងថា ដោយសារតែគាត់មាន ភាពស្មោះត្រង់នឹងបក្ស ហើយនឹងភាពវៃឆ្លាត ថាតើជនជាប់ចោទចង់បន្ថែមអ្វីផ្សេងទៀតទៅលើចំណុចទាំងនេះ? ដូចដែលលោកជនជាប់ចោទ បានលើកឡើងចំពោះប្រធានបទមួយនេះ ។

[១៣:៤១:២១]

**ជនជាប់ចោទ៖**

**ឆ៖** ខ្ញុំមិនទាន់គិតថា ចម្លើយរបស់ខ្ញុំពេញលេញនៅឡើយទេ ។ ប៉ុន្តែ នៅចំពោះមុខនេះ ក៏ប៉ុន្តែ នៅចំពោះ មុខនេះ ខ្ញុំរកគិតគុណភាពអី ដែលខ្ញុំត្រូវជម្រាបជូនលោកចៅក្រម មិនទាន់ឃើញទេ ។ ដូច្នេះសំណួរ ដែល-- ។ ដូច្នេះ--

**ស៖** នៅពេលដែលលោកចេញពីការឃុំខ្លួន ថាតើលោកត្រឡប់ទៅគ្រួសាររបស់លោកវិញ ឬក៏លោក វិលចូលព្រៃ?

**ឆ៖** ខ្ពីពេក ខ្ញុំសូមបញ្ជាក់ព្រឹកមិញ ខ្ញុំឆ្លើយខ្ពីពេក ។ ថ្ងៃ៣ខ្ញុំទៅដល់ផ្ទះពេលក៏យប់ ទៅដល់ពេល យប់ហើយ ។ ខ្ញុំនៅផ្ទះ៣អាទិត្យៗ ។ ហើយបានខ្ញុំមកនៅភ្នំពេញ ដេកនៅកុដិលេខ៣របស់ខ្ញុំវិញ ។ ថ្ងៃខ្ញុំធ្វើសកម្មភាពបដិវត្តន៍ៗ យប់ខ្ញុំស្នាក់នៅហ្នឹងវត្តខ្ញុំហ្នឹង រហូតដល់ខែសីហាបានខ្ញុំ-- ខ្ញុំធ្វើសកម្មភាព បដិវត្តន៍របៀបនេះរហូតដល់ខែសីហា ។ ចុងខែសីហា ខ្ញុំបានអនុញ្ញាតឲ្យទៅតំបន់រំដោះ ខ្ញុំអនុញ្ញាតឲ្យ ទៅតំបន់រំដោះ គឺទៅខាងស្អាង កោះធំ ទៅធ្វើសកម្មភាពបដិវត្តន៍នៅទីនោះ ស្រុកខេត្តកណ្តាល ។ សូមបញ្ជាក់ថា ស្អាង កោះធំនេះនៅខេត្តកណ្តាល *ណុងដង់លើប្រូវាំង (Non dance le province)* ។

**ស៖** លោកបានលើកឡើងថា លោកនៅកុដិរបស់លោកសង្ឃ ថាតើលោកមានជំនឿជាក់លាក់ ណា មួយដែលឬទេទៅលើបញ្ហាហ្នឹង?

**ឆ៖** ឆ្នាំ១៩៦២ តែមិនចាំច្បាស់-- ជម្រាបព្រឹកមិញវាមិនច្បាស់ ។ ពីឆ្នាំ១៩៦២ ខ្ញុំស្នាក់នៅកុដិ លេខ៣ វត្តឧណ្ណាលោមនេះ ។ ខ្ញុំនៅស្នាក់កុដិលេខ៣នេះ តាំងពី៦២ រហូតគ្រូមេកុដិ ដែលខ្ញុំគោរព ហើយនិងស្រឡាញ់នេះ ឈ្មោះ ប្រាជ្ញ ប៉ុល, ព្រះនាម ប្រាជ្ញ ប៉ុល ។ លោកគ្រូនៅកុដិខ្ញុំនេះ ជាមន្ត្រីសង្ឃ ថ្នាក់ខ្ពស់ណាស់ ថ្នាក់ខ្ពស់ដែរ ដែលខ្ញុំស្រឡាញ់ ហើយដែលលោកដឹងថា ខ្ញុំធ្វើនយោបាយលោករកវ៉ៃ ខ្ញុំ ។ ពេលណាដែលលោកដឹងថា ខ្ញុំធ្វើនយោបាយលោករកវ៉ៃខ្ញុំ ខ្ញុំបានពុះពារ ថ្វាយបង្គំលោក ទូលលោក អំពីការពិត ដល់ក្រោយមកខ្ញុំបានទទួលការជឿទុកចិត្ត ។

ព្រឹកមិញ ខ្ញុំបានជម្រាបលោកចៅក្រមបន្តិចពីរឿងហ្នឹង ប៉ុន្តែឥឡូវ ខ្ញុំបញ្ជាក់មានការទាក់ទងនឹង កុដិលេខ៣នេះជ្រៅណាស់ ។ ការមនោសញ្ចេតនារបស់ខ្ញុំនៅក្នុងកុដិលេខ៣នេះជ្រៅណាស់ ជ្រាលជ្រៅ មែនទែន ខ្ញុំស្រឡាញ់គ្រូខ្ញុំប្រហែលឪពុកខ្ញុំ ។

[១៣:៤៧:០៧]

**ស៖** លោកមានអារម្មណ៍គោរពទៅលើលោកសង្ឃនេះ ដោយសារតែលោកមានជំនឿ ហើយនិងមានការចាប់អារម្មណ៍ទៅលើសាសនាព្រះពុទ្ធ ?

**ឆ៖** បើសាសនាវិញ ខ្ញុំសូមជម្រាបលោកចៅក្រមថា ជីតាខ្ញុំខាងម្តាយ ជាអ្នកចេះដឹងខាងទ្រឹស្តីព្រះពុទ្ធសាសនា ។ ដូច្នេះ ខ្ញុំទទួលឥទ្ធិពលហ្នឹង ទ្រឹស្តីព្រះពុទ្ធសាសនាខ្ញុំចេះច្រើន ។

**ស៖** នៅក្នុងការយល់ឃើញរបស់លោក ខ្ញុំជឿថាមាន៩ និង១០ខែ លោករស់នៅក្នុងជីវភាពកុដិនេះ ថាតើអ្វីទៅជាគោលការណ៍ចំពោះសាសនា ឬជំនឿនេះ ?

**ឆ៖** សីល១០របស់ព្រះពុទ្ធសាសនា ឈរលើ(ខ)មួយសំខាន់ គឺសម្លាប់សត្វ ។ សីល១០របស់ព្រះពុទ្ធសាសនា ឈរលើ(ខ)មួយសំខាន់ គឺសម្លាប់សត្វៗ ។ សម្លាប់សត្វគឺបាប ។ ចំណែក ទ្រឹស្តីកុម្មុយនីស្តវិញ គឺខុសពីនេះ ។ តាមទ្រឹស្តីកុម្មុយនីស្ត ស្នេហាប្រជាជនពិតប្រាកដៗ គឺត្រូវប្រគល់លទ្ធភាពអនុវត្តផ្តាច់ការទៅដល់វណ្ណៈអធន ។

ខ្ញុំសូមបញ្ជាក់ម្តងទៀត ទ្រឹស្តីកុម្មុយនីស្តពិតប្រាកដ-- ទ្រឹស្តីកុម្មុយនីស្ត គឺគេនិយាយអ៊ីចេះ គេនិយាយថា សេចក្តីស្នេហាប្រជាជនពិតប្រាកដ ។ សេចក្តីស្នេហាប្រជាជនពិតប្រាកដគឺ ត្រូវប្រគល់លទ្ធភាពអនុវត្តផ្តាច់ការទៅដល់វណ្ណអធន ។

*(ជនជាប់ចោទនិយាយជាភាសាបារាំង)*

**អ្នកបកប្រែ(ពីបារាំង)៖** លោកចៅក្រមស្នេហាពិតប្រាកដចំពោះប្រជាជនគឺផ្តល់ការស្រឡាញ់ទៅដល់អ្នកវណ្ណៈអធន និងការយល់ឃើញដោយខ្លួនឯង ។

**ស៖** លោកបាននិយាយថា សីល១០ គឺផ្អែកទៅលើៗការហាមមិនឲ្យសម្លាប់សត្វ ថាតើសីល១០នេះ គឺអនុវត្តតែការរារាំងសម្លាប់សត្វតែប៉ុណ្ណោះ ឬក៏រាំងសម្លាប់មនុស្សផងដែរ?

**ឆ** (ភាសាបារាំង)៖ យើងអាចសំដៅទៅលើមនុស្សផងដែរ ។

**ស៖** លោកបានជម្រាបថា លោកនៅជាមួយគ្រួសារ បន្ទាប់មកលោករត់ចូលព្រៃ ហើយយើងលើកឡើងនៅ-- លោកអាចនិយាយថា នៅខែមេសា និងខែឧសភា ឬក៏ក្រោយហ្នឹង ?

**ឆ៖** ត្រឡប់ពីផ្ទះមកដល់ភ្នំពេញនៅថ្ងៃទី២៥ មេសា ១៩៧០ ។ ខ្ញុំចេញពីភ្នំពេញទៅស្អាងកោះធំនៅខែប្រាំបី ខែសីហា ១៩៧០ ។

**ស៖** ថាលោកជួបអ្នកណាគេ? ជួបនៅពេលៗចូលព្រៃ តើលោកជួបនរណាគេ ? តើលោកបានជួបបុគ្គលដែលលោកជួបដែលលោកបានលើកឡើង គឺលោកបាននិយាយថា ឆាយ គឹមហួរ(ហ៊័) នោះ

ឬយ៉ាងម៉េច? តើលោកអាចជម្រាបខ្ញុំអំពី ឆាយ គឹមហួរ (ហ៊ា) ដែរ ឬទេ?

[១៣:៥២:១០]

**ឆ៖** ខ្ញុំបែកគ្នាជាមួយនឹងបង ឆាយ គឹមហ៊ា តាំងពីឆ្នាំ១៩៦៧ ។ នៅពេលដែលខ្ញុំចេញទៅព្រៃលើក ដំបូង គាត់ក៏ចេញទៅព្រៃដែរ គាត់ទៅកន្លែងផ្សេង គឺទៅខាងន៉ៃ ភ្នំវល្លិ៍នេះ ។ ឯចំណែកខ្ញុំ បក្សបញ្ជូន ខ្ញុំទៅនៅខាងស្រុកចំការលើ ខេត្តកំពង់ចាម ។ ចេញពីគុកទៅ ខ្ញុំបែកពី ឆាយ គឹមហ៊ា ហើយ ។ ខ្ញុំបែកគ្នាពី ឆាយ គឹមហ៊ា ហើយ ។

**ស៖** តើលោកជួបគាត់ក្រោយមកទៀត ឬយ៉ាងម៉េច?

**ឆ៖** គាត់ពេលនោះប្រតិបត្តិការក្នុងឋានៈជាប្រធានមន្ទីរភូមិភាគនិរតី ។

**ស៖** ថាតើមន្ទីរនោះឈ្មោះអ្វី? ហើយប្រើសម្រាប់ធ្វើអី? ថាតើមានអ្វីកើតឡើងនៅក្នុងមន្ទីរនេះ?

**ឆ៖** វាជាការិយាល័យរដ្ឋបាលរបស់ភូមិភាគនិរតី ដែលមាន តាម៉ុក ជាប្រធាន ។

**ស៖** នៅពេលដែលលោកនិយាយថា មន្ទីររដ្ឋបាលហ្នឹង គឺគេមានតួនាទីខាងមន្ត្រីនគរបាល--ខាងប៉ូលិសដែរឬទេ?

ឆ៖ ឯចំណែកអាការិយាល័យនេះ វាជាអ្នករក្សាទុកដាក់ឯកសារ ។ ខ្ញុំសូមនិយាយម្តងទៀត គណៈកម្មាធិការភូមិភាគ វាគ្រប់គ្រងទាំងអស់គ្រប់កិច្ចការ ទាំងទាហាន ទាំងប៉ូលីស ទាំងភ័ស្តុភារៗ ប្រជាជន ។ ឯចំណែក មន្ទីរភូមិភាគនេះ វាទទួលខុសត្រូវខាងការទុកដាក់ឯកសារ ជាអ្នក--

ការងារខ្លះប្រធានមន្ទីរភូមិភាគនេះ វាជាមុខជំនួសគណៈកម្មាការភូមិភាគទៅបញ្ជាស្អីផ្សេងទៀតបានដែរ ។ ពេលខ្លះប្រធានមន្ទីរភូមិភាគនេះ វានាំបញ្ជារបស់គណៈកម្មាធិការភូមិភាគៗនេះ ទៅបញ្ជាឲ្យអ្នកផ្សេងទៀតដែរ ។

ខ្ញុំសូមបញ្ជាក់ គឺប្រធានមន្ទីរភូមិភាគៗ ។ ប្រធានមន្ទីរភូមិភាគៗ គឺការិយាល័យរដ្ឋបាលរបស់មន្ទីរភូមិភាគ ។ វាអត់មានអំណាចអីផ្ទាល់ខ្លួនវាទេ តែវានាំបញ្ជារបស់គណៈកម្មាធិការភូមិភាគ ។

[១៣:៥៨:៥៦]

**ស៖** នៅក្នុងមន្ទីរ២០១ ថាតើមានបុគ្គលឃុំខ្លួនយ៉ាងម៉េចខ្លះ ?

**ឆ៖** មន្ទីរ២០១ វាមានតែការិយាល័យទេ ចង់ដាក់គុកមនុស្ស គឺយកមកដាក់នៅ ម-១៣ ។

**ស៖** ថាតើលោកៗបានដឹងអំពីអត្ថិភាពនៃមន្ទីរសន្តិសុខដែរឬទេ ? ថាតើបុគ្គលត្រូវបានគេឃុំខ្លួន និង សួរចម្លើយដែរឬទេ? នៅពេលដែលលោកបានដឹងអំពីគោលនយោបាយៗ ជាក់លាក់បក្សកុម្មុយនីស្ត

កម្ពុជា?

**ឆ៖** អ្នកណា? យ៉ាងម៉េច? សូមឲ្យច្បាស់សំណួរ ខ្ញុំអត់ទាន់ច្បាស់ទេ ។

**ស៖** ខ្ញុំចង់ដឹងថា តើលោកបានទទួលព័ត៌មានទាក់ព័ន្ធនឹងអត្ថិភាពនៃមន្ទីរសន្តិសុខដែរឬទេ? ដែលមន្ទីរសន្តិសុខនេះបានបង្កើតឡើង ដើម្បីអនុវត្តសេចក្ដីសម្រេចរបស់បក្សកុម្មុយនីស្តកម្ពុជា ?

**ឆ៖** ខ្ញុំបានជម្រាបលោកចៅក្រមពីព្រឹកមិញហើយ ។ កាលនៅតំបន់២៥ បានន័យថា នៅខាងស្អាងកោះធំ ខ្ញុំឃើញមន្ទីរនគរបាលមួយដឹកនាំដោយមិត្ត តេង ។ តេងៗ ក្រោមការដឹកនាំរបស់មិត្តតេង ។ TENG តេង ហើយមកនៅខាង-- ពេលខ្ញុំចូលមកដល់ភូមិភាគនិរតីភ្លាម ខ្ញុំជួបមិត្តចាស់ម្នាក់ឈ្មោះ តាំង ខែត ៗគាត់ទទួលភារៈមន្ទីរនគរបាលមួយដែរនៅខាង-- កន្លែងដែលគាត់នៅ មិនដឹងឈ្មោះអី? ត្រពាំងជោរ នៅខាងត្រពាំងជោរ ។ ខ្ញុំជួបដូច្នេះ ខ្ញុំឃើញមន្ទីរនគរបាលពីរ មុនកំណើត ម-១៣ នេះខ្ញុំឃើញមន្ទីរនគរបាលពីរ មួយនៅខាងស្អាងកោះធំ មួយទៀតនៅខាងត្រពាំងជោរ ។

ហើយតាមធម្មតា ខ្ញុំឮពីសម័យតស៊ូអាវុធជំនាន់មុន គឺព្រឹត្តការណ៍តស៊ូ១៩៥០-- សុំទោស ១៩៤៥-៥៤ ក៏មានមន្ទីរនគរបាលដែរ ។ ខ្ញុំសូមបញ្ជាក់ថា តាមការដឹង តាមការឮ តាមការពិគ្រោះគ្នាក្នុងជួរបដិវត្តន៍នេះ-- ។ ដូច្នេះ មុនកំណើតមន្ទីរ១៣នេះ វាមានប្រវត្តិសាស្ត្រមុនរួចមកហើយ ហើយក៏ខ្ញុំឃើញមន្ទីរនគរបាលពីរ ដែលខ្ញុំដឹងឮនឹងត្រចៀក ខ្ញុំឮនឹងត្រចៀកមានមន្ទីរនគរបាលពីរ កាលមុន ម-១៣ ។

[១៤:០៤:១៨]

**ស៖** លោកបានឮអំពីមន្ទីរនគរបាលនេះ ឬក៏លោកបានឃើញអ្វីកើតឡើងនៅទីនោះ ។ មុននឹងលោកបានលើកឡើងថា លោកបានឃើញមន្ទីរនគរបាលដែលគ្រប់គ្រងដោយកម្មាភិបាល តេង ថាតើប្រសិនបើលោកបានឃើញមែននោះ ថាតើលោកបានឃើញអ្វីខ្លះ? ហើយលោកមានអ្វីកើតឡើងខ្លះ?

[១៤:០៥:០០]

**លោក រ៉ូប៊ឺត ពើទីត៖**

ជនជាប់ចោទគឺមាន ឧបករណ៍ស្ដាប់សំឡេង ឆ្លើយតបឆ្លើយឆ្លងជាមួយគ្នា គឺវាធ្វើឲ្យមានការបញ្ហាចំពោះការបកប្រែ ។ ដូច្នេះហើយ ដើម្បីឲ្យកំណត់ហេតុបានច្បាស់លាស់ ជនជាប់ចោទគួរតែបិទប្រដាប់ស្ដាប់របស់គាត់ដើម្បីឲ្យមានការបកប្រែឲ្យបានត្រឹមត្រូវ ហើយមានការកំណត់ត្រាបានត្រឹមត្រូវ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

ហើយ ខ្ញុំគិតថាមិនមែនជាបញ្ហាទេ មេធាវីបានលើកឡើងគឺ ជនជាប់ចោទបានស្តាប់ការបកប្រែតាមឧបករណ៍របស់គាត់ ហើយគឺគាត់បញ្ជាក់នៅពេលដែលភាសាបារាំងមិនត្រឹមត្រូវ នេះជាអ្វីដែលគាត់បានស្តាប់ ។ ហើយខ្ញុំបញ្ជាក់ព្រឹកមិញហើយថា យើងមានបញ្ហាទាក់ទងទៅនឹងការបកប្រែ ។

**លោក រ៉ូប៊ឺត ពេទីត៖**

គាត់បានយល់ភាសាបារាំង ហើយគាត់ឆ្លើយមុនពេលដែលភាសាបារាំងនោះបានបញ្ចប់ ហើយខ្ញុំសុំឲ្យជនជាប់ចោទ ឲ្យគាត់រង់ចាំដល់ពេលបញ្ចប់ការបកប្រែនេះសិន ដើម្បីកុំឲ្យវាមិនមានបញ្ហាទៅដល់ការប្រែ ហើយវាអាចដំណើរការបកប្រែនេះបានដំណើរការទៅយ៉ាងស្រួល ។

**ប្រធានអង្គជំនុំ៖**

ឥឡូវយើងធ្វើអ៊ីចេះ ហើយសូមរៀបចំឲ្យបានស្រួលឡើងវិញ ។ នៅពេលដែលសំណួរ លោកជនជាប់ចោទនៅពេលដែលឆ្លើយរួចហើយ សូមលោកបិទមីក្រូហ្វូន ហើយដើម្បីស្តាប់នូវសំណួររបស់ចៅក្រម ។ ហើយចំណែកឯ ព្រឹកមិញនេះគឺយើងបានកត់សម្គាល់នូវសំណើនេះ ប៉ុន្តែកិច្ចពិភាក្សាដើម្បីថាតើរៀបចំនូវឧបករណ៍កត់ត្រានូវការបកប្រែជាភូមិសាស្ត្រ ឈ្មោះភូមិសាស្ត្រនានា តាមមធ្យោបាយនៃការប្រើប្រាស់ជាភាសាខ្មែរ ហើយនិងភាសាឡាតាំងនោះ តើយើងត្រូវរៀបចំនូវរបៀបម៉េចដើម្បីឲ្យការកត់ត្រាហ្នឹងជម្រាបជូនឲ្យកាន់តែច្បាស់លាស់បញ្ជាក់បន្ថែមជាលាយលក្ខណ៍អក្សរនៅ នៅកញ្ចក់នៃទូរទស្សន៍នេះ ។ ប៉ុន្តែឥឡូវនេះ យើងមិនទាន់បានគិតគូរពិចារណាជាមួយនឹងខាងកិច្ចការរដ្ឋបាល ផ្នែកខាងរូបភាពនេះនៅឡើយទេ ដោយសារត្រូវតែមានពេលវេលាដើម្បីជជែកគ្នាអំពីរបៀបរៀបចំយ៉ាងម៉េចដើម្បីឲ្យសម្រួលដល់កិច្ចការនេះ ហើយរសៀលនេះនៅពេលដែលយើងចប់ យើងនឹងពិចារណា ហើយសិក្សារៀបចំចាត់ចែងបញ្ហានេះ ដើម្បីសម្រាប់ធ្វើថ្ងៃស្អែក និងថ្ងៃមុខទៀត ។

ហើយបញ្ហា ការបកប្រែនេះ យើងបានកត់សម្គាល់ជាយូរមកហើយ វាមិនមែនត្រឹមតែការប្រើប្រាស់ឧបករណ៍នោះទេ សូម្បីតែបច្ចេកទេស ឬក៏កម្រិតសមត្ថភាពក្នុងការបកប្រែនេះ ក៏មានបញ្ហាផងដែរ ដោយសារការបកប្រែភាសាបច្ចេកទេសមួយចំនួន វានាំឲ្យមានបញ្ហាពិបាកក្នុងការបកប្រែដែរ ។ អ៊ីចឹងហើយ បានយើង អង្គសវនាការរំឭកម្តងហើយម្តងទៀត ព្យាយាមក្នុងការប្រើប្រាស់នូវឃ្លានូវវាក្យខណ្ឌដែលត្រូវនិយាយ ទាំងសួរ ទាំងឆ្លើយ ទាំងការបញ្ជាក់ផ្សេងៗ ដើម្បីឲ្យយឺត ហើយនិងប្រើនៅក្នុងប្រយោគខ្លីសមល្មមដែលអាចសម្រួលដល់ការប្រែរបស់អ្នកបកប្រែបាន ។ ប៉ុន្តែទោះបីយ៉ាងណា

ក៏ដោយ ពីព្រោះជាដំបូងៗនេះ ដោយសារទាំងអស់គ្នាទាំងអង្គជំនុំជម្រះផង ក៏មិនទាន់សមនឹងការឆ្លងកាត់របៀបដឹកនាំនីតិវិធី ដែលមានការបកប្រែច្រើនភាសាដូច្នេះ ។ អ៊ីចឹង យើងបន្តិចទៀត យើងនឹងមានបទពិសោធន៍ ហើយយើងនឹងសម្របសម្រួលបានល្អជាងនេះ ជាមិនខាន ។ បាទ សូមបន្តទៅទៀត ។

សូមអញ្ជើញ លោក ហ្សង់ម៉ាក បន្តទៀត ។

[១៤:០៩:១៤]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** ប្រសិនបើបាន ខ្ញុំយល់ត្រឹមត្រូវនោះ លោកបាននិយាយថា លោកបានដឹងមុនពេលមន្ទីរ ម-១៣ មានមន្ទីរនគរបាលចំនួនពីរ លោកក៏បានបញ្ជាក់ផងដែរ ។ លោកបានជួបយ៉ាងហោចណាស់កម្មាភិបាលមួយរូប ហៅ តេង ខ្ញុំអត់សូវអានឈ្មោះត្រឹមត្រូវ ដែលគាត់ជាអ្នកគ្រប់គ្រងមន្ទីរនគរបាល ។

លោកបាននិយាយអំពីកម្មាភិបាលមួយទៀតគឺ កុល ថេងកែត ថាតើព័ត៌មាននេះត្រឹមត្រូវដែរឬទេ?

**ឆ៖** ម៉្យាងជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ដែលខ្ញុំរាយការណ៍ជូនលោកចៅក្រម ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនេះ គឺពីឆ្នាំ១៩៤៥ រហូតដល់ឆ្នាំ១៩៥៤ ឥស្សរៈខ្មែរយៀកមិញមានមន្ទីរនគរបាលសម្លាប់មនុស្សរួចមួយសារមកហើយ នេះជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ។

ទីពីរ ដែលខ្ញុំដឹង ។ ដឹងហ្នឹង ដឹងច្បាស់តែម្តង ។ ម៉ឹង សំណាង ហៅ តេង នេះជាប្រធានមន្ទីរនគរបាល នៅខាងតំបន់២៥ មន្ទីរនគរបាលនេះកើតឡើងនៅក្នុងខែ១២ ឆ្នាំ១៩៧០ ។ រឿងនេះ ហើយដែលខ្ញុំជម្រាបលោកចៅក្រមព្រឹកមិញថា នៅពេលដែលគេចាត់តាំងឲ្យខ្ញុំធ្វើនគរបាលនេះ ខ្ញុំភ័យ ខ្ញុំខ្លាចកំបុតកទៅជាមួយនឹងមេ ទោះមេដែលគ្រប់គ្រងតំបន់២៥នេះ ឈ្មោះ សុខ ប៊ុតចំរើន ឈ្មោះ ស៊ីសុវត្ថិ ប៊ុតមុន្នី នេះ បានរំលោភលើគោលការណ៍បក្ស ចាត់បក្សជនគ្នាឯងសម្លាប់ ចាត់បក្សជនគ្នាឯងដាក់គុកដោយគ្មានការអនុញ្ញាតពីមជ្ឈិម ។ នេះខ្ញុំឮច្បាស់តែថា ឲ្យចូលទៅឃើញគុក ឃើញច្រវ៉ាក់ ឃើញខ្នោះឃើញឃ្នាងរបស់គេអត់ទេ តែការចាត់តាំងហ្នឹងច្បាស់ ព្រោះខ្ញុំនៅក្នុងខាងយោធា ។ ខ្ញុំរត់មក ខ្ញុំសុំសំណើមក មកដល់ភូមិភាគនិរតីជួបមិត្តភក្តិចាស់ ឈ្មោះ តាំង ខែត គ្រូនៅវិទ្យាល័យចំរើនវិជ្ជា គេធ្វើប្រធានមន្ទីរនគរបាល ទីស្នាក់ការរបស់គេនៅត្រពាំងជោរ ជាមន្ទីរនគរបាល១របស់តំបន់ តំបន់៣២ របស់ភូមិភាគនិរតី ។ ដូច្នេះ ខ្ញុំលើកព្រឹត្តិការណ៍មន្ទីរនគរបាល២នេះ ដើម្បីបញ្ជាក់ថា មុនម-១៣ នេះ វាមានមន្ទីរនគរបាល២ ដែលខ្ញុំបានដឹងឮរួចទៅហើយ ដឹងឮច្បាស់ ។ ដូច្នេះ រឿងដែលខ្ញុំរាយការណ៍

ទាំងប៉ុន្មាន មួយជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ មួយទៀតជាព្រឹត្តិការណ៍ ដែលខ្ញុំឮជាក់ស្តែង ។

[១៤:១៣:១៤]

**ស៖** តើបេសកកម្មច្បាស់លាស់របស់មន្ទីរសន្តិសុខនេះ គឺយ៉ាងម៉េច ហើយមានការសួរចម្លើយនៅទីនោះដែរឬទេ? ហើយការសួរមច្លើយនេះធ្វើឡើងតាមរបៀបណា?

**ឆ៖** ការសួរចម្លើយនៅក្នុងមន្ទីរនគរបាលអស់នេះ តាមខ្ញុំដឹងឮជៀសមិនរួចពីទារុណកម្ម ។ របៀបយកចម្លើយនៅមន្ទីរ មិត្តតេង មាននៅសល់ជាឯកសារនៅស-២១ ពីព្រោះ ណាត ខ្លួនគាត់ គាត់ចង់ក្តាប់ណាស់អាមន្ទីរហ្នឹង ។ មន្ទីរមិត្ត តេង ហ្នឹង ។ នៅពេលចាប់ផ្តើមស-២១ ដំណើរការគាត់យកឯកសារពីខាងមន្ទីរនគរបាល មិត្តតេង មួយកម្ពុះ យកមកឲ្យខ្ញុំទុក ខ្ញុំទុក ដូច្នេះ វានៅជាឯកសាររបស់មន្ទីរស-២១ ហ្នឹងរបៀបសួរចម្លើយសរសេរខុសគ្នា ក៏ប៉ុន្តែជៀសមិនរួចពីទារុណកម្មដូចគ្នា ។ ចំណែកមិត្ត តាំង ខែក វិញ មានជំហរមិនត្រឹមត្រូវទេ ។ មិត្ត តាំង ខែក គាត់ថា គាត់មានជំហរវណ្ណៈខ្ពង់ខ្ពស់ណាស់ គាត់ជូនយោបល់ទៅថ្នាក់លើ អំពីមនុស្សណាដែលសង្ស័យអី ខ្ញុំមិនយល់ព្រម ក៏ប៉ុន្តែគ្មានឯកសារនៅសល់នៅស-២១ទេ-- ពីឯកសារដែល តាំង ខែក សួរចម្លើយអត់មានសល់នៅស-២១ទេ ។

ដូច្នេះ សរុបមកមន្ទីរនគរបាលទាំងពីរ ដែលកើតមុនខ្ញុំក៏មានទារុណកម្ម ជាប្រវត្តិសាស្ត្រពីជំនាន់មុនមកមន្ទីរនគរបាលផ្សេងទៀតជំនាន់ឥស្សរៈក៏មានទារុណកម្ម នេះវាហូរហែជាប្រវត្តិមកអញ្ចឹង ។

**ស៖** ប្រសិនបើខ្ញុំយល់ត្រឹមត្រូវនោះ លោកបានបញ្ជាក់ថា គឺមានឯកសារ ដែលពាក់ព័ន្ធទៅនឹងវិធីសាស្ត្រ ដែលអ្នកទោសត្រូវបានគេសួរចម្លើយ ។ ឯកសារនេះ គឺវាពាក់ព័ន្ធទៅនឹងវិធីសាស្ត្រ ការធ្វើទារុណកម្ម តើត្រឹមត្រូវដែរឬទេ? ហើយថាតើលោកដឹងបញ្ហាដែលអំពីឯកសារនេះតាំងពីពេលណាមក?

[១៤:១៦:៣៤]

**ឆ៖** នគរបាលពីសម័យខ្មែរឥស្សរៈមាននៅជាឯកសារ ដែលបងឆាយ គឹមហ៊ី ហើយនិងអ្នកតស៊ូពីជំនាន់មុន គេនិយាយប្រាប់ខ្ញុំ ។ ឯចំណែក មន្ទីរនគរបាលនៅតំបន់២៥របស់ មិត្តតេង ខ្ញុំមិនបានជួបមិត្តតេង ផ្ទាល់ទេកាលនោះ តែជាគោលការណ៍ឈ្មោះ ម៉េង ផន ហៅ សុខ ប្រធានយោធាតំបន់២៥នេះនិយាយអំពីរបៀបធ្វើទារុណកម្ម ហើយនិងស្នារតីដាច់ខាតរបស់ មិត្តតេង ប្រាប់ខ្ញុំដែរ ។

សូមបញ្ជាក់ថា មិត្តផន ហៅ សុខ នេះ ក៏ជាកម្មាភិបាលម្នាក់ ដែលគ្រប់គ្រងខ្ញុំពីជំនាន់៦៥ មកដែរ ដូច្នេះ គេមិនលាក់នឹងខ្ញុំទេ ។ ហើយការដែលខ្ញុំរួចខ្លួនដោយ សុខ ប៉ិតចំរើន មិនបានចាប់ក៏ដោយសារ សុខ នេះដែរ ។ ដូច្នេះ រឿងធ្វើទារុណកម្មជៀសមិនរួចនៅមន្ទីរនគរបាលរបស់ខ្មែរក្រហម

ក៏ដូចជានគរបាលជំនាន់ខ្មែរឥស្សរៈ វាជារឿងសាមញ្ញ ដែលអ្នកផងដឹងឮ ទាំងប្រជាជន ទាំងជួរបដិវត្តន៍ ហើយស្រេចរួចទៅហើយ ។

**ស៖** ប្រសិនបើខ្ញុំយល់ត្រឹមត្រូវនោះ លោកបានបញ្ជាក់ថា លោកបានដឹងអំពីវិធីសាស្ត្រ ធ្វើទារុណកម្ម ហើយវិធីសាស្ត្រទារុណកម្មនេះ គឺជៀសមិនរួចទេ នៅក្នុងកំឡុងខ្មែរក្រហម តើវាកើតឡើងនៅក្នុងកំឡុងខ្មែរក្រហម ឬក៏កំឡុងពេលខ្មែរឥស្សរៈ? អ៊ីចឹង ជាអ្វីដែលលោកចង់ជម្រាបយើងខ្ញុំ ឬយ៉ាងម៉េច?

នៅក្នុងការសន្ទនាវាងបញ្ហាទារុណកម្មនេះ តើមានអ្វីនិយាយប្រាប់លោកជាក់លាក់នៅលើបញ្ហាហ្នឹង?

**ឆ៖** រឿងដែលខ្ញុំដឹងពីរឿងទារុណកម្មនេះ គេនិយាយជារួមទេ ។ គេនិយាយថា ជៀសមិនរួចពីទារុណកម្ម ដឹងជារួមអញ្ចឹង ។ ដូច្នេះ ទារុណកម្ម ខ្ញុំឮដំបូងគឺ សំដៅការវ៉ៃដោយរំពាត់ លើរូបរាងកាយនេះជាសំខាន់ ទារុណកម្មដែលខ្ញុំដឹងឮមុននឹងខ្ញុំកាន់កាប់កិច្ចការនៅមន្ទីរ១៣ ។

[១៤:២០:០៨]

**ស៖** ហើយក្រៅពីការធ្វើទារុណកម្ម តើលោកបានដឹងអំពីការសម្លាប់ដែរឬទេ?

**ឆ៖** រឿងនេះ វាច្បាស់ណាស់ៗ ។ ខ្ញុំដឹងច្បាស់ពីរឿងសម្លាប់ តែពីរឿងដោះលែងមានកន្លែងខ្លះនិយាយមានដោះលែងមែន តែដូចតិចណាស់ ។ ពីរឿងមិនដោះលែងច្រើន ។

**ស៖** មនុស្សភាគីច្រើនត្រូវបានដោះលែង ប៉ុន្តែអ្នកណាជាសម្រេចបញ្ហាដោះលែង? ថាអ្នកណាជាអ្នកសម្រេចលើបញ្ហាសម្លាប់ ? ហេតុអ្វី?

**ឆ៖** មុនខ្ញុំកាន់កាប់មន្ទីរ ១៣ ខ្ញុំមិនបានគិតដល់បញ្ហានោះឲ្យល្អិតទេ ។ ថាអ្នកណាជាអ្នកសម្រេចចាប់? អ្នកណាជាអ្នកសម្រេចដោះលែង? មុននឹងឈានចូលទៅដល់សាច់បញ្ហា ខ្ញុំសូមបញ្ជាក់ជូនថា នៅពេលនោះ យើងប្រើពាក្យថា "គិញ" អត់ទាន់ប្រើពាក្យថា "*សេអ៊ីអា*" ស្អីៗទៀតទេ ។ ប្រើពាក្យថា "គិញ" ប្រើពាក្យថា "ខ្មាំង" ។

ដល់ខ្ញុំចូលមកកាន់កាប់កិច្ចការនៅមន្ទីរ ១៣ ក្រោយពីខ្ញុំបានអង្វរករបដិសេធសុំមិនធ្វើការនេះ ព្រោះខ្លាចកំបុតក ។ បើមេវាក្បត់ អាមន្ទីរនគរបាលនឹងក៏វាកំបុតកទៅជាមួយមេដែរ ។ ឆាយ គឹមហ៊ីគាត់ពន្យល់ ។

អ្នកសម្រេចឲ្យចាប់ គឺទាល់តែសមាជិកមជ្ឈិម ។ ពីថ្ងៃនោះមកខ្ញុំចៀសខ្លាចកំបុតកមិនប៊ាន

សម្រេចទេ អារឿងចាប់ ។ មិនប៉ានទាំងសម្រេចសរសេរឯកសារស្អីឲ្យឃើញថាខ្លួនឯងមានបំណងចង់សង្កត់ធ្ងន់លើអ្នកណា ឬនរណាទៀត ។ ដូច្នេះហើយបានជាសំណុំរឿងដែលខ្ញុំសរសេរ ខ្ញុំចូលចិត្តឲ្យសាមីខ្លួនគេសរសេរ ។

ហើយអ្នកដែលមានសិទ្ធិដោះលែង ក៏មិនមែនខ្ញុំ ក៏មិនមែនប្រធានមន្ទីរនគរបាលនានាដែរ ។ អ្នកដោះលែង គឺទាល់តែខាងលើគេសម្រេច ។ នេះដែលខ្ញុំចាប់ផ្តើមអនុវត្តនៅម-១៣ គឺយ៉ាងនេះឯង ។ អ្នកចាប់ គឺមជ្ឈិមបក្ស ដែលទទួលភារៈនៅតាមភូមិភាគមាននានា ដូចជា វន វ៉េត, ដូចជា តាម៉ុក, ដូចជា ជូ ជេត ហៅ ស៊ី, ដូចជា ហ្លួត ហេង ហៅ ប៉ាល់ ជាដើម ។ ទុកឲ្យគេសម្រេចចុះ ។

[១៤:២៣:៥៤]

**ស៖** តើអ្វីជាការស្នើសុំពីលោក? នៅពេលគេនិយាយពីលោកអំពី ម-១៣ ថាគេសុំឲ្យលោកធ្វើអ្វីពីមន្ទីរម-១៣ ហ្នឹង?

**ឆ៖** រឿងនេះ និយាយវារបៀបជាការអធិប្បាយព្រឹត្តិការណ៍មួយម៉ាត់ពីរទៅចុះ ។ ថ្ងៃ២០ កក្កដានេះ បង វន គាត់ឲ្យ ឆាយ គឹមហ៊ ឌុបខ្ញុំទៅជួបគាត់ ។ ដល់ទៅជួបយប់នោះ អត់បានធ្វើការជាមួយនឹងបង វន ទេ ព្រោះបង វន មានភ្ញៀវមកពីភ្នំពេញ ។ កម្លាំងសម្ងាត់ពីភ្នំពេញ គេទៅជួបគាត់ ។ គាត់គ្រាន់តែផ្តាំមួយម៉ាត់ថា មិត្តស្អែកធ្វើការជាមួយមិត្ត ហុក ទៅ គឹមហ៊ ទៅ ខ្ញុំផ្តាំផ្ញើរួចអស់ហើយ ។ ហើយដល់ថ្ងៃ២១ ហ្នឹងឯង បង គឹមហ៊ គាត់ក៏ចាប់ផ្តើមនិយាយជាមួយនឹងខ្ញុំ ។ ដូចដែលខ្ញុំបានជម្រាបលោកចៅក្រមពីព្រឹក ពីរឿងខ្ញុំអង្វរករយ៉ាងម៉េចខ្លះ? ពីរឿងគេណែនាំមកយ៉ាងម៉េចខ្លះ? ណែនាំហើយប្រាប់ថាឥឡូវបក្សមានតែអង្ករ និង អំបិល ឲ្យមិត្តទេ ក្រៅពីនោះដោះស្រាយ ។ តាំងពីផ្ទះនៅ តាំងពីអីៗ ។

**ស៖** តើអ្វីជាបេសកកម្មរបស់ ម-១៣? តើអ្វីជាបេសកកម្មជាក់លាក់របស់ ម-១៣ នោះ?

**ឆ៖** ដំបូងគេប្រគល់គិញ ដែលគេហៅថា "គិញ" ហ្នឹង គឺមនុស្សជាខ្មែរហ្នឹង អ្នកក្រ ចូលពីដីរំដោះទៅដី លន់ នល់ ។ សុំទោសចូលពីដី លន់ នល់ មកដីរំដោះ តែគេចាប់បាន កងឈ្លបគេចាប់បានគេបញ្ជូនមកហើយ ដូចជាឈ្មោះ កៅ គឹមហៀង, កែវ ប៊ុនហៀង អីទេ? ដែលខ្ញុំជម្រាបដែលលោកចៅក្រមពីព្រឹកនោះ ។ គេចាប់បាននៅឯមុខនុះ ពួកកងឈ្លបគេចាប់បានគេបញ្ជូនមកឲ្យ*អ៊ុំម* ម-១៣ វាយសួរចម្លើយ ។

ដូច្នេះដំបូង គឺចាប់គិញ ដែលគេហៅថា "គិញ" ហ្នឹង យកមកវ៉ៃសួរចម្លើយ ហើយកម្ទេច ហ្នឹងហើយដែលគេហៅថា បុព្វហេតុការពារដីរំដោះ ការពារប្រជាជន នៅក្នុងដីរំដោះកុំឲ្យខ្មាំងវាដណ្តើមដី

រំដោះទៅបាន ហើយនិងកុំឲ្យខ្មាំងវាមកទម្លាក់គ្រាប់បែក ឬក៏លើកទ័ពចូលមកវ៉ៃយកដីរំដោះទៅបាន ។

ដូច្នេះ កាតព្វកិច្ចកម្មេចពេលនេះគឺដើម្បីការពារទឹកដីរំដោះ ការពារអាយុជីវិតប្រជាជន នេះការនិយាយវាទៅអ៊ីចឹង ។

[១៤:២៧:១៥]

**ស៖** ដូច្នេះបេសកកម្មរបស់មន្ទីរ ម-១៣ នោះ គឺកម្រិតត្រឹមតែសួរចម្លើយ ហើយនិងសម្លាប់នៅអ្នកដែលគេចាត់ទុកថា ជាគិញ តែប៉ុណ្ណឹងទេឬ?

**ឆ៖** ភារកិច្ចដំបូងដែលយើងខ្ញុំនៅក្នុង*អ៊ុម* ម-១៣ ធ្វើនេះ គឺដំបូង គឺប៉ុណ្ណឹង ។ ក៏ប៉ុន្តែចាប់ផ្តើមទៅវាមានបញ្ហាផ្សេងទៅទៀត ។

ដូចជា ទី១ គេចាប់ស្រីម្នាក់នៅភូមិកុមាររមាសយកទៅឲ្យម-១៣ ថាជាមនុស្សលួចក្រវិលគេទំហំ៥ហ៊ុន ។ ខ្ញុំមិនព្រមដាក់គុក ព្រោះខ្ញុំមើលទៅជីវភាពដែលគេចោទថា លួចនោះ វាជីវភាពធូរធារ ក៏ប៉ុន្តែបង គឹមហ៊ី គាត់ថាប្រយ័ត្ន! ប្តីវាជាទាហានពាក់*អាស្ទរជង់* គ្រាន់តែថាទាហានគេទៅចោលប្រពន្ធ ហើយប្រពន្ធគេនៅជាមួយនឹងយើងត្រូវតែថែរក្សាគេ ។ ម្លោះហើយជជែកគ្នាចុះឡើង បាន១ខ្ញុំអង្វរករសុំបង ឆាយ គឹមហ៊ី ដោះលែងអ្នក ម្ដឹស នេះបាន ដោយមានការអនុញ្ញាតពីខាងលើមកទៀត ពីតាម៉ុកពីអី១មកទៀត បានខ្ញុំដោះលែងបាន ។ នេះវាចូលក្នុងមនុស្សក្នុងដីរំដោះទៅវិញ ។ ផុតពីមនុស្សក្នុងដីរំដោះ វាចូលមនុស្សពីក្រៅ ដូចយ៉ាង ប៊ីហ្ស៊ូ ខ្ញុំនេះគាត់មកពីក្រៅ ហើយគេចោទគាត់ថា ស្អីណាចាប់យកមកឲ្យ ម-១៣ សួរចម្លើយ មួយបែបហ្នឹងទៅទៀត ។

ដូច្នេះសភាពការណ៍ វាចេះតែស្មុគស្មាញកើតឡើងហើយ ។ ការយល់ដឹងរបស់មន្ទីរ ១៣ វាចេះតែវិវិត្តន៍ទៅតាមនុ៎ង តាមការណែនាំបណ្តើរ១របស់គេហ្នឹង ។

[១៤:២៩:៤៣]

**ស៖** ដូច្នេះលោកបានប្រាប់យើងថា ពីដំបូងឡើយមន្ទីរ ម-១៣ នោះ ត្រូវបានបង្កើតឡើង ដើម្បីប្រឆាំងនឹងគិញ ។ ដើម្បីការពារនៅតំបន់រំដោះ ហើយបន្ទាប់មកទៀត មានមនុស្សផ្សេង១ទៀតត្រូវបានបញ្ជូនមកពីតំបន់ផ្សេង១ទៀត តើគេចាត់ទុកអ្នកទាំងនោះថា គិញ? ថាហេតុអីបានជាគេនាំអ្នកទាំងមក ម-១៣ នោះ?

**ឆ៖** មនុស្សដែលខ្ញុំបានជម្រាបលោកចៅក្រម មានម្នាក់នៅក្នុងតំបន់រំដោះ នៅក្នុងភូមិភាគនិរតី គឺស្រីម្នាក់ឈ្មោះ ម្ដឹស នៅភូមិកុមាររមាស ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ គឺក្នុងភូមិភាគនិរតីនេះ ។

ឯចំណែកមនុស្សបីនាក់ទៀត គឺហ្វ្រង់ស័រ ប៊ីហ្សូ *(Francois Bizot),* ហើងនិងគូកនគាត់មានឈ្មោះ មិត្តឡាយ ហើយនិងមិត្ត ស៊ុន មកពីក្រៅ ។ រឿងនេះដែលធ្វើឲ្យខ្ញុំស្មុគស្មាញ ។ ក៏ប៉ុន្តែ រឿងនេះវាហួសសមត្ថភាពខ្ញុំដែរ ។ វាជាសមត្ថភាពរបស់ វន វ៉េត តស៊ូសុំយោបល់អនុគ្រោះដោះលែងពី ប៉ុល ពត រឿងនេះ វែងឆ្ងាយ ។

ទន្ទឹមហ្នឹងនេះ រឿងនៅក្នុងតំបន់រំដោះក៏វាចេះតែមានដែរ ហើយរឿងមកពីតំបន់ពីខាងមុខនោះក៏មានដែរ ។ រឿងតំបន់រំដោះខ្ញុំសូមទុកថាំថ្ងៃ លើកបន្តិចទៀតសឹមនិយាយព្រោះរឿងវាដល់ទៅ ៧៣ នុះ បាន១វាមាន១បញ្ហានេះ ។ ឯចំណែករឿងនេះ នៅតំបន់ខាងមុខគេបញ្ជូនមនុស្សពីខាងកប់ស្រូវ ។ ខ្ញុំសូមជូនភូមិសាស្ត្រកប់ស្រូវ គឺនៅខាងជិតភ្នំពេញ ខាងជើងភ្នំពេញ ។ ខាងកប់ស្រូវនេះ វាមានខ្មែរណសិរ្សពីរខ្មែរ ។ វាទាស់គ្នា ។ វាប្ដឹងគ្នាប្រធានស្រុកកណ្ដាលស្ទឹងចាប់មួយក្រុមយកទៅឲ្យខាងមន្ទីរ ១៣ ។ មន្ទីរ ១៣ សួរចម្លើយមួយភ្លែតដំបូង ឃើញអីយ៉ាស់មនុស្សទាស់គ្នាទេ ។ ខ្ញុំស្ទុះទៅរាយការណ៍ជូនយោបល់ វន វ៉េត សូមអង្វរគាត់ថា មនុស្សនេះទាស់គ្នាទេ ។ មិនមែនជារឿងខ្លាំងឬអីទេ ។ តស៊ូចុះឡើង១បាន វន វ៉េត គាត់សម្រេច ។ អង្វរករគាត់ចុះឡើង១បាន វន វ៉េត គាត់សម្រេចឲ្យខ្ញុំដោះលែងមនុស្សមកពីខាងកប់ស្រូវ តែមុននឹងដោះលែងគ្រូនចាញ់ងាប់ម្នាក់បាត់ហើយ ។

ដូច្នេះ រឿងវាចេះតែស្មុគស្មាញទៅក្នុងប្រជាជនខ្លួនឯងហ្នឹង ។ នៅក្នុងដីរំដោះខ្លួនឯងហ្នឹង ។

[១៤:៣២:៥៦]

**ស៖** នៅក្នុងមន្ទីរ ម-១៣ នោះ ត្រូវបានបង្កើតឡើង នៅក្នុងតំបន់រំដោះ ប៉ុន្តែនៅក្នុងកំណត់ត្រាឯកសារសំណុំរឿង មានការយោងមួយថា ទៅ--- នៅក្នុងតំបន់ពិសេស តើភូមិភាគពិសេសនោះ មានលក្ខណៈដូចម្ដេច? តើវាបង្កើតបានជាតំបន់ណាខ្លះ?

**ឆ៖** លោកចៅក្រមជាទីគោរព ។ បញ្ហានេះ វាជាបញ្ហាប្រវត្តិសាស្ត្ររបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងដណ្ដើមដីយកមកគ្រប់គ្រងពី លន់ នល់ ។

ដើមឡើយវាមានភូមិនិរតី ។ តាម៉ុក គាត់ទំនាស់ជាមួយនឹងបញ្ញាជនខ្លាំង ដេញបញ្ញាជន ៤នាក់ឲ្យចេញផុតពីនិរតី ២៤ម៉ោង ។ ម្ល៉ោះហើយ ប៉ុល ពត ត្រូវសម្រួលឲ្យគេប្រមូលបញ្ញាជននៅខាងភូមិភាគនិរតីប៉ុន្មាន យកទៅបង្កើតភូមិភាគពិសេស ។

ដូច្នេះ ភូមិភាគពិសេសនេះ ទើបនឹងកកើតថ្មីទេ ។ មុនកំណើត *អឹមត្រី* បន្តិច ឬក៏យើងថាដំណាលនឹងមន្ទីរ ១៣ ក៏ថាបានដែរ ។ ដូច្នេះ ជាភូមិភាគមួយថ្មី ។ ភូមិភាគពិសេសនេះ មានតំបន់ពីរ គឺ

តំបន់១៥ នៅខាងជើងផ្លូវលេខ៤ ហើយនិងនៅខាងជើងក្រុងភ្នំពេញ ។ មានស្រុក៤ គឺ ស្រុកអង្គស្នួល, ស្រុកកណ្តាលស្ទឹង, ស្រុកដង្កោ និង ស្រុកពញាឮ ។

តំបន់១៥នេះ ដឹកនាំដោយបក្សជនជើងចាស់ម្នាក់ឈ្មោះ ចេង អន ។ នៅខាងត្បូងភ្នំពេញ មានតំបន់២៥ តំបន់២៥នេះរួមមានស្រុកបួនដែរ គឺស្អាង,កោះធំ, លើកដែក និងកៀនស្វាយ ។

តំបន់២៥នេះ ដឹកនាំដោយបក្សជនម្នាក់ជើងចាស់ដែរ ឈ្មោះ នង សួន ។ តំបន់ទាំងពីរនេះ រួមគ្នាជាមួយនឹងក្រុងភ្នំពេញ ក្រុងភ្នំពេញនេះ ដឹកនាំដោយ ក្រោយមកដឹកនាំដោយនេះ មិត្តម្នាក់នេះ ដែលថតជាមួយនឹងខ្ញុំនេះ ឈ្មោះ ស៊ិន ណារ៉ា ពីលើកមុនដឹកនាំដោយក្មួយរបស់ វន វ៉េត ឈ្មោះ ប៉ើក ផន ហៅ ហង្ស ប៉ុន្តែដល់ ប៉ើក ផន ស្លាប់ទៅ ឥឡូវនូវមិត្តនេះគាត់ដឹកនាំបន្ត ។

ដូច្នេះ ក្រុងភ្នំពេញ រួមជាមួយនឹងតំបន់១៥ រួមជាមួយនឹងតំបន់២៥ កើតទៅជាភូមិភាគពិសេស ដែល វន វ៉េត គាត់គ្រប់គ្រងពីលើ ។ ឯអាតំបន់២៥នេះ អាភូមិភាគពិសេសនេះ វាមានមន្ទីររបស់វាច្រើន ក្នុងហ្នុងហ្នឹងមន្ទីរភូមិភាគ ឈ្មោះថាមន្ទីរ៣០៥ ។ មន្ទីរ៣០៥នេះ ដឹកនាំដោយអាឱតអតីតបញ្ញាជនម្នាក់ឈ្មោះ រស់ ជាតិថូ អាឱតអតីតអ្នកការទូត ។ ដូច្នេះ ខ្ញុំសូមជូនថាភូមិភាគពិសេសជាភូមិភាគមួយថ្មី កកើតឡើងនៅក្នុងឆ្នាំ៧១ហ្នឹង មានតំបន់ពីរ គឺតំបន់២៥ និងតំបន់១៥ ហើយនិងអ្នកតស៊ូសម្ងាត់នៅក្រុងភ្នំពេញ ។

**ស៖** ដូច្នេះ ភូមិភាគពិសេសមានតំបន់ពីរ គឺថាតំបន់១៥ ហើយនិង២៥ បូកជាមួយនឹងភ្នំពេញមួយទៀត តើត្រូវអ៊ីចឹងទេ?

**ឆ៖** បាទ, គឺភូមិភាគ មិនមែនតំបន់ទេ ។

**ស៖** តំបន់១៥, តំបន់២៥ ?

**ឆ៖** មិនទេ ភ្នំពេញខ្លួនឯង--

**ស៖** សូមរង់ចាំសិន ប្រសិនបើលោកចាំទេ គឺថាយើងមានបញ្ហាបកប្រែ ។

**ឆ៖** មានតំបន់១៥ មានតំបន់២៥ តំបន់ភូមិភាគពិសេស មានតំបន់១៥ មានតំបន់២៥ និងភ្នំពេញ ដែលមានកម្លាំងបង្កប់សម្ងាត់ធ្វើសកម្មភាព ។

**ស៖** នៅក្នុងភូមិភាគពិសេសនេះ តើមានមន្ទីរសន្តិសុខច្រើនដែរឬទេ? ឬក៏មានតែមន្ទីរស-២១ មួយទេ ជាមន្ទីរនោះ ?

**ឆ៖** ជាផ្លូវការ មន្ទីរ-១៣ វាជាមន្ទីរនគរបាលរបស់ភូមិភាគពិសេស ។ ក៏ប៉ុន្តែ មនុស្សដែលចាប់

ពីនៅខាងត្បូងភ្នំពេញ និងខាងផ្លូវលេខ៤ ខាងត្បូងផ្លូវភ្នំពេញ គឺចាប់នៅតំបន់២៥ ត្រូវធ្លាក់ទៅលើមន្ទីរនគរបាលរបស់ មិត្តតេង ។

សរុបមកវិញ មន្ទីរ-១៣ ទទួលភារៈ ទទួលមនុស្សដែលចាប់មកពីតំបន់១៥ របស់ភូមិភាគពិសេស។ ឯចំណែកមន្ទីរមិត្តតេង ទទួលភារៈចាប់មនុស្ស ទទួលមនុស្សសួរចម្លើយ ពីមន្ទីរ--ពីតំបន់២៥ ខ្ញុំនិយាយច្រឬកច្របល់ណាស់ សុំទោសខ្ញុំនិយាយម្តងទៀត ។ មន្ទីរ-១៣ ទទួលភារៈឃុំឃាំងនិងសួរចម្លើយ និងកម្ទេចមនុស្សនៅក្នុងតំបន់១៥ ឯចំណែកមន្ទីរនគរបាល់របស់មិត្តតេង ទទួលភារៈឃុំឃាំងសួរចម្លើយ និងកម្ទេចមនុស្សដែលចាប់នៅក្នុងតំបន់២៥ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះ សូមប្រកាសផ្អាកក់សវនាការ២០ម្ភៃនាទី ។ សម្រាកដល់ម៉ោងបី សូមអញ្ជើញចូលត្រឡប់មកវិញ បាទ, ដំណើរបន្តកិច្ចដំណើរការសវនាការបន្តទៅទៀត ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ ។

*[សវនាការសម្រាកពីម៉ោងរយៈពេល១៤:៤១នាទីដល់ម៉ោង ១៥:០៥:០០នាទី]*

**ក្រឡាបញ្ជី៖**

អញ្ជើញអង្គុយចុះ!

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាសបន្តដំណើរការសវនាការតទៅទៀត អម្បាញ់មិញគឺលោក ហ្សង់ម៉ាក លោកចៅក្រមកំពុងតែដំណើរការ នៃការសួរដល់ជនជាប់ចោទ សូមអញ្ជើញដល់លោក ហ្សង់ម៉ាកបន្តតទៅទៀត ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** ខ្ញុំចង់ត្រឡប់ទៅរកមន្ទីរ១៣ ហើយនិងទៅភូមិភាគពិសេស តើនរណាជាអ្នកសម្រេចក្នុងការបង្កើតនូវភូមិភាគពិសេសនេះ? តើនរណានៅក្នុងបក្សជាអ្នកសម្រេចនូវ បង្កើតនូវភូមិភាគពិសេសនេះ?

**ជនជាប់ចោទ៖**

ឆ៖ សេចក្តីសម្រេចចិត្តនេះធំណាស់ទាល់តែ ប៉ុល ពត បានសម្រេចបាន ។ ដើម្បីបញ្ជាក់ថា ប៉ុល ពត សម្រេចនៅពេលដែលមុននឹងបានឮអំពីការបង្កបង្កើតភូមិភាគនេះ ខ្ញុំឃើញ វន វេត គាត់ទៅរៀន តាម៉ុក ក៏ទៅរៀនមកវិញឮអារឿងបង្កើតភូមិភាគពិសេសនេះឯង ។

ដូច្នេះ សរុបមក ខ្ញុំគ្មានឯកសារទេ ក៏ប៉ុន្តែឈរលើព្រឹត្តិការណ៍បែបនេះ ហើយនិងសារសំខាន់នៃការបង្កើតភូមិភាគបែបនេះ វាទាល់តែ ប៉ុល ពត សម្រេចបានទៅរួច ។

**ស៖** ចំពោះលេខាភូមិភាគ តើអ្នកណាជាអ្នកទទួលបន្ទុកនៅភូមិភាគ? តើមុខងារជាក់លាក់របស់គេដូចម្តេចដែរ? តើមានសមាជិកក្នុងគណៈកម្មាធិការណាមួយក្នុងបក្សជាអ្នកទទួលបន្ទុក ឬយ៉ាងម៉េច?

**ឆ៖** ខាងគណៈកម្មាធិការភូមិភាគពិសេសគឺ វន វេត។ បន្ទាប់មក គឺមានសមាជិកពីរនាក់ទៀតគឺ ចេង អន និង នង សួន ។ ចេង អន គាត់ជាលេខាតំបន់១៥ ហើយបង នង សួន ហើយបងនង សួន ជាលេខាតំបន់២៥ ។

**ស៖** តើ វន វេតមានមុខងារអ្វីផ្សេងទៀតទេនៅក្នុងបក្សនោះ?

[១៥:០៨:៥០]

**ឆ៖** វន វេត ជាសមាជិកមជ្ឈិមពេញសិទ្ធិ ។ ក៏ប៉ុន្តែ ខ្ញុំមិនទាន់ដឹងច្បាស់ថាពេលនោះបង វ៉ន គាត់ចូលអចិន្ត្រៃយ៍ហើយនៅ មិនដឹងច្បាស់ ។ ខ្ញុំមិនទាន់ដឹងច្បាស់ បងវន ជាសមាជិកអចិន្ត្រៃយ៍ *(និយាយភាសាបារាំង) "កុម្មុយតេទ័កណង់ ឌឺកុម្មុយតេសង់ត្រាល់", "កុម្មុយតេទ័កណង់ ឌឺកុម្មុយតេសង់ត្រាល់ សេណេតេប៉ាល់ អ្វហ្គូវង់ កឺប៉្រឺវ៉ន តេតេដេសាម័ម ព័កម៉ាន់ឌឺកុម្មុយនិស្ត"* ។

**ស៖** សមាជិកអចិន្ត្រៃយ៍របស់គណៈមជ្ឈិមបក្សដែរឬទេ នៅពេលនោះ? តើពេលណាដែលលោក បានដឹងថា គាត់បានក្លាយនៃគណៈចិន្ត្រៃយ៍នោះ?

**ឆ៖** កន្លែងមជ្ឈិមក្រោយ១៩៧៥ ខ្ញុំដឹងថា បងវ៉ន ជាសមាជិកអចិន្ត្រៃយ៍ ក្រោយឆ្នាំ១៩៧៥ គឺក្រោយខ្ញុំមកកាន់ការនៅ ក្រោយពីខ្ញុំមកកាន់ការនៅស-២១ ។

**ស៖** ដូច្នេះថ្ងៃនេះ លោកបានប្រាប់យើងថានូវការកាត់ទោសមួយចំនួន ដែលថាតាំងរហូតមកដល់៧៥ អ៊ីចឹងហើយលោកមិនបានដឹងពីមុខងារជាក់លាក់របស់ វន វេត នៅក្នុងគណៈអចិន្ត្រៃយ៍ ឬ អំពីនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា តើកាលនោះពិតអ៊ីចឹងដែរឬទេ?

**ឆ៖** រឿងនេះ មិនមានអ្នកណាប្រាប់ថាគាត់ចូលជាអចិន្ត្រៃយ៍ហើយ ឬនៅទេ ក៏ប៉ុន្តែតាម--ក៏ប៉ុន្តែជាក់ស្តែងគឺគាត់ជាសមាជិកមជ្ឈិមពេញសិទ្ធិរួចទៅហើយ ។

**ស៖** អ៊ីចឹងលោកបានប្រាប់យើងថា នៅក្នុងការអនុវត្តលោកបានដឹងថាគាត់ជាសមាជិកនៃគណៈមជ្ឈិម ប៉ុន្តែមិនដឹងច្បាស់ថាជាសមាជិកនៃគណៈអចិន្ត្រៃយ៍នោះ ។

**ឆ៖** បាទ, អ៊ីចឹងមែន ។

ស៖ ឥឡូវក្រៅពី វន វ៉េត ថាតើអ្នកផ្សេងទៀតដែលជាមនុស្សសំខាន់ៗ ដូចជា ជាមនុស្សដែលជាអ្នកមើលខុសត្រូវ ឬនៅក្នុងមន្ទីរម-១៣ នោះមានអ្នកណាខ្លះ?

[១៥:១៣:៤៧]

**ឆ៖** ការងារមានពីរ, ការងារបក្ស កន្លះខែម្តងខ្ញុំទៅប្រជុំជីវភាព ដែលហៅថា "យើងប្រជុំជីវភាព" នេះគឺទៅធ្វើទិតៀននិងធ្វើស្វ័យទិតៀនជាមួយនឹងអ្នកផ្សេងទេ គឺជាមួយនឹងលេខាសាខា ។ ដើម្បីទិតៀន និងស្វ័យទិតៀន ។ ឯចំណែកការងារនគរបាលវិញ គ្មានអ្នកណាប៉ានមកណែនាំខ្ញុំទេក្រៅអំពីវន វ៉េត ហើយខាងភូមិភាគនិរតីក្រៅពី តាម៉ុក ហើយនិងបងស៊ី, ជូ ជេត នោះ ។

**ស៖** តើ សុន សេន មានតួនាទីអ្វីជាក់លាក់នៅក្នុងមន្ទីរម-១៣ ដែរឬទេ?

ឆ៖ ដើម្បីច្បាស់លាស់ ខ្ញុំសូមជម្រាបលោកចៅក្រមអំពីប្រវត្តិលោកគ្រូ សុន សេន ។ ឆ្នាំ១៩៧០ លោកគ្រូ សុន សេន គាត់ជាលេខាភូមិភាគឦសាន *"បឹនរ៉េដេស"* គាត់ជាលេខាភូមិភាគឦសាន ។ ដល់បន្ទាប់មកគាត់ចុះមកជាមួយ ប៉ុល ពត គាត់មកជាសហប្រធាន ភូមិភាគនិរតីជាមួយ កុយ ធួន ប្រធានភូមិភាគឧត្តរមិនមែននិរតីទេគឺឧត្តរខ្ញុំច្រឡំមាត់ ។ គាត់ចុះពីឦសានមកចុះមកធ្វើជាសហប្រធានភូមិភាគឧត្តរជាមួយនឹង កុយ ធួន ។ *"ឡាសូនឌុយន័រ កូប្រេស៊ីដង់ដឺឡាសូន ឌុយន័រ"* ជាមួយ កុយ ធួន ។

ហើយដល់ឆ្នាំ១៩៧៣ ឬក៏ដើមឆ្នាំ--ចុងឆ្នាំ១៩៧៣ គាត់ទៅភូមិភាគពិសេស ។ គាត់ទទួលភារៈអនុលេខាភូមិភាគពិសេស ។ ហើយក្នុងឋានៈគាត់ជាអនុលេខាភូមិភាគពិសេសនេះ គាត់គ្រប់គ្រងពីលើតំបន់១៥ផង ហើយនិងគ្រប់គ្រងកម្លាំងសម្ងាត់ក្រុងភ្នំពេញផង ។ សូមបញ្ជាក់ជូនលោកចៅក្រមលើសសំណួរលោកមួយម៉ាត់ទៅទៀត សូមជូនជាការសង្កេតថានៅពេលនោះ ប៉ុល ពត, នួន ជា ហើយនិងខៀវ សំផន ទៅបោះទីតាំងមន្ទីរសម្ងាត់មួយនៅភូមិច្រកស្បាច់ ឃុំពាម ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។ សរុបមក សុន សេន គាត់មកជាអនុលេខាភូមិភាគពីចុង១៩៧៣ នៅពីក្រោយខ្នងគាត់មាន

ប៉ុល ពត នៅភូមិច្រកស្បាច់ ។

**ស៖** ការិយាល័យពិសេសនេះស្ថិតនៅក្នុង តើកន្លែងនោះនៅក្នុងភូមិភាគពិសេស ឬក៏នៅក្រៅភូមិភាគពិសេសទេ ការិយាល័យសម្ងាត់នោះ?

[១៥:១៩:១៥]

**ឆ៖** ឃុំពាម ជាមូលដ្ឋានបង្អែកបដិវត្តន៍យូរហើយ ជាទីតាំងវានៅក្នុងភូមិភាគនិរតី ក៏ប៉ុន្តែគេប្រគល់មកឲ្យភូមិភាគពិសេសគ្រប់គ្រងតាំងពី៧០ មកម្ល៉េះ ។ សូមទោសៗ តាំងពីឆ្នាំ១៩៧១ មកម្ល៉េះ ។

**ស៖** តើអ្វីជាទំនាក់ទំនងរវាង ម-១៣ ហើយនិងការិយាល័យពិសេសនេះ តើគោលបំណងសំខាន់របស់ការិយាល័យពិសេសគឺអ្វីខ្លះ ?

**ឆ៖** ខ្ញុំត្រឹមតែឮដំណឹងទេ ពីរឿងអាមន្ទីរសម្ងាត់របស់គេនេះ ។ ខ្ញុំគ្រាន់តែឮគេខ្សឹបខ្សៀវមួយម៉ាត់មួយកពី *ប៉ុយរ៉ូ ស៊ីគ្រេ ស៊ីក្រែត ឡូហ្វីស ស៊ីក្រែត ឌឺ ប៉ុល ពត* ។ ខ្ញុំអត់ដែលបានទៅជាន់ដីហ្នឹងទេ ហើយឮថាខ្សឹបខ្សៀវគ្នាមួយម៉ាត់មួយកទេ អត់មានអីជាផ្លូវការទេ ។ ដូច្នេះៗ ខ្ញុំនៅឆ្ងាយពីការិយាល័យសម្ងាត់របស់ ប៉ុល ពត នេះណាស់ ។ មេខ្ញុំដែលខ្ញុំចុះឡើងទាក់ទង គឺមានតែ សុន សេន ទេ ។

**ស៖** តើមន្ទីរម-១៣ នោះស្ថិតនៅកន្លែងណា ? ដោយជាក់លាក់នៅក្នុងទីតាំងណា ដោយជាក់លាក់ ? នៅក្នុងអង្គភាពរបស់ ម-១៣ ឬក៏ តើមានអង្គភាពអ្វីច្រើនទេ បើមានតើនៅកន្លែងណាខ្លះ ?

**ឆ៖** អ៊ឹមត្រី (M-13) សូមទោស ម-១៣ ។ មានតែ ម-១៣ “ក” ដែលខ្ញុំគ្រប់គ្រងដោយផ្ទាល់ និងម-១៣ “ខ” ដែលអនុប្រធានរបស់ខ្ញុំគេគ្រប់គ្រង ។

មន្ទីរ ម-១៣ “ខ” នេះបោះទីតាំងនៅ ស្តុកស្រោត ឃុំស្តុកគោល ហើយស្រុកកាលនោះ គេហៅថាស្រុកអង្គស្នួល តំបន់១៥ ។ តាំងពី-- ខ្ញុំសូមអនុញ្ញាតឲ្យកកើតមន្ទីរ១៣ “ខ” ពេលណាមក មន្ទីរ១៣ “ខ” នៅទីនោះរហូត ។ ឯចំណែកមន្ទីរ១៣ “ខ” សូម ទោសមន្ទីរ១៣ “ក” ដែលខ្ញុំគ្រប់គ្រងផ្ទាល់ប្តូរកន្លែងច្រើន ។ កន្លែងដំបូង គឺអន្លង់វែង, ថ្នូរគប់ ឃុំអមលាំង កន្លែងនេះហើយដែល *ប៊ីហ្សូ* គាត់ទៅជាប់ ។

ហើយបន្ទាប់មកខ្ញុំផ្លាស់ទីតាំងទៅនៅកន្លែងមួយឈ្មោះ ទួលស្វាយមាស ឬក៏ហៅថា តាលាវសម្រាប់ធ្វើស្រែ ។ ប៉ុន្តែ ដល់មានការបះបោរអ្នកទោសរត់ អស់មួយសាទៅ ។ ខ្ញុំផ្លាស់ទីតាំងមកនៅក្បែរ ត្រពាំងច្រាប ។ ត្រពាំងច្រាប នេះហើយជាទីតាំងចុង ក្រោយបំផុតរបស់ ម-១៣ “ក” ។

សរុបមកមន្ទីរ១៣របស់ខ្ញុំមានតែពីរទីតាំងទេ មានតែពីរកន្លែងទេ មានតែពីរសាខាទេ ។ សាខាទីមួយ គឺអ៊ុម ម-១៣ “ក” របស់ខ្ញុំ ដែលផ្លាស់កន្លែងបីលើក ។ ឯចំណែកមន្ទីរ ម-១៣ “ខ” នៅស្រុកស្រោត ជារៀងរហូត ។

**ស៖** ទាក់ទងទៅនឹងចំណុចហ្នឹង ថាតើៗលោកបានពិចារណាបង្កើតអង្គភាពពីរហ្នឹង ម-១៣ “ក” និង “ខ” តើហេតុអ្វីបានជាមានពីរ ម៉េចក៏មិនមានតែមួយនៅពេលនោះ ?

**ឆ៖** ប៉ុន ប្រគល់ឲ្យខ្ញុំកាន់កាប់ មន្ទីរ-១៣ គ្មាន ១៣ “ក” គ្មាន ១៣ “ខ” ទេ ។ ក៏ប៉ុន្តែ ខ្ញុំសង្កេតឃើញមនុស្សមួយចំនួនត្រូវដោះលែង។ ដូច្នេះ យកអ្នកដោះលែងទៅឲ្យឆ្ងាយពីអ្នកដែលនៅជាប់ ហើយកម្ទេច ។ ដោយសារយល់ដល់បញ្ហានេះហើយ បានជាខ្ញុំសុំអនុញ្ញាតមេខ្ញុំ បងវន គាត់យល់ព្រមឲ្យបោះទីតាំងមួយទៀត ។ ហើយយកអនុប្រធានរបស់ខ្ញុំ គឺមិត្ត ស៊ុំ ឈ្មោះដើម ហូ គឹមអេង យកទៅធ្វើជាប្រធាន ឈ្មោះដើម ហូ គឹមអេង ។

**ស៖** ដូច្នេះបើខ្ញុំយល់ច្បាស់ពីដំបូង គឺថាមានមន្ទីរតែមួយទេហៅថា ម-១៣ ។ មន្ទីរមួយនេះឯងដែលមានអ្នកជាប់ឃុំត្រូវបានដោះលែង ប៉ុន្តែវាមានទម្រង់នៃការដោះលែងនោះខុសគ្នា ។ នៅក្នុងគំនិតនេះ ខ្ញុំមិនយល់ច្បាស់ទេ ។ លោកបាននិយាយថា គេត្រូវតែដោះលែង គឺត្រូវតែយកទៅកន្លែងឆ្ងាយមួយទៀត ហើយត្រូវសម្លាប់កន្លែងនោះ ? តើនេះជាគំនិតដែលលោកនិយាយអ៊ីចឹង ឬក៏ខ្ញុំស្តាប់ទៅច្រឡំ ?

**ឆ៖** *អឹមម៉ាណោឡាវ៉ាន់ អឹមម៉ាណោឌឺ ឌូ (គ្មានការបកប្រែ)* ។

**ស៖** នៅពេលដែលខ្ញុំសួរសំណួរលោកទាក់ទងទៅនឹងការមានមន្ទីរពីរ ឬបីខុសគ្នា លោកបានប្រាប់ យើងថាពីចំណុចដំបូង គឺថាមានមន្ទីរតែមួយទេ ។ ប៉ុន្តែ មានអ្នកឃុំខ្លួនមួយចំនួនត្រូវបានដោះលែង ហើយការដោះលែងនោះមានន័យដូចម្តេច ? តើការដោះលែងឲ្យមានសេរីភាព ឬក៏ៗដោះពីហ្នឹងយក ទៅសម្លាប់នៅកន្លែងណានោះ ?

[១៥:៣០:២០]

**ឆ៖** អ្នកដែលខ្ញុំដោះលែង គឺដោះលែងស្ពាតរ ព្រោះខ្ញុំមុននឹងដោះលែងទាល់តែបានការអនុញ្ញាតពីប្រធានភូមិភាគទេ ។ ច្បាស់លាស់ ។

**ស៖** តើមានអ្វីកើតឡើងលើអ្នកទោស ម-១៣ បន្ទាប់ពីពួកគេត្រូវបានយកមកសួរចម្លើយ ?

**ឆ៖** អ្នកណាដែលមើលទៅគ្មានលទ្ធភាពនឹងដោះលែង ការសួរចម្លើយតាមធម្មតាៗតែងតែមានទារុណកម្ម ដល់ចុងបញ្ចប់ គឺសុទ្ធតែត្រូវកម្ទេច ដល់ចុងបញ្ចប់គឺសុទ្ធតែកម្ទេច ។

**ស៖** ថាតើការសម្លាប់ គឺជាវិធាន ឬក៏ជាការលើកលែង ?

**ឆ៖** ការកម្ទេច វាជាគោលការណ៍សំខាន់ ឲ្យតែខាងភូមិភាគៗគេសម្រេចហើយ អាមន្ទីរនគរបាលនេះចាំតែទទួលសួរចម្លើយ ហើយកម្ទេច ។ ដូច្នេះ ការកម្ទេច ការកម្ទេចជាគោលការណ៍ដែលឋិតថេរ ទៀងទាត់ ។

**ស៖** លោកនិយាយប្រាប់យើងអំពីសាខាពីរ ។ លោកនិយាយអំពី ម-១៣ "ខ" គឺជាមន្ទីរនៅស្តុកស្រោត លោកបានជម្រាបយើងអំពី មន្ទីរ-១៣ "ក" ដែលមាននៅទីតាំងផ្សេងនៅពេលខុសគ្នា ថាតើមានមន្ទីរសន្តិសុខផ្សេងទៀតទាក់ទងទៅនឹង ម-១៣ ដែរឬទេ ? ប្រសិនបើមែននោះ ថាតើលោកបានឮអំពីមន្ទីរ-៩៩ ដែរឬទេ ?

**ឆ៖** ខ្ញុំទើបតែនឹងឃើញនៅក្នុងសៀវភៅ *ឌឹឡូស អិចហ្សៀហ្វីស ហ្សីនន័រ* ខ្ញុំចេះតែឆ្ងល់អាម-៩៩ ហ្នឹងស្អី ។ ដល់ឥឡូវតាមដានឯកសារចុះឡើងៗឃើញថា អា ម-៩៩ នេះ ពីលើកមុនខ្ញុំធ្លាប់ហៅថាមន្ទីរនគរបាល ។ ខ្ញុំគ្រាន់តែបានមើលឯកសារហូរហែមក ខ្ញុំដឹងថាអាម-៩៩ នេះរបស់ដែលខ្ញុំធ្លាប់ហៅថា គឺរបស់ដែលខ្ញុំធ្លាប់ហៅថា មន្ទីរនគរបាល តំបន់-៣២ ។ អង្គភាពពីរនេះដាច់ពីគ្នាទាំងស្រុង ។

**ស៖** តើព័ត៌មានពិស្តារអ្វីទៀតលោកចង់ប្រាប់យើង ដែលពាក់ព័ន្ធទៅនឹងដំណើរការរបស់ ម-១៣?

**ឆ៖** មន្ទីរ១៣ ទីមួយវាទទួលមនុស្សដែលគេសម្រេចចាប់យកមកសួរចម្លើយ ។ យកមកសួរចម្លើយ បើកាលណាសួរចម្លើយហើយកម្ទេច ។ នេះជាការងាររបស់មន្ទីរ-១៣ "ក" ។ ឯចំណែកមន្ទីរ-១៣ "ខ"ទទួលមនុស្សដែលគេប្រគល់មកឲ្យអប់រំ មួយរយៈគេឲ្យដោះលែងៗទៅលែងទៅវិញ ។

**ស៖** តើលោកអាចពិពណ៌នាអំពីលក្ខខណ្ឌនៃការឃុំខ្លួននៅមន្ទីរ ម-១៣ ដែរឬទេ?

**ឆ៖** វេទនាភ្នែកខ្លាំងណាស់ ថ្នាំសង្កូវក៏អត់ ។ ចុងបញ្ចប់នៅឆ្នាំ១៩៧៤ ពួកនោះហូបសុទ្ធតែកន្ទក់ទេ នេះជារឿងពិត ។ កុំថាតែពួកអ្នកដែលជាប់ឃុំឃាំង សូម្បីតែកម្មាភិបាលដូចខ្ញុំខ្លួនឯងហ្នឹងក៏ពេលខ្លះមិនមានបាយហូបផង ហូបតែដំឡូងជ្វា ដំឡូងមី ហូបក្តួច ។ នេះខ្ញុំសូមនិយាយតែមួយផ្នែកទេ ។ ហើយអាការដាក់ខ្នោះជើងទាំងយប់ ទាំងថ្ងៃហើយ ទាំងស្រី ទាំងប្រុស ។ ហើយនៅពេលដែលមានអាបេចាស់ហ្នឹង នៅពេលមាន បេ-៥២ ផងត្រូវជីករណ្តៅជម្រៅប្រហែលជាពីរម៉ែត្រ ទទឹងប្រហែលជាពីរម៉ែត្រអីដែរ បណ្តោយប្រហែលជាបីម៉ែត្រ គ្របដំបូលពីលើ ។ ដូច្នេះ រណ្តៅរបស់ខ្ញុំនៅ ម-១៣ "ក" នេះប្រហែលជាបីរណ្តៅមានស្រី មានប្រុស ។ ពីររណ្តៅ ឬបីរណ្តៅទេ ខ្ញុំភ្លេចហើយ ។ មានស្រីមាន

ប្រុស។

ដូច្នេះ លក្ខណៈសម្បត្តិនៃការឃុំខ្លួន វាលែងនិយាយ ។ ពិបាកលែងនិយាយហើយ ។ អមនុស្សធម៌វាផុតលេខ ។

[១៥:៣៨:១៧]

**លោក ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំនឹងអានពីកំណត់សម្គាល់មួយ ដែលបានភ្ជាប់នៅក្នុងកិច្ចសម្ភាសន៍ថ្ងៃ៣ ខែតុលា ២០០៧ នៅក្នុងឯកសារ D៧១ ។ លោកនិយាយអំពីកថាខណ្ឌមួយដែល គឺនិយាយអំពីការភ័យខ្លាចលើរូបខ្ញុំ ។ ហើយលោកនិយាយដូចខាងក្រោម៖

នៅក្នុង តំបន់-២៥ គឺកន្លែងដែលមនុស្សសន្តិសុខធ្វើការងារ គឺយើងហៅថា “សាខាពិសេស” ។ ហើយខ្ញុំស្អប់ការសម្លាប់ ប៉ុន្តែខ្ញុំនៅតែ-- គឺជាការទាក់ទងទៅនឹងសេចក្ដីបង្គាប់របស់បក្ស ។ នៅក្នុងមន្ទីរ ម-១៣ គឺខ្ញុំស្អប់ដូចអាចម៍ ហើយខ្ញុំត្រូវតែដើរទៅមន្ទីរនេះ ។ ការវ៉ៃនិងវិធីសាស្ត្រផ្សេងៗ គឺការសម្លាប់ដោយការចងក នេះ គឺមិនល្អទេ ។ ខ្ញុំមិនប៉ានធ្វើការតតាំង ដូចដែល ហ៊ូ យន់ បានធ្វើឡើងនៅពេលដែលប្រឈមមុខជាមួយនឹង តាម៉ុក និង ប៉ុល ពត ។ ខ្ញុំព្យាយាមដោះស្រាយបញ្ហាដោយខ្លួនខ្ញុំផ្ទាល់ នេះមានន័យថា ជាបឋមធានា ខ្ញុំអាចស្វែងរកការពិត និងអាចយកចម្លើយសារភាព ។ ប៉ុន្តែ ខ្ញុំមិនអាចគ្មានវិធីណារកការពិត ដែលវាធ្វើឲ្យខ្ញុំភ័យខ្លាចនៅពេលដែលខ្ញុំរាយការណ៍ចម្លើយដែលមាននៅក្នុងចម្លើយសារភាព ។

ហើយទីពីរ ខ្ញុំសួរ វន វ៉េត ឲ្យដោះបុគ្គលដែលបញ្ជូនមក ។ ខ្ញុំអាចដោះលែងតែប្រាំបីនាក់ទាំងអស់នោះតែប្រាំបីទេ ។ ខ្ញុំចាំឈ្មោះប្រាំមួយ ។

ហើយទីបី ខ្ញុំត្រូវបានគេសុំឲ្យចាត់តាំងឲ្យបំបែក ម-១៣ ជាពីរ ។ ទីមួយ គឺ ម-១៣ “ខ” ។ “ក” នៅជើងភ្នំ ដែលអ្នកទោសត្រូវបានបញ្ជូនទៅដាំស្រូវ ហើយមានការលួចរត់ អ្នកទោសអាចលួចរត់ ។

ហើយទីពីរ គឺមន្ទីរ “ខ” នៅស្រុកស្ដុកស្រោត ឃុំស្ដុកគោល ដែលគេទុកអ្នកទោសសម្រាប់រយៈពេលមួយចំនួនមុនពេលដោះលែង ។

ហើយចំណុចទីបួន ដូចដែលខ្ញុំបានធ្វើច្រើនយ៉ាងខ្លាំង ដើម្បីស្វែងរកការពិត ។ តាម៉ុក គឺគាត់ខឹងនឹងខ្ញុំទាក់ទងទៅនឹង ខាម ប្រាក់សុន ហៅ ឌុ-- ដែលគាត់មកពីហាណូយ ហើយខ្ញុំក៏បានសុំឲ្យមានការ

ដោះលែងអ្នកពីនិរតី វាពិបាកចំពោះខ្ញុំ ហើយអ្នកដែលដោះលែងឈ្មោះ ហាម ហ៊ីន ។

**ស៖** ថាលោកចង់បញ្ជាក់ទៅលើចម្លើយដែលខ្ញុំដកស្រង់នេះដែរ ឬទេ? តើលោកមានយោបល់អ្វីលើកឡើងទាក់ទងនឹងបញ្ហាហ្នឹងដែរ ឬទេ?

**ឆ៖** សូមបញ្ជាក់តែមួយម៉ាត់ទេ ។ ពាក្យថា មន្ទីរ ១៣ "ក" ដែលលោកចៅក្រមអាចមិញនេះ "*អ៊ុមត្រីស្សុកា*" ដែលយើងនៅពេលនេះ យើងហៅថា "*អ៊ុមត្រីស្រះអា*" ឯចំណែក "*អ៊ុមត្រី*" មន្ទីរ១៣ "ខ" ដែលលោកចៅក្រមអាចមិញហ្នឹង គឺ "*អ៊ុមត្រីស្សុកាអាស*" ។ "*កាអាស*" ហ្នឹង គឺ "ខ" ដែល "*កូវ៉េស្តុង*" ហ្នឹង អក្សរ "*បេ*" ដែលជា "*អ៊ុមត្រីបេ*" ក្រៅពីនោះ ខ្ញុំរក្សាសេចក្តីប្រកាសរបស់ខ្ញុំ ។ បញ្ជាក់គោលជំហររបស់ខ្ញុំជូនចៅក្រមស៊ើបអង្កេតទាំងអស់ ។

[១៥:៤៣:៣៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកសហព្រះរាជអាជ្ញា ។

**លោក រ៉ូប៊ឺត ពើទីត៖**

ខ្ញុំសូមអភ័យទោស ។ រាល់ពេលដែលជនជាប់ចោទ គាត់និយាយហើយ គាត់កាច់ទៅប៉ុស្តិ៍ផ្សេង គឺមានការបាត់បង់ចំពោះការបកប្រែ។ បានន័យថា យ៉ាងហោចណាស់កំណត់ហេតុសវនាការរបស់យើង គឺមិនមានការកត់ហេតុ កត់បានត្រឹមត្រូវនោះទេ នៅក្នុងតុលាការផ្សេងៗ ដូចជានៅក្នុងតុលាការផ្សេងៗ ប្រសិនបើភាគី ឬក៏សាក្សី ឬក៏បុគ្គលណាមួយគាត់ចង់ធ្វើការផ្លាស់ប្តូរភាសារបស់គាត់ គាត់ត្រូវតែជម្រាបអ្នកបកប្រែ ប្រសិនបើមិនអ៊ីចឹងទេ គឺនឹងមានការបកប្រែបាត់នូវខ្លឹមសារ ។ នេះវាកើតឡើងដូចទៅនឹងការឆ្លើយតបរបស់ជនជាប់ ដែលធ្វើឡើងនៅពេលនេះ ជាពិសេសនៅក្នុងភាសាអង់គ្លេស ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក ហ្សង់ម៉ាក ។

**លោក ហ្សង់ម៉ាក ឡាវែន៖**

ដើម្បីធានាថា មិនមានការយល់ខុស សូមឲ្យបញ្ជាក់ ឬក៏ឆ្លើយឡើងវិញ ដែលបានផ្តល់អម្បាញ់មិញ ។

**ស៖** ខ្ញុំសួរលោកថា លោកមានយោបល់យ៉ាងម៉េចទាក់ទងទៅនឹងអត្ថបទដែលខ្ញុំបានអានអម្បាញ់មិញ? ជាពិសេស ការលើកឡើងរបស់លោក ដែលចង់លើកឡើងអំពីការងារ ដែលលោកបានធ្វើនៅ ម-

១៣ ? ហើយលោកនឹងត្រូវផ្តល់យោបល់ ចំពោះបញ្ហាហ្នឹង ដែលយើងបានលើកឡើងជាមុន ។

**ឆ៖** ខ្ញុំមិនទាន់យល់សេចក្តីអធិប្បាយរបស់លោកសហព្រះរាជអាជ្ញានៅឡើយប៉ុន្មានទេ ហើយក៏មិនទាន់យល់សេចក្តីសួរបញ្ជាក់របស់លោកចៅក្រមប៉ុន្មានដែរ? សូមមេត្តាឲ្យខ្ញុំបានយល់ស្រួលបួល ។

[១៥:៤៦:២០]

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញាឡើងបញ្ជាក់ម្តងទៀត ដើម្បីជម្រាបជូនដល់ជនជាប់ចោទ ។ ដើម្បីលោកយល់ជ្រួតជ្រាបអំពីគោលបំណងនៃការលើកឡើងរបស់លោកសហព្រះរាជអាជ្ញា ។

**លោក រ៉ូប៊ឺត ពើទីត៖**

អរគុណ ។ ខ្ញុំនិយាយថា ប្រសិនបើបុគ្គលណាម្នាក់ គាត់ចង់ប្តូរភាសានិយាយក្នុងអំឡុងពេលការផ្តល់សេចក្តីសន្និដ្ឋាន ឬការលើកឡើងនៅពេលដែលគាត់និយាយនោះ អ៊ីចឹង ចាំបាច់គឺបញ្ហាប្តូរភាសានឹងមានការបាត់ខ្លឹមសារក្នុងការបកប្រែ ។

ឧទាហរណ៍ថា ជនជាប់ចោទចាប់ផ្តើមឆ្លើយភាសាខ្មែរ ហើយបន្ទាប់មកគាត់ប្តូរទៅជាភាសាបារាំង និងមានការខ្វះចន្លោះ និងការបកប្រែដែលមិនអាចតាម ។

ដោយសារបញ្ហានេះ គឺកំណត់ហេតុសវនាការនៅចុងពេលបញ្ចប់សវនាការនឹងមិនមានការកត់ត្រាពេញលេញ និងត្រឹមត្រូវ ។ ដូច្នេះ ខ្ញុំស្នើថា ដើម្បីនៅក្នុងដំណាក់កាលនេះ គឺសូមឲ្យជនជាប់ចោទគឺនិយាយតែមួយភាសា គឺភាសាខ្មែរ ប្រសិនបើអាចធ្វើទៅបាន ។ ហើយមិនអាចឈប់ ហើយនិងព្រមានអ្នកបកប្រែជំពោះការផ្លាស់ប្តូរភាសានោះទេ ដើម្បីកុំឲ្យមានចន្លោះនៃការបកប្រែ ។

ដូច្នេះខ្ញុំសូមរំឭកទៅលើបញ្ហានេះ ។ យើងអត់មានអ្នកបកប្រែភាសាបារាំង ភាសាបារាំងទៅខ្មែរ និងបារាំងទៅខ្មែរ ហើយនិងអង់គ្លេសនោះទេ ។

ដូច្នេះ ហើយយើងត្រូវគិតថា ការដូរភាសាផ្សេងៗ វាអាចនឹងបង្កើតជាបញ្ហាចំពោះការបកប្រែ ។ ខ្ញុំសង្ឃឹមថា ខ្ញុំបានលើកឡើងច្បាស់លាស់ទៅលើបញ្ហានេះ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក ហ្វ្រង់ស្វ័រ រូ ។

[១៥:៤៨:៣២]

**លោក ហ្វ្រង់ស្វ័រ រូ៖**

អរគុណលោកប្រធាន ។ គ្រាន់តែជាការបំភ្លឺជនជាប់ចោទ គឺគាត់មិនបានផ្លាស់ប្តូរភាសារបស់គាត់ទេ ។ គាត់ព្យាយាមធ្វើការកែតម្រូវកំហុសនៅក្នុងភាសាបារាំង ដែលបានអានដោយចៅក្រម ឡាវែន៍ នៅក្នុងឯកសារភាសាបារាំងដែលអាចដោយចៅក្រម ឡាវែន៍ ។ ម-១៣ "ក" គឺបាននិយាយ ហើយជនជាប់ចោទបានបញ្ជាក់ថា ម-១៣ "ក" គឺ ម-១៣ "ក" ។ អក្សរ "កា" (K) ហ្នឹង គឺឆ្លើយតបទៅនឹងអក្ខរក្រម "ក" នៃភាសាឡាតាំង គឺ "អា" (A) ដូច្នេះហើយ ម-១៣ "កា" (K) នេះ ដែលប្រើអក្សរ "កា" (K) នៅពេលនោះ ។ ជនជាប់ចោទបានបញ្ជាក់ថា ហើយ ម-១៣ "កាហាស" (KH) នោះគឺជនជាប់គាត់បញ្ជាក់ថា វាជា ម-១៣ "ខ" ដូច្នេះហើយគាត់មិនមែនជា-- ផ្លាស់ប្តូរភាសាទេ ។ គាត់ចង់ធ្វើការបញ្ជាក់ទៅលើឯកសារ និងភាសាបារាំង ដែលលើកឡើងនោះទេ ។

នៅពេលដែលយើងនិយាយអំពី ម-១៣ "កា" (K) នោះ យើងសំដៅទៅលើ ម-១៣ "ក" ហើយនៅពេលដែលយើងនិយាយអំពី "អ៊ុម-១៣ កាហាស" (KH) គឺយើងសំដៅលើ ម-១៣ "ខ" ។ នេះគឺជាមន្ទីរសាខា ម-១៣ ដែលយើងបានពិភាក្សាក្នុងរសៀលនេះ ។

**ប្រធានអង្គជំនុំ៖**

លោកសហព្រះរាជអាជ្ញាមាន--

**លោក រ៉ូប៊ីត ពើទីត៖**

អរគុណលោកប្រធាន ប៉ុន្តែក្នុងការផ្តល់ចម្លើយថ្ងៃនេះជនជាប់ចោទបានឆ្លើយមួយផ្នែកជាភាសាបារាំង ហើយយើងឃើញមានការចន្លោះបកប្រែ ដូច្នេះហើយខ្ញុំសូមលើកយោបល់ថា ជនជាប់ចោទ ឬបុគ្គលណាក៏ដោយគួរតែនិយាយតែមួយភាសា ។ ហើយឲ្យមានការបកប្រែឲ្យតាមតែមួយភាសាតាមតែគាត់និយាយដើម្បីឲ្យមានការបកប្រែ និងការកែប្រែត្រឹមត្រូវទៅលើបញ្ហានេះ។ សូមអរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៥២:៣៨]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ការកត់សម្គាល់របស់សហព្រះរាជអាជ្ញាលើកឡើងនេះគឺជាការសមរម្យ ហើយគួរតែត្រូវបានកែលម្អដោយហេតុថា នៅក្នុងអំឡុងពេលតែមួយជនជាប់ចោទលោកតែងតែប្រើភាសាពីរ ដោយមានតែភាសាខ្មែរផង ហើយភាសាបារាំងផង។ ដូច្នេះ គឺអង្គជំនុំជម្រះសូម

ជម្រាបទៅលោក កាំង ហ្គេកអ៊ាវ ជាជនជាប់ចោទថា អំណឹះតទៅគឺលោកត្រូវប្រើប្រាស់ភាសាមួយក្នុងចំណោមភាសាពីរនេះឲ្យបានច្បាស់លាស់ ដោយលោកប្រើប្រាស់ភាសាខ្មែរក្នុងករណីលោកមានបំណងចង់ឆ្លើយឬក៏បញ្ជាក់នឹងសំណួរផ្សេងៗជាភាសាបារាំងថែមទៀតនោះ សូមលោកសុំជាមុនដើម្បីអង្គជំនុំជម្រះសម្រេចឲ្យលោកប្រើប្រាស់ជាភាសាបារាំងក្នុងលក្ខខណ្ឌជាក់លាក់ណាមួយ ដើម្បីបង្កសម្រួលដល់ខាងអ្នកបកប្រែភាសា ដើម្បីឲ្យគាត់មានឱកាសក្នុងការបកប្រែភាសាហ្នឹងបានច្បាស់លាស់ សូមអញ្ជើញលោក ហ្សង់ម៉ាកឡាវែន៍ បន្តទៀត។

**ចៅក្រម ហ្សង់ ម៉ាកឡាវែន៍៖**

**ស៖** តើលោកអាចជម្រាបយើងបានដែរឬទេ អ្វីដែលខ្ញុំបានអានអម្បាញ់មិញនេះ គឺវាទាក់ទងទៅនឹង ផ្នែកការងាររបស់លោកដែលលោកបានធ្វើនៅម-១៣ តើលោកពេញចិត្តនឹងការងារទាំងអស់នេះដែរឬទេ?

**ឆ៖** ខ្ញុំសូមជម្រាបលោកចៅក្រមថា នៅពេលដែលលោកអានសេចក្តីប្រកាសរបស់ខ្ញុំ អាប្រដាប់ខ្ញុំ ស្តាប់នេះ មិនសូវឮដាច់មួយកំណាត់ ខ្ញុំឮនៅខាងចុង ។ នេះជារឿងពិត ។ ក៏ប៉ុន្តែ បើនិយាយពីឲ្យ ខ្ញុំឆ្លើយបញ្ជាក់ជូនលោកក្នុងពេលនេះថាតើខ្ញុំពេញចិត្តនឹងការងារនេះ? ខ្ញុំអត់ពេញចិត្តទេ តែជៀសវាមិនរួច ត្រូវតែធ្វើ ។ ខ្ញុំយកលេសសុំ វន វ៉េត ឲ្យដាក់ទោសដល់ខ្ញុំ ដោយសារពួកអ្នកជាប់ឃុំឃាំងនៅនោះគេរត់គេច តែគាត់មិនព្រមដាក់ទោសខ្ញុំទៀត គាត់ចេះតែឲ្យអ្នកទោសមកមនុស្សមកឲ្យខ្ញុំឃុំឃាំង សួរចម្លើយ ហើយនិងកម្ទេច ។ ខ្ញុំមិនដឹងធ្វើម៉េច អើ! ទ្រាំទៅ វាសនាកំណត់មកអញ្ចឹង ។ ហើយខ្ញុំបានសូត្រកំណាព្យរបស់ *អាល់ហ្វ្រិនឌឺវិនញៀរ* ដែលមានចំណងជើងថា *ឡាម័រឌឺលូ* នោះទុកជាការលំហែសម្រាលក្នុងចិត្តរបស់ខ្លួន ។ នេះខ្ញុំ បានជម្រាបលោកចៅក្រមព្រឹកមិញហើយ ។

សរុបមកវិញចំពោះការងារនៅទីនោះខ្ញុំរកតែពេលចេញ តែចេញវាអត់រួច នេះជម្រាបលោកដោយត្រង់ ។

[១៥: ៥៦:១១]

**ស៖** នៅពេលលោកនិយាយថា លោកមិនអាចធ្វើអ្វីក្រៅពីហ្នឹង ថាតើលោកបានពិចារណានឹងធ្វើអ្វីផ្សេងក្រៅពីហ្នឹងដែរឬទេ?

តើលោកយល់សំណួររបស់ខ្ញុំដែរឬទេ? លោកបាននិយាយថាលោកត្រូវបានឲ្យធ្វើការងារហ្នឹងដែលលោកគ្មានជំរើស ដូច្នេះថាតើលោកបានពិចារណាធ្វើការងារផ្សេង ឧទាហរណ៍ថា រត់ចេញពី

ការងារទាំងអស់ហ្នឹងដែរឬទេ?

**ឆ៖** ខ្ញុំគ្មានបានគិតទៅដល់រកមធ្យោបាយអីផ្សេងទៀតក្រៅពីសុខចិត្តធ្វើតាមគេ ដើម្បីរស់តទៅទៀតប៉ុណ្ណោះទេ ។ អត់សោះ អត់មានបានគិតទៅរកមធ្យោបាយអីផ្សេងទៀតទេ ទ្រាំនៅហើយធ្វើតាមគេអ៊ីចឹង ។ ដឹងថាការងារនោះវាឧក្រិដ្ឋណាស់ហើយ តែមិនដឹងធ្វើម៉េច! ដូចខ្ញុំបាននិយាយអ៊ីចឹងទ្រាំទៅវាសនាវាមកអ៊ីចឹងទៅហើយ ។

**សៈ** តើលោកសង្កេតឃើញថា មានការផ្លាស់ប្តូរនៅក្នុងប្រភេទបុគ្គលដែលត្រូវបានគេចាប់ខ្លួនហើយបញ្ជូនទៅម-១៣ដែរឬទេ? ដោយសារតែនៅព្រឹកនេះលោកនិយាយអំពីគិញ ក្រៅពីគិញថាតើមានបុគ្គល ផ្សេងទៀតដែលត្រូវបានចាត់ទុកថាជាខ្មាំងដែរឬទេ? ថាបើសិនជាមានតើនរណាគេខ្លះ?

**ឆ៖** ដំបូងមានមែន មនុស្សដែលចូលមកពីដី លន់ នល់ ចូលមកក្នុងតំបន់រំដោះ ដែលគេហៅថាគិញ ក្នុងនោះក៏ខ្ញុំជឿថា មួយភាគតូចទេដែលគិញមែនទែន ។ គ្នាអ្នកក្រ ហើយគេចអាម៉េចមិនរួចបើមិនមកវាងាប់ អានោះគ្នាត្រូវតែមកអ៊ីចឹងហើយ មិនដឹងធ្វើម៉េចទេ ។ អានេះមួយផ្នែកទៅ ។ មួយផ្នែកទៀត ចាប់ផ្តើមមានបញ្ហាដូចខ្ញុំបានរាយការណ៍ជូនលោកចៅក្រមអ៊ីចឹង ។

វាមានរឿងទំនាស់គ្នា ទំនាស់នៅក្នុងភូមិនោះក៏មាន ទំនាស់ខាងការងាររណសិរ្សនៅឯខាងកប់ស្រូវនេះក៏មាន ម្ល៉ោះហើយខ្ញុំចេញមុខ ដោះស្រាយតាមលទ្ធភាពដែលខ្ញុំដោះស្រាយទៅបាន ដើម្បីសេចក្តីពិត ។ ក៏ប៉ុន្តែរឿងដែលគួរឲ្យតក់ស្លុតមែនទែន គឺការបោសសម្អាតនៅមូលដ្ឋានបង្អែក ឃុំអមលាំងនេះវាជាមូលដ្ឋានបង្អែក ការបោសសម្អាតមូលដ្ឋានបង្អែកនេះជាបញ្ហាមួយដែលធ្វើឲ្យពិបាកទ្រាំណាស់នឹកឡើងពេលណាវាខ្លោចផ្សាពេលហ្នឹង ។ ដូច្នេះ ប្រភេទមនុស្សវាមកអ៊ីចឹង ។ ទន្ទឹមនឹងនេះ ដូចខ្ញុំបានជម្រាបលោកចៅក្រមរួចព្រឹកមិញ ហើយ វាទំនាស់ក្នុងជួរទៅទៀត ដូចជាខាងតាម៉ុក ត្រូវបុគ្គល សង្ហាហឿន ដែលជាកូនសិស្សសំណព្វរបស់គាត់មកឲ្យនៅម-១៣ អត់ប៊ានអន្តរគមន៍ ។ ក៏ប៉ុន្តែ ខ្លួនគាត់ទៅរកចាប់កម្មាភិបាលហាណូយម្នាក់ដោយចោទគេថា បាញ់មិត្ត យ៉ាន ហើយបង្ខំឲ្យម-១៣ វ៉ៃសួរចម្លើយ ។ ខ្ញុំមិនធ្វើវាមានទោសទាំងខ្ញុំទៅទៀត ។ ដូច្នេះ ទំនាស់វាចាក់ស្រែះនៅក្នុងហ្នឹង រកផ្លូវណាឲ្យរកសេចក្តីពិតឲ្យឃើញវាមិនឃើញទេ ។ សរុបមក វិញខ្ញុំនៅនិយាយដដែលហ្នឹងថាខ្ញុំអត់មានបានគិតរកផ្លូវឯណាដោះស្រាយក្រៅពីសុខចិត្តធ្វើតាមគេនោះទេ ដោយសារខ្លាចស្លាប់ ។

**សៈ** គិញនេះ ឬសត្រូវទាំងអស់នេះ គឺជាបុរស ឬក៏ស្ត្រី ឬក៏ក្មេងៗ ចំពោះគិញទាំងអស់ហ្នឹង?

**ឆ៖** វាពិតណាស់ ។ ទំនាស់ផ្ទៃក្នុង ឬគេហៅថាគិញ គឺសុទ្ធតែជាមនុស្ស មនុស្សប្រុស មនុស្ស

ស្រី ។ ក៏ប៉ុន្តែនៅក្នុងពេលនោះចិត្តខ្ញុំ ខ្ញុំបានខំពុះពារចិញ្ចឹមក្មេងបីនាក់ដែរ ។ ផ្ទុយនឹងសេចក្តីណែនាំរបស់គេ ថាប្រយ័ត្នវាសងសឹក តែចិញ្ចឹមមិនរស់ ។ អើម៉្យាងដោយសារបញ្ហាលក្ខខណ្ឌជីវភាពនៅពេលនោះវាលំបាក ។ តែម្យ៉ាងទៀតខ្ញុំឃើញសំខាន់ លក្ខខណ្ឌជីវភាពប្រហែលគ្នាមែន ។ ក្មេងតូចៗចិញ្ចឹមខ្លះមនោសញ្ចេតនាមិនបានទេ ដល់ខ្ញុំរាយការណ៍រឿងបរាជ័យរបស់ខ្ញុំក្នុងការចិញ្ចឹមកូនក្មេង សុន សេនចាក់បណ្តោយៗទៅ ។ ខ្ញុំក៏សុខចិត្តចុះចាញ់គេខាងគោលជំហរជាមួយនឹងរឿងក្មេងហ្នឹងតាំងពីពេលនោះមក មិនហ៊ានតវ៉ាអីហ្នឹងគេតទៅទៀតទេ ។ ដូច្នេះ ឧក្រិដ្ឋកម្មធ្លាក់ទៅលើកូនក្មេងវាចាប់ប្រហែលពីឆ្នាំ១៩៧៤ម្ល៉េះ ។ ហើយនៅម-១៣ មានបីនាក់ប៉ុណ្ណោះ ។ ហើយមកច្រើននៅ ស-២១ នេះ ។ ជំហរខ្ញុំចំពោះរឿងកូនក្មេងនេះ វាចុះចាញ់គេវាខុសហើយ ។

**ស៖** ក្មេងបីនាក់ តើមានក្មេងប៉ុន្មាននាក់ដែលបានទៅដល់ម-១៣ ? ថាតើមានអ្វីកើតឡើងចំពោះក្មេង ទាំងអស់នោះ?

**ឆ៖** នៅជាក្មេងជំទង់ខ្ញុំបានដោះលែង និងក៏ជំនះជាមួយបង ឆាយ គឹមហ៊ា ដែរ គាត់ថាប្រយ័ត្នសង សឹក តែខ្ញុំថាមិនអីទេ ។ ក៏ដោះលែងទៅ ។ ឯចំណែក ក្រោយមកខ្ញុំឃើញក្មេងបីនាក់ហ្នឹងឯងដែលជាកូនរបស់មនុស្សម្នាក់ឈ្មោះសាំង អ៊ុន ។ ខ្ញុំទុកឪពុកឲ្យនៅថែរក្សាមិនដឹងម៉េច ក្មេងចូលទៅហ្នឹងវាមានតែឪពុកអត់ម្តាយ ។ ខ្ញុំភ្លេចទៅសភាពការណ៍កាលនោះ ។ តែខ្ញុំខំពុះពារចិញ្ចឹម ។ ចិញ្ចឹមវាមិនរស់ ។ ដូច្នេះ ក្មេងបីនាក់ហ្នឹង គឺជាក្មេងដែលចូលមកមន្ទីរ១៣ ហើយ ។ ហើយខំចិញ្ចឹមៗវាមិនរស់ ។ តាមខ្ញុំចាំគ្មាន ក្មេងឯណាទៀតក្រៅពីហ្នឹងទៀតទេ ។ សូមបញ្ជាក់ថានៅម-១៣ អត់មានបញ្ជីទេ ។ បើមានបញ្ជីគ្រាន់ បានរំឭកឃើញខ្លះ ។

**ស៖** ក្រៅពីក្មេងបីនាក់ហ្នឹង ថាតើមានក្មេងផ្សេងទៀតត្រូវបានគេឃុំនៅម-១៣ ដែរឬទេ? តើមានអ្វី កើតឡើងចំពោះក្មេងដែលត្រូវបានគេឃុំទាំងអស់នោះ?

**ឆ៖** ថាក្រៅពីក្មេងបីនាក់នេះ តាមខ្ញុំចាំគ្មានក្មេងណាម្នាក់ទៀតទេ ។ មានតែក្មេងជំទង់ម្នាក់ ដែលចូលមកដល់កាលពីឆ្នាំ៧១ ប្រហែលជាខែ៩ ខែ១០អីហ្នឹង ឆ្នាំ៧១ មានចូលក្មេងម្នាក់ជំទង់ហើយ ។ ក្រោយពីក្មេងជំទង់មករហូតមក គ្មានក្មេងណាម្នាក់មកទេ ។ មកគ្មានក្មេង៣នាក់ ដែលឪពុកឈ្មោះសាំង អ៊ុន ខ្ញុំនិយាយនៅក្នុងៗកំណត់ ហេតុឆ្លើយចំពោះលោកចៅក្រមស៊ើបអង្កេតរួចហើយ ។

**ស៖** ខ្ញុំចង់បញ្ជាក់ថា ខ្ញុំយល់ត្រូវដែរឬទេ? ម-១៣ គឺមានក្មេងតែ៣នាក់ទេ ដែលត្រូវបានឃុំនៅទីហ្នឹង ក្មេង៣នាក់ដែលលោកចិញ្ចឹម ហើយក្រៅពីហ្នឹង គឺមានក្មេង ដែលលោកដោះលែង អ៊ីចឹងតើការ

ពិត ដែរឬទេ? ចំពោះអ្វីដែលលោកបានលើកឡើង?

**ឆ៖** តាមខ្ញុំចាំ គឺប៉ុននុ៎ង ។

**ស៖** ចាតើលោកផ្តល់ចម្លើយពិស្តារឲ្យយើងបានដែរឬទេ ចំពោះអង្គការចាត់តាំងម-១៣ ? ជាពិសេស នៅពេលដែលគេនាំមនុស្សទៅម-១៣ ចាតើមានការចុះឈ្មោះ ហើយមានអគារសម្រាប់ធ្វើការចុះ ឈ្មោះ ឬតម្កល់ឈ្មោះដែរឬទេ?

**ឆ៖** សូមជម្រាបថានៅសម័យសង្គ្រាមនុ៎ង អត់មានក្រដាស អត់មានសៀវភៅអីទេ ។ ក្រដាសទៅ សុំខាងការិយាល័យមន្ទីរ២០១ហ្នឹង អាក្រដាស់គេសម្រាប់បោះពុម្ពកាសែតរបស់គេហ្នឹង យកមកហែក ហើយ អត់មានស្តាបប៉ាការសរសេរទេ សរសេរខ្មៅដៃ ។ ពេលមនុស្សចូលមកហ្នឹងមានកត់ ប៉ុន្តែដល់តែហើយ ពីកម្ទេចមនុស្សអីទៅ ក៏ដុតក្រដាសហ្នឹងចោលអស់ទៅ ទាំងចម្លើយ ទាំងអីហ្នឹងបញ្ជូនទៅលើហើយ អស់ចប់ អត់មានរក្សាទុកបញ្ជីមួយរយអីទេ ។

**ស៖** លោកបាននិយាយថាអ្នកទោសត្រូវបានដាក់ច្រវ៉ាក់ជាប់គ្នា ចាតើគេដាក់ច្រវ៉ាក់អ្នកទាំងអស់នោះ យ៉ាងម៉េច គឺគេដាក់ច្រវ៉ាក់នៅជើងឬក៏នៅដៃ?

[១៦:០៧:០៥៤]

**ឆ៖** សូមជម្រាបចៅក្រមថា មិនមែនដាក់ច្រវ៉ាក់ទេ គឺដាក់ខ្នោះ ។ មានរនុកដែកវែងអ៊ីចឹងទៅហើយ ធ្វើកងដាក់ជើង ម្នាក់ដាក់ជើងមួយៗបន្តគ្នា ។

**ស៖** ចាតើអ្នកដែលជាប់ឃុំនោះ គេបានធ្វើចំណាត់ថ្នាក់ខុសៗគ្នាដែរ ឬទេ? ឬក៏ឲ្យគេងូតទឹកដែរឬទេ? ឬក៏នៅជាប់ខ្នោះជារៀងរហូត?

**ឆ៖** ជាពិសេសស្រីៗ ព្រឹកឡើងបញ្ចេញឲ្យទៅដាំត្រប់ ចន្លោះគុកមានត្រពាំងច្រាប ឯចំណែកប្រុសៗ ច្រើនតែនៅជាប់ហ្នឹងខ្នោះហ្នឹងឯង មិនដែលបានចេញទេ មិនងាយដែលបានចេញទេ ។

**ស៖** លោកបានបញ្ជាក់ប្រាប់យើងពីខាងដើមថា ការកង្វះអាហារហ្នឹង គឺវាមិនមានអង្ករគ្រប់គ្រាន់ ដូច្នេះហើយ តើអ្នកជាប់ឃុំ តើគេមានអ្វីហូបចុកដែលគ្រាប់គ្រាន់ឬក៏យ៉ាងណា?

**ឆ៖** គ្នាទៅមានអីទៅហូបនោះ បើពួកខ្ញុំខ្លួនឯង វាអត់មានអីហូបទៅហើយ គ្នាហូបកន្ទក់ទេអាហ្នឹង សូមជម្រាបលោកចៅក្រមឲ្យត្រង់ ។

**ស៖** ដូច្នេះរបបអាហាររបស់កម្មាភិបាល ហើយនឹងអ្នកជាប់ឃុំហ្នឹង គឺខុសគ្នា?

**ឆ៖** កម្មាភិបាលវាលើសពីយុវជនបន្តិច ក៏ប៉ុន្តែយុវជនហើយនឹងពួកអ្នកទោស ដែលជនរងគ្រោះ

មកជាប់គុកនៅទីនោះ អ៊្វ!ខុសគ្នាឆ្ងាយណាស់ មើលមិនឃើញទេ ចិញ្ចឹមគ្នាឲ្យរស់សម្រាប់តែសួរចម្លើយប៉ុណ្ណោះ នេះនិយាយមួយម៉ាត់ឲ្យច្បាស់ទៅ ។

**ប្រធានអង្គជំនុំ៖**

សំឡេងហ្នឹង ដូចស្តាប់អត់ឮខាងបកប្រែ សូមចាត់ចែងរៀបចំមើលផង។

ជនជាប់ចោទអញ្ជើញនិយាយម្តងទៀត ព្រោះអម្បាញ់មិញនេះ គឺស្តាប់មិនបាន អត់មានការបកប្រែ។ សូមអញ្ជើញតទៅទៀត ។

[១៦:១១:៣៤]

**ជនជាប់ចោទ៖**

**ឆ៖** លោកចៅក្រម លោកសួរខ្ញុំថា របបកម្មាភិបាល ហើយនឹងអ្នកទោសខុសគ្នាអី?

ខ្ញុំថា កម្មាភិបាល ខ្ញុំបានជម្រាបលោកថា កម្មាភិបាល ហើយនឹងយុទ្ធជនខុសគ្នាបន្តិច ខុសគ្នាបន្តិច មិនខុសច្រើនទេ ។ ឯចំណែកៗជនរងគ្រោះដែលទៅជាប់ទោសទណ្ឌនៅទីនោះខុសគ្នាមើល មិនឃើញទេ ។ គ្នាដល់ចុងឆ្នាំ១៩៧៤ ខែ៩ ខែ១០ ឆ្នាំ១៩៧៤ ហូបតែកន្ទក់ទេ ។

ដូច្នេះវាខុសគ្នាខ្លាំងណាស់ យើងខ្ញុំចិញ្ចឹមពួកនុំងដូចជាគ្រាន់តែទុកសម្រាប់ឲ្យរស់សួរចម្លើយចប់ នឹងអាលឲ្យគ្នាស្លាប់ប៉ុណ្ណោះ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** តើលោកមានលទ្ធភាពអាចនឹងពិនិត្យមើលឃើញទេ ថានែជាប់ទោសទាំងនោះបានស្លាប់ដោយសារអត់អាហារនោះ?

**ឆ៖** អ្នកដែលឈឺស្លាប់ដោយសារអត់បាយ ហើយនឹងឈឺមាន ប៉ុន្តែជាទូទៅ ជាទូទៅមិនដែលទុកឲ្យ ដល់ថ្នាក់នុំងទេ មើលតែសួរចប់ ជាគោលការណ៍ គេឲ្យចេញទៅហើយៗ ។

**ស៖** តើបាន លោកកត់សម្គាល់ឃើញទេថា មានបុគ្គលិក គាត់មានអត់អាហារស្លាប់ដែរ ឬទេ?

**ឆ៖** តាមខ្ញុំចាំ គ្មានបុគ្គលិកណាម្នាក់ស្លាប់ដោយសារអត់បាយអីទេ អត់មានទេ ។

**ស៖** តើអ្វីលក្ខខណ្ឌអនាម័យនៅទីនោះយ៉ាងម៉េចដែលចំពោះអ្នកទោស? ជាពិសេស តើគេទៅបត់ដៃ បត់ជើងហ្នឹង តើគេអាចលាងខ្លួនប្រាណអីបានដែរឬទេ?

**ឆ៖** មន្ទីរ១៣ក នៅជិតស្ទឹង ដូច្នេះឲ្យចុះទៅ-- មន្ទីរ១៣កនៅជិតស្ទឹង ត្រពាំងនោះ ទឹកនោះរមាស់ណាស់ ប្រើមិនកើតទេ ជិតស្ទឹង ពេលដែលចុះទៅងូត គឺមុជទឹកស្ទឹង ។

ខ្ញុំសូមបញ្ជាក់ទឹកត្រពាំងច្រាបនេះ រមាស់ អាត្រពាំងហ្នឹងវារមាស់ អាទឹកស្ទឹងបានវាល្អ ហើយ ខ្ញុំបានបញ្ចេញអ្នកទោស ដែលជាជនរងគ្រោះហ្នឹងឲ្យទៅមុជទឹកស្ទឹង ។

[១៦:១៦:៣៤]

**ស៖** តើអ្នកទោសទាំងអស់ទទួលការអនុញ្ញាតឲ្យទៅងូតទឹកនោះដែរ នៅទឹកស្ទឹងនោះដែរ ឬទេ?

**ឆ៖** ទៅងូតរាល់ថ្ងៃ ខ្មោច មិត្តមាស ជាអ្នកជូនទៅ ។

**ស៖** តើគេដាក់ច្រវ៉ាក់ចងភ្ជាប់ជាមួយគ្នាទៅងូតទឹកឬ?

**ឆ៖** អត់មានចងអីទេ ឯចំណែកប្រុសៗយកខ្សែអង្រឹងចង ។

**ស៖** លោកបានប្រាប់យើងថា មិនមានការថែទាំវេជ្ជសាស្ត្រអីទេ តើលោកអាចបញ្ជាក់បន្ថែមបានទៀតទេ?

**ឆ៖** ប្រាកដ អត់ប្រកែកទេ សូម្បីតែ--

**ស៖** លោកនិយាយអំពីរណ្តៅ តើអាចប្រាប់យើងបានទេថា ថាតើរណ្តៅទាំងនេះត្រូវបានជីកដើម្បីលាក់កំបាំងអ្នកទោសពីទម្លាក់គ្រាប់បែក ឬក៏ជីកដើម្បីគោលបំណងអ្វីផ្សេង?

**ឆ៖** អាមួយដែលយើងខ្ញុំជីកនេះ សម្រាប់ដាក់ជនរងគ្រោះឲ្យផុតអំពីគ្រោះថ្នាក់នៃគ្រាប់បែកអាហ្នឹងមួយបែប ។ អាមួយបែបទៀតនៅម្ខាងស្ទឹង ខាងនៅម្ខាងនោះស្ទឹង គឺជីករណ្តៅអ៊ីចឹង សម្រាប់កប់សាកសព ហើយមានមួយបែបទៀត យើងខ្ញុំជីករណ្តៅហ្នឹងទៅ គ្របពីលើទៅជាត្រង់សេ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំគិតថា យើងនឹងផ្អាកសម្រាប់ល្ងាចនេះ អ៊ីចឹងសូមអញ្ជើញលោកប្រធានបន្ត ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះយើងត្រូវឈប់សម្រាកនៅពេលល្ងាចនេះហើយ អង្គជំនុំជម្រះសាលាដំបូងសូមប្រកាសផ្អាកសវនាការនៅថ្ងៃនេះ ត្រឹមនេះ សវនាការនឹងបន្តនៅពេលព្រឹកនៅថ្ងៃស្អែកទី៧ ខែមេសា ឆ្នាំ២០០៩ ជាប់ពីម៉ោង៩ទៅ ។

អង្គជំនុំជម្រះ បង្គាប់អនុរក្សមន្ទីរឃុំឃាំងឲ្យនាំជនជាប់ចោទត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឲ្យនាំខ្លួនគាត់ មកកាន់សាលសវនាការនៅថ្ងៃស្អែកឲ្យបានមុនម៉ោង៩ព្រឹកជាកំហិត ។ សូមជម្រាបដល់អ្នកចូលរួមក្នុងនីតិវិធីសវនាការ និងសាធារណជន សូមអញ្ជើញចូលមកកាន់បន្ទប់សវនាការឲ្យបានមុនម៉ោង៩ព្រឹក ៕

**លោកស្រី សែ កុលវឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ ។

*[សវនាការផ្អាកនៅម៉ោង ១៦:២០:៤៥នាទី]*